ទស្សនាវដ្ដីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

# ស្វែងរក ការពិត



- អនុសញ្ញាស្ដីពីអំពើប្រល័យពូជសាសន៍
- នៅតែសោកស្ដាយ

ចែកជូនដោយឥតគិតថ្លៃដល់មន្ទីរស្រុកនិងឃុំទូទាំងព្រះរាជាណាចក្រកម្ពុជា

លេខ១៧១ ខែមីនា ឆ្នាំ២០១៤

ទស្សនាវដ្តីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

# ស្វែងរកការពិត

លេខ១៧១ ខែមីនា ឆ្នាំ២០១៤


## មាតិកា


◆ អនុសញ្ញាស្តីពីអំពើប្រល័យពូជសាសន៍ ..........១

◆ សំណើសុំចំពោះការគាំទ្រដល់អង្គការក្រៅ ..........៣

**ផ្នែកឯកសារ**

◆ យិន ដួង ប្រធានក្រុមចោរព្រៃតំបន់បូព៌ា ..........៤

**ផ្នែកប្រវត្តិសាស្ត្រនិងការស្រាវជ្រាវ**

◆ អំពើប្រល័យពូជសាសន៍ជនជាតិចាម ..........១០

◆ សន្យាបុស្សី ៈ គុកឥតជញ្ជាំង សៀវភៅរៀប ..........១៦

◆ ក្លាយជាខ្មែរក្រហមដោយមិនដឹងខ្លួន ..........២០

◆ ការសោកស្តាយ និងសំណាង ..........២២

◆ ជីវិតតស៊ូរបស់ សួង ដុស នៅក្នុងរបបខ្មែរក្រហម ..........២៣

**ផ្នែកច្បាប់**

◆ ការរៀបចំសំណង ការប្រឈមរបស់ដើមបណ្តឹង ..........២៨

◆ ការបង្ហាញនៃការជម្លៀសដោយបង្ខំ ..........៣៦

**វេទិកាពិភាក្សាសាធារណៈ**

◆ តើសំណងអ្វីខ្លះដែលដើមបណ្តឹងរដ្ឋប្បវេណីអាចទទួល ..........៣៨

**ទំព័រស្រាវជ្រាវរកគ្រួសារ**

◆ នៅតែសោកស្តាយ ..........៥០

◆ ស្ត្រីដែលជានិមិត្តរូបរបស់ខ្ញុំ ..........៥៣

◆ ញឹម ចាន់ ជីវិតស្ថិតនៅក្រោមការសម្រេចរបស់ ..........៥៥

◆ ដំណើរជីវិតរបស់ ព្រំ គៀម ក្នុងរបបខ្មែរក្រហម ..........៥៦

◆ រឿងរ៉ាវរបស់ ឯក ស៊ីប៉ូរ៉ាន់ ..........៥៨

◆ មួយឆ្នាំបានហូបតែមួយវដូវ ..........៦០

◆ ឪពុករបស់ខ្ញុំនៅក្នុងរបបខ្មែរក្រហម ..........៦១




ឪពុករបស់ ទូច សាគន្ធ (រូបខាងឆ្វេង) ថតឆ្នាំ១៩៦៨។ សូមអានរឿងរបស់ ទូច សាគន្ធ នៅទំព័រទី៥០


## រក្សាសិទ្ធិ

មជ្ឈមណ្ឌលឯកសារកម្ពុជា

អនុញ្ញាតឲ្យបោះពុម្ពផ្សាយដោយ
ក្រសួងព័ត៌មាននៃព្រះរាជាណាចក្រកម្ពុជា
ប្រកាសទេសរដ្ឋមន្ត្រីនិងរដ្ឋមន្ត្រីក្រសួងព័ត៌មាន
លេខ០២៩១ពម.៩៩
ចុះថ្ងៃទី២ ខែសីហា ឆ្នាំ១៩៩៩

រូបថតឯកសារៈ មជ្ឈមណ្ឌលឯកសារកម្ពុជា
និងសារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង



***ស្នេរលេខនេះ៖*** *ឆាយ ដាវីន, ជុំ ម៉ាប់, លឹម ជ័យទ័ត្ត, ផូលេខ គូស័រ, លី សុខឃាង, គ្រីស៊ីន ប័រគ័រលី, ហ៊ុយ សម្ផស្ស, ហ័តសុន ម៉ាក់ហ្វាន, ផាត កុសល, ហួរ ហាច, អៀង ណារី, ឃឹម ទិត្យពិសី, វង្ស សុសីហា, យ៉ុង សុធឿន* ***អ្នកនិពន្ធនិងស្រាវជ្រាវ៖*** *ទាវ សារៈមុនិន្ទ, ស៊ិន សុធីតា* ***អ្នកបកប្រែ៖*** *នង ច័ន្ទមល្លិកា និង ភួង ច័ន្ទប្រណិត* ***និពន្ធនាយកទូទៅ៖*** *ឆាំង យុ និង ញាណ សុជាតិ* ***ជំនួយការនិពន្ធនាយក៖*** *សោម ប៊ុនថន* ***ក្រាហ្វិកកុំព្យូទ័រ៖*** *សោម ប៊ុនថន* ***គ្រប់គ្រងការចែកផ្សាយ៖*** *ឆេង វ៉េង*



Email: dccam@online.com.kh, Homepage: www.dccam.org, www.cambodiatribunal.org, www.cambodiasri.org

# រំឭកខួបលើកទី៦៥នៃអនុសញ្ញាស្តីពីការទប់ស្កាត់និងការដាក់ទណ្ឌកម្មឧក្រិដ្ឋកម្មនៃអំពើប្រល័យពូជសាសន៍

ក្នុងឱកាសដែលយើងប្រារព្ធពិធីរំឭកខួបលើកទី៦៥នៃការផ្តល់សច្ចាប័នលើអនុសញ្ញាស្តីពីការទប់ស្កាត់និងការដាក់ទណ្ឌកម្មឧក្រិដ្ឋកម្មនៃអំពើប្រល័យពូជសាសន៍នេះ ខ្ញុំមានចិត្តរីករាយជាអនេក ប៉ុន្តែជាមួយគ្នានោះដែរ ខ្ញុំនៅតែមិនអាចទប់អារម្មណ៍ប្រេះប្រួលបាននៅឡើយ ។ ក្នុងនាមមជ្ឈមណ្ឌលឯកសារកម្ពុជាជាអង្គការក្រៅរដ្ឋាភិបាលអន្តរជាតិមួយដែលបានធ្វើកិច្ចការងារជំនួសមុខឲ្យជនរងគ្រោះនៃការរំលោភបំពានសិទ្ធិមនុស្សធ្ងន់ធ្ងរអស់រយៈពេលជិតពីរទសវត្សរ៍កន្លងមកនេះ ខ្ញុំមានកិត្តិយសយ៉ាងខ្លាំងដែលមានឱកាសធ្វើកិច្ចការនេះ ។ ក្នុងនាមខ្ញុំជាជនរងគ្រោះមួយរូបនៃរបបខ្មែរក្រហម (របបមួយដែលប្រជាជនកម្ពុជាប្រមាណចន្លោះពី១លានដល់២លាននាក់បានស្លាប់) ខ្ញុំនៅតែមានអារម្មណ៍ខកចិត្តចំពោះកិច្ចការមួយចំនួនដែលយើងកំពុងធ្វើនៅពេលនេះ ដើម្បីបង្ការ និងទប់ស្កាត់អំពើប្រល័យពូជសាសន៍ និងអំពើរំលោភបំពានសិទ្ធិមនុស្សធ្ងន់ធ្ងរនាពេលអនាគត ។

យើងបានធ្វើដំណើរលើកំណាត់ផ្លូវយ៉ាងវែងឆ្ងាយក្នុងការពង្រឹងនូវវិធីសាស្ត្រ និងគោលនយោបាយដ៏មានតម្លៃមួយចំនួនដើម្បីឆ្លើយតបទៅនឹងការប្រឈមនៃការដោះស្រាយ និងការដាក់ទណ្ឌកម្មលើអំពើប្រល័យពូជសាសន៍ ។ ដោយទទួលស្គាល់ថា ដើមចមនៃអំពើប្រល័យពូជសាសន៍ផ្តោតលើភាពមិនស្មើគ្នារវាងក្រុមដែលមានអត្តសញ្ញាណ យើងបានផ្តោតជាសំខាន់លើទិដ្ឋភាពផ្នែកច្បាប់ និងរដ្ឋាភិបាលស្តីពីការទប់ស្កាត់អំពើប្រល័យពូជសាសន៍ ។ ទាក់ទងទៅនឹងការដាក់ទណ្ឌកម្ម តុលាការផ្សេងៗជាច្រើនត្រូវបានបង្កើតឡើងដើម្បីឆ្លុះបញ្ចាំងអំពីសកម្មភាពរំលោភបំពានសិទ្ធិមនុស្សធ្ងន់ធ្ងរនៃរបបឧក្រិដ្ឋកម្ម ហើយបានដាក់ទណ្ឌកម្មមេដឹកនាំកំពូលដែលទទួលខុសត្រូវខ្ពស់បំផុត ។

ប៉ុន្តែទន្ទឹមពេលដែលវិធីសាស្ត្រ និងគោលនយោបាយទាំងនេះឆ្លុះបញ្ចាំងអំពីការប្តេជ្ញាចិត្តក្នុងការដោះស្រាយឧក្រិដ្ឋកម្មនៃអំពើប្រល័យពូជសាសន៍ នៅមានកិច្ចការងារជាច្រើនទៀតដែលនឹងត្រូវធ្វើដើម្បីទប់ស្កាត់អំពើប្រល័យពូជសាសន៍នេះ ។ ពិតប្រាកដណាស់ កិច្ចការងារទប់ស្កាត់អំពើប្រល័យពូជសាសន៍ស្ថិតនៅក្នុងកិច្ចខិតខំប្រឹងប្រែងដែលយើងបានធ្វើ ។ ការជួយរដ្ឋក្នុងកិច្ចការដោះស្រាយភាពមិនស្មើគ្នារវាងក្រុមនិងក្រុម ការបង្កើតជាយន្តការឲ្យដឹងជាមុនឬយន្តការទប់ស្កាត់ ឬការដាក់ទោសជនល្មើសឲ្យជាប់ពន្ធនាគារអស់មួយជីវិត បានទប់ស្កាត់នូវអំពើប្រល័យពូជសាសន៍ក្នុងកម្រិតជាតិ និងអន្តរជាតិ ។

ប៉ុន្តែ នៅពេលដែលយើងប្រមូលផ្តុំគ្នាដើម្បីរំឭកដល់អនុសញ្ញាអន្តរជាតិ វាមានសារសំខាន់ក្នុងការទទួលស្គាល់ដែលថា ការពុះពាររបស់យើងមិនមែនជាការយន្តការតែមួយគត់ដែលអាចដោះស្រាយរាល់បញ្ហាក្នុងកម្រិតជាតិឬអន្តរជាតិទេ ។ គោលការណ៍មួយក្នុងចំណោមគោលការណ៍ដែលយើងជួបប្រទះនាពេលបច្ចុប្បន្នក្នុងការទប់ស្កាត់អំពើប្រល័យពូជសាសន៍ ដែលយើងបានធ្វើអស់រយៈពេលជាង៦០ឆ្នាំកន្លងមកនេះ គឺជាការតស៊ូក្នុងកម្រិតតំបន់ ។ ការរើសអើង ការប្រកាន់ពូជសាសន៍ ការគំរាមកំហែង និងអំពើឃោរឃៅ ដែលនាំទៅរកការធ្វើឲ្យមានអំពើហិង្សាលើមនុស្សជាតិទៅជាមានលក្ខណៈស្របច្បាប់ ត្រូវបានដោះស្រាយក្នុងកម្រិតបុគ្គល និងសហគមន៍ ហើយមិនមានមធ្យោបាយ ឬយន្តការដ៏ប្រសើរណាមួយក្នុងការដោះស្រាយនូវលក្ខខណ្ឌនាំទៅរកអំពើប្រល័យពូជសាសន៍ជាជាងមធ្យោបាយនៃការអប់រំអំពីអំពើប្រល័យពូជសាសន៍នោះទេ ។

ការអប់រំអំពីអំពើប្រល័យពូជសាសន៍ គឺជាផ្នែកមួយដ៏សំខាន់ក្នុងយុទ្ធនាការរបស់យើងដើម្បីបង្កើតវប្បធម៌មួយដែលឲ្យតម្លៃលើសិទ្ធិមនុស្ស បុគ្គល និងសង្គម ។ ការអប់រំអំពីអំពើប្រល័យពូជសាសន៍អាចជាមធ្យោបាយមួយក្នុងការស្វែងរកយុត្តិធម៌ ការផ្សះផ្សា ការចងចាំ ហើយសំខាន់ជាងនេះ ការយល់ដឹងអំពីបុគ្គល ។

ទន្ទឹមពេលដែលការអប់រំអំពីអំពើប្រល័យពូជសាសន៍ មិនមានជាឱសថព្យាបាលបញ្ហារបស់យើងក្នុងការទប់ស្កាត់អំពើប្រល័យពូជសាសន៍ ពិតប្រាកដណាស់ វាជាមធ្យោបាយមួយដែលសមទទួលបានការយកចិត្តទុកដាក់កាន់តែខ្លាំង ។

ពិតប្រាកដណាស់ មានកម្មវិធីសិក្សាអំពីសន្តិភាពផ្សេងៗជាច្រើននៅក្នុងប្រទេសដែលងើបចេញពីជម្លោះ ហើយការសិក្សាអំពី ហូឡូខស៍ គឺជាផ្នែកដ៏សំខាន់នៃការពុះពាររបស់យើងដើម្បីកសាងការយល់ដឹងអំពីសិទ្ធិមនុស្ស និងប្រវត្តិសាស្ត្រ ។ ប៉ុន្តែដើម្បីឲ្យមានប្រសិទ្ធិភាព ការអប់រំអំពីអំពើប្រល័យពូជសាសន៍ត្រូវតែធ្វើឡើងក្នុងតំបន់ ។ កម្មវិធីសិក្សាក្នុងតំបន់ គឺជាកម្មវិធីមួយដែលផ្សារភ្ជាប់ជាមួយនឹងវប្បធម៌ក្នុងតំបន់ វិធីសាស្ត្របង្រៀន និងប្រវត្តិសាស្ត្រក្នុងតំបន់ ។ ការអប់រំអំពីអំពើប្រល័យពូជសាសន៍ដែលមានប្រវត្តិសាស្ត្រ វប្បធម៌ និងការអប់រំគរុកោសល្យបែបបរទេសអាចប្រមើលមើលឃើញនូវបរិបទនៃទិដ្ឋភាពរំលោភអំណាចដូចគ្នាដែលបណ្តាលឲ្យមានការរំលោភសិទ្ធិមនុស្សធ្ងន់ធ្ងរ ។ សិទ្ធិមនុស្ស ការយល់ពីសមានចិត្ត និងការឲ្យតម្លៃផ្សេងៗ គឺជាតម្លៃដែលអាចកើតមានក្នុងខ្លួនរបស់មនុស្ស នៅពេលដែលបុគ្គលមានទំនុកចិត្តលើការសិក្សាអំពីតម្លៃនេះដោយខ្លួនឯងជាមួយនឹងសេរីភាព និងការទទួលខុសត្រូវ ។

ក្នុងន័យនេះ ការអប់រំអំពីអំពើប្រល័យពូជសាសន៍គឺជាការអប់រំដែលត្រូវពង្រឹងជាមួយនឹងសហគមន៍អ្នកសិក្សារៀនសូត្រជាជាងសម្រាប់សហគមន៍អ្នកសិក្សារៀនសូត្រ ។

ការកម្រិតក្នុងថ្នាក់តំបន់ មិនមែនជារឿងងាយស្រួលនោះឡើយ ។ មជ្ឈមណ្ឌលឯកសារកម្ពុជា បានតស៊ូពុះពារអនុវត្តកម្មវិធីអប់រំអំពីអំពើប្រល័យពូជសាសន៍របស់ខ្លួននៅក្នុងប្រទេសកម្ពុជាចាប់តាំងពីឆ្នាំ២០០៤ សហការជាមួយក្រសួងអប់រំ យុវជន និងកីឡា ។ ប្រវត្តិសាស្ត្រនៃរបបខ្មែរក្រហម (ដែលស្គាល់ថាជារបបកម្ពុជាប្រជាធិបតេយ្យ) ត្រូវបានបង្រៀន ហើយត្រូវបានបញ្ឈប់ទៅវិញអស់រយៈពេលជាច្រើនឆ្នាំក្នុងប្រទេសកម្ពុជា ។ ទោះបីជាយ៉ាងណាក៏ដោយ ក្នុងឆ្នាំ២០០៧ មជ្ឈមណ្ឌលឯកសារកម្ពុជាបានបោះពុម្ពផ្សាយសៀវភៅសិក្សាអំពីប្រវត្តិសាស្ត្រនៃរបបកម្ពុជាប្រជាធិបតេយ្យ ហើយក្រោយមក ក្នុងឆ្នាំ២០០៩ មជ្ឈមណ្ឌលឯកសារកម្ពុជាបានចាប់ផ្តើមបណ្តុះបណ្តាលគ្រូបង្រៀនអំពីប្រវត្តិសាស្ត្រនេះនៅទូទាំងប្រទេសកម្ពុជា ។ ចាប់តាំងពីឆ្នាំ២០០៧មក សៀវភៅសិក្សាជាងប្រាំសែនក្បាលត្រូវបានបោះពុម្ព ហើយត្រូវបានចែកចាយទៅកាន់វិទ្យាល័យទាំងអស់នៅទូទាំងប្រទេស ហើយគ្រូបង្រៀនជាងបីពាន់នាក់ត្រូវបានបណ្តុះបណ្តាលអំពីកម្មវិធីសិក្សានេះ ។ បច្ចុប្បន្ន កម្មវិធីសិក្សានេះ គឺជាមុខវិជ្ជាតម្រូវនៅតាមវិទ្យាល័យទាំងអស់ ហើយត្រូវបានដាក់បញ្ចូលនៅតាមសកលវិទ្យាល័យ និងរាជបណ្ឌិត្យសភាបណ្តុះបណ្តាលវិជ្ជាជីវៈនគរបាលនិងយោធា ។ ការប្រែក្លាយការទប់ស្កាត់អំពើប្រល័យពូជសាសន៍ឲ្យទៅជាកិច្ចខិតខំប្រឹងប្រែងក្នុងតំបន់ តាមរយៈការអប់រំអំពីអំពើប្រល័យពូជសាសន៍ មិនមែនជារឿងងាយស្រួលនោះទេ ហើយយើងនៅតែមានការងារច្រើនជាងនេះដែលត្រូវធ្វើ ។ អាស្រ័យហេតុនេះ តម្លៃនៃការអប់រំអំពីអំពើប្រល័យពូជសាសន៍ទាក់ទងនឹងការលើកស្ទួយយុត្តិធម៌ ការផ្សះផ្សា និងការចងចាំមិនអាចនិយាយបំផ្លើសនោះទេ ។

សិទ្ធិមនុស្ស និងប្រវត្តិសាស្ត្រ មានទំនាក់ទំនងគ្នាទៅវិញទៅមក ពីព្រោះដើម្បីយើងមិនអាចនិយាយអំពីសិទ្ធិមនុស្សដោយមិនគិតពីប្រវត្តិសាស្ត្រ ហើយក៏មិនអាចនិយាយពីប្រវត្តិសាស្ត្រដោយមិនបានគិតពីសិទ្ធិមនុស្សនោះឡើយ ។ ដើម្បីទប់ស្កាត់អំពើប្រល័យពូជសាសន៍ឲ្យមាននិរន្តរភាព ការទប់ស្កាត់នោះត្រូវតែបានយល់ដឹងជាសកលក្នុងកម្រិតអន្តរជាតិ ហើយក៏ត្រូវតែសាបព្រោះដល់ប្រជាជនសាមញ្ញ ។ ការអប់រំត្រូវតែជាជំហានបន្ទាប់ឆ្ពោះទៅមុខក្នុងការងាររបស់យើង ដើម្បីបង្កើតពិភពលោកមួយគ្មានអំពើប្រល័យពូជសាសន៍ ។ **ឆាំង យុ**

◆ **និយាយពីការរស់នៅក្នុងសម័យខ្មែរក្រហម គឺនិយាយពីការផ្សះផ្សា អប់រំកូនចៅឱ្យអត់ឱន អធ្យាស្រ័យគ្នា**

◆ **រៀនប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ គឺរៀនពីការទប់ស្កាត់អំពើប្រល័យពូជសាសន៍**

# សំណើសុំចំពោះការគាំទ្រដល់អង្គការក្រៅរដ្ឋាភិបាលនៅតំបន់អាស៊ីអាគ្នេយ៍

មជ្ឈមណ្ឌលឯកសារកម្ពុជាសូមស្នើសុំដោយក្តីគោរពចំពោះឯកឧត្តមអគ្គលេខាធិការដើម្បីគាំទ្រឲ្យមានការចុះឈ្មោះមជ្ឈមណ្ឌលឯកសារកម្ពុជា ជាអង្គការក្រៅរដ្ឋាភិបាលនៅក្នុងសហគមន៍ប្រជាជាតិអាស៊ីអាគ្នេយ៍ ហៅកាត់ថា “អាស៊ាន” ។ ក្នុងនាមជាអង្គការក្រៅរដ្ឋាភិបាលនៅក្នុងតំបន់អាស៊ីអាគ្នេយ៍ មជ្ឈមណ្ឌលឯកសារកម្ពុជាអាចលើកកម្ពស់ភាពជាអ្នកដឹកនាំរបស់ប្រទេសកម្ពុជានៅក្នុងការអប់រំអំពីអំពើប្រល័យពូជសាសន៍ក្នុងតំបន់ និងបង្កើតបណ្តាញបន្ថែមសម្រាប់ការផ្លាស់ប្តូរព័ត៌មាន និងធនធានជាមួយនឹងប្រទេសជិតខាង ។

ដូចដែលឯកឧត្តមបានដឹងយ៉ាងច្បាស់ មជ្ឈមណ្ឌលឯកសារកម្ពុជា ត្រូវបានទទួលស្គាល់ក្នុងកម្រិតអន្តរជាតិចំពោះភាពជំនាញ និងបទពិសោធរបស់ខ្លួនក្នុងការអប់រំអំពីអំពើប្រល័យពូជសាសន៍ ។ ដោយមានការសហការជាមួយនឹងក្រសួងអប់រំ យុវជន និងកីឡា មជ្ឈមណ្ឌលឯកសារកម្ពុជាបានបណ្តុះបណ្តាលគ្រូជាង៣.០០០នាក់ហើយបានចែកចាយសៀវភៅប្រវត្តិសាស្ត្រចំនួនជាងប្រាំសែនក្បាល ។ មិនមានអង្គការក្រៅរដ្ឋាភិបាល ឬប្រទេសណាផ្សេងនៅក្នុងតំបន់អាស៊ាន អាចប្រៀបប្រដូចនឹងសមត្ថភាព ឬភាពអាចជឿទុកចិត្តបានរបស់មជ្ឈមណ្ឌលឯកសារកម្ពុជាក្នុងការអប់រំអំពីអំពើប្រល័យពូជសាសន៍បានទេ ។

ការលើកស្ទួយការអប់រំអំពីអំពើប្រល័យពូជសាសន៍របស់ប្រទេសកម្ពុជានៅក្នុងតំបន់អាស៊ាន នឹងបំពេញនូវចន្លោះប្រហោងដ៏សំខាន់ ហើយបង្កើននូវអានុភាពរបស់ប្រទេសកម្ពុជានៅក្នុងតំបន់ ។ មិនមានប្រទេសអាស៊ានណាបានធ្វើផែនការផ្តួចផ្តើមបង្កើតកម្មវិធីអប់រំអំពីអំពើប្រល័យពូជសាសន៍ ស្រដៀងគ្នានេះទេ ហើយការលើកកម្ពស់ មជ្ឈមណ្ឌលឯកសារកម្ពុជា ចូលក្នុងចំណោមអង្គការក្រៅរដ្ឋាភិបាលនៅក្នុងតំបន់នឹងបង្កើនអានុភាពរបស់ប្រទេសកម្ពុជានៅក្នុងប្រព័ន្ធអប់រំក្នុងតំបន់ ។

ការលើកកម្ពស់ភាពជាអ្នកដឹកនាំរបស់ប្រទេសកម្ពុជានៅក្នុងការអប់រំអំពីអំពើប្រល័យពូជសាសន៍ក្នុងឆាកអាស៊ានមិនមែនជាស្នាដៃតូចតាចសម្រាប់រដ្ឋាភិបាលកម្ពុជា និងប្រជាជននោះទេ ។ នៅពេលអាស៊ានជិតនឹងត្រូវធ្វើសមាហរណកម្មក្នុងតំបន់ ប្រទេសដែលទទួលផលប្រយោជន៍ច្រើននោះ នឹងក្លាយជាប្រទេសដែលបានចាប់ផ្តើមការផ្លាស់ប្តូរទស្សនវិស័យកម្រិតក្នុងស្រុក និងថ្នាក់ជាតិ ទៅជាកម្រិតថ្នាក់តំបន់ និងអន្តរជាតិ ។ ទន្ទឹមពេលដែលជាធម្មតា រដ្ឋាភិបាលបានរួមចំណែកភាគច្រើនដល់កិច្ចខិតខំប្រឹងប្រែងនេះ អង្គការក្រៅរដ្ឋាភិបាលអាចធ្វើជាអ្នកនាំមុខទីពីក្នុងការផ្លាស់ប្តូរព័ត៌មាន និងធនធាន ។

ប្រទេសកម្ពុជានឹងទទួលផលប្រយោជន៍ដោយផ្ទាល់ និងប្រយោលពីភាពជាអ្នកដឹកនាំក្នុងតំបន់ ។ ទាក់ទងទៅនឹងឥទ្ធិពលដោយផ្ទាល់ សហគមន៍អប់រំនៅក្នុងប្រទេសកម្ពុជានឹងទទួលផលប្រយោជន៍ពីឱកាសក្នុងការផ្លាស់ប្តូរ និងឋានៈកាន់តែច្រើន ហើយសំឡេងរបស់ប្រទេសកម្ពុជានឹងទទួលបានការយកចិត្តទុកដាក់កាន់តែខ្លាំង ដោយសារកម្ពុជាចូលរួមក្នុងកិច្ចខិតខំប្រឹងប្រែងក្នុងការអប់រំនេះ ។

ទាក់ទងទៅនឹងឥទ្ធិពលដោយប្រយោល ការលើកកម្ពស់ការអប់រំអំពីអំពើប្រល័យពូជសាសន៍ ក្នុងកម្រិតតំបន់ នឹងឆ្លុះបញ្ចាំងការប្តេជ្ញាចិត្តបន្ថែមរបស់រដ្ឋាភិបាលកម្ពុជាលើសិទ្ធិមនុស្ស ។

សរុបសេចក្តីមក មជ្ឈមណ្ឌលឯកសារកម្ពុជាមើលឃើញឱកាសនេះ ជាឱកាសមួយមិនគួរឲ្យជឿសម្រាប់អង្គការក្រៅរដ្ឋាភិបាល ប្រទេសកម្ពុជានិងតំបន់ ហើយយើងទន្ទឹងរង់ចាំការណែនាំ និងការគាំទ្ររបស់ឯកឧត្តមលើសំណើរបស់យើង ។

**ឆាំង យុ**

# យិន ឌួង ប្រធានក្រុមចោរព្រៃភូមិភាគបូព៌ា

*ដកស្រង់ចេញពីឯកសារចម្លើយសារភាព D៥៩៦៨៣*

យិន ឌួង មានអាយុ២៩ឆ្នាំ មានស្រុកកំណើតនៅភូមិរើល ឃុំដូនតី ស្រុកពញាក្រែក តំបន់២០ ភូមិភាគបូព៌ា ។ ឪពុកឈ្មោះ យិន គឹម និងម្តាយឈ្មោះ យ៉ាន ។ ឌួង ត្រូវបានអង្គការចាប់ខ្លួននៅថ្ងៃទី១ ខែវិច្ឆិកា ឆ្នាំ១៩៧៨ ។ នៅក្នុងឯកសារចម្លើយសារភាពដែលមានចំនួនសែសិបទំព័រ ឌួង បានរៀបរាប់យ៉ាងលម្អិតអំពីសកម្មភាពរបស់ខ្លួន និងខ្សែសង្វាក់ក្នុងការបំផ្លាញអង្គការបដិវត្តន៍ ។ ខាងក្រោមនេះជាសេចក្តីសង្ខេបចម្លើយសារភាពរបស់ យិន ឌួង ៖

ពាក់កណ្តាលឆ្នាំ១៩៧០ ខ្ញុំចូលធ្វើបដិវត្តន៍នៅក្នុងឈ្លបភូមិរើល ឃុំដូនតី តាមរយៈ សំបូរ ជាប្រធានពេទ្យតំបន់២០ ។ ក្រោយមក ខ្ញុំបានចូលធ្វើ សេ.អ៊ី.អា តាមការចាត់តាំងរបស់ សំបូរ ដោយមានតួនាទីជាអ្នកបំផ្លាញបដិវត្តន៍ ហើយសមាជិកដែលចូលរួមនៅពេលនោះមានឈ្មោះ ឡាង សមាជិកឃុំដូនតី, ជៀប ប្រធានសហករណ៍ភូមិពាមរាក់, សេង ប្រធានភូមិពាមស្វាយ, ហឿង សមាជិកឃុំ និង ប៉េង ប្រធានភូមិ ។ សំបូរ និង ស៊ឹម បានណែនាំខ្ញុំនិងអ្នកទាំងអស់គ្នាឲ្យបំផុសប្រជាជនប្រឆាំងនឹងកម្លាំងរបស់អង្គការ ។ ខ្ញុំ, ហឿង និង ជៀប បានបំផុសប្រជាជនឲ្យប្រឆាំងនឹង



*រូបថតអ្នកទោសនៅមន្ទីរសន្តិសុខ-២១*

អង្គការបដិវត្តន៍ ដោយលើកថា ធ្វើបដិវត្តន៍លំបាកគ្មានសិទ្ធិសេរីភាពការដើរហើរលំបាក មិនដូចពីសង្គម ។ ក្រោយមក ឡាង បានចាត់តាំងខ្ញុំមកចូលនៅក្នុងកងទ័ពស្រុកពញាក្រែក តំបន់២០ ។

ឡាង ឲ្យខ្ញុំមកទាក់ទងខ្មែរ សេ.អ៊ី.អា នៅស្រុកនិងកងទ័ពស្រុកពញាក្រែក មួយចំនួនមានឈ្មោះ ស៊ឹម លេខាស្រុក, ភុន ប្រធានឃោសនាការស្រុក, សាលី ជំនួយការស្រុក និង ផល ប្រធានពេទ្យស្រុក ។ មួយរយៈក្រោយមក ខ្ញុំបានជួបជាមួយ ស៊ឹម រួចគាត់បានហៅខ្ញុំណែនាំឲ្យទាក់ទងជាមួយឈ្មោះ សារ៉ែន ប្រធានយោធា, បូ ប្រធានទ័ព, ឡាត់, សន ប្រធានទ័ពស្រុក, ស៊ិន អនុក្រុម, ថៃ, ថេង, សំ, សាយ និង ស៊ាង ហេង ។ ក្រោយមក ខ្ញុំមកនៅក្នុងយោធាស្រុក សារ៉ែន បានឲ្យខ្ញុំកសាងកម្លាំង សេអ៊ីអា ថែមទៀត គឺ យ៉ុន, សាម៉ា និង សង្ហា ។ បន្ទាប់មក សារ៉ែន បានចាត់តាំងឲ្យខ្ញុំធ្វើជាកម្មាភិបាលអប់រំឈ្លបនៅស្រុកពញាក្រែក ។ ខ្ញុំជាមួយខ្មែររបស់ខ្ញុំ បានបំផុសយុទ្ធជនពីរបបសង្គមចាស់មានការសប្បាយនិងលើកឡើងឲ្យយុទ្ធជនឃើញថា របបបដិវត្តន៍មានការតឹងតែង ។

ក្រោយរំដោះថ្ងៃ១៧ មេសា ឆ្នាំ១៩៧៥ សារ៉ែន បានឲ្យខ្ញុំទាក់ទងជាមួយខ្មែរ សេ.អ៊ី.អា បន្ថែម ដោយមានឈ្មោះ សួស ប្រធានឃុំខ្ទួរមានជ័យ, យ៉ាន អនុឃុំខ្ទួរមានជ័យ, ដួន ប្រធានឃុំដូនតី, ម៉ុន អនុឃុំដូនតី, សៅ ប្រធានឃុំ, យន អនុឃុំដូនតី និង អែម សមាជិកឃុំដូនតី ។ បន្ទាប់មក ខ្ញុំទាក់ទងអ្នកទាំងបីឃុំឲ្យធ្វើសកម្មភាពបំផុសកងឈ្លបនៅតាមឃុំទាំងបី ។ ក្រោយមក សារ៉ែន បានហៅខ្ញុំ, សាម៉ា, សង្ហា, សារ៉ាត និង យ៉ុន ទៅប្រជុំដាក់ផែនការ ដោយចាត់តាំងឲ្យខ្ញុំទៅទាក់ទងយួន ហើយយកស្រូវរបស់អង្គភាពយោធាស្រុកទៅឲ្យយួនឈ្មោះ ថាញ់ នាទីសេដ្ឋកិច្ចរបស់យោធាតំបន់តៃនិញ ចំនួន១២បាវ ដើម្បីសហការជាខ្មែរត្រៀម សម្រាប់ផែនការវាយបក្សកុម្មុយនីស្តកម្ពុជានៅពេលក្រោយ ។ ក្រៅពីកិច្ចការទាំងនេះ ខ្ញុំមានភារកិច្ចជ្រើសរើសកងឈ្លបឃុំមកធ្វើទ័ពរបស់តំបន់បូព៌ា ។ សកម្មភាពខ្ញុំនៅពេលនោះ គឺធ្វើឲ្យប្រជាជនខឹងនឹងបដិវត្តន៍ដែលដាក់ទិសដៅឲ្យយុទ្ធជនទៅធ្វើយោធា ។ ក្រោយមក ឈ្មោះ សារ៉ែន បានចាត់តាំងខ្ញុំមកទទួលជាសមាជិកទី១ខាងផលិតកម្ម ស្រុកពញាក្រែក ។ នៅទីនោះ ខ្ញុំមានខ្មែររយៈមួយចំនួនគឺ ឡាង ជាខ្មែររបស់ខ្ញុំផ្ទាល់, ផាន សមាជិកសហករណ៍, ជា ប្រធានភូមិ, ផន សមាជិកភូមិទី១, ឆាយ ប្រធានសហករណ៍, ស៊ុយ អនុភូមិ, យុំ សមាជិកសហករណ៍, សយ ប្រធានឈ្លប, ទូច ប្រធានឃ្លាំងសហករណ៍ អៃ ប្រធានឈ្លប និង ចយ ប្រធានឈ្លបភូមិ ។ យើងទាំងអស់គ្នាមាននាទីធ្វើសកម្មភាពបំផ្លាញបដិវត្តន៍នៅភូមិដ្ឋាន ។

ចុងឆ្នាំ១៩៧៦ ស៊ឹម និង សារ៉ែន បានហៅខ្ញុំ និងខ្មែរទៅចាត់តាំងដោយឲ្យយកស្រូវ១២បាវ ជាមួយនឹងជ្រូក មាន់ ទា មួយចំនួនទៅឲ្យយួនឈ្មោះ ថាញ់ ។

ឆ្នាំ១៩៧៧ ស៊ឹម បានចាត់តាំងខ្ញុំឲ្យធ្វើប្រធាន “ខ” កងស្រុកពញាក្រែក រួចហើយគាត់ឲ្យខ្ញុំមកការពារមុខសញ្ញានៅភូមិត្នោតតាមព្រំដែន ។ ពេលទៅត្រៀមនោះខ្មែរខ្ញុំមាន យ៉ុន និង សង្ហា ។

ដល់ចុងឆ្នាំ១៩៧៧ សារ៉ែន បានឲ្យខ្ញុំ និង សង្ហា បំផុសយុទ្ធជនឲ្យរត់ចោលសមរភូមិ ដើម្បីឲ្យយួនចូល និងដើម្បីរួមផែនការសហការវាយបក្សកុម្មុយនីស្តដែលជាផែនការធ្វើរដ្ឋប្រហារ ។ ការបំផុសនេះគឺលើកឡើងថា ខ្មាំងចេញពីទ័ពពីខាងក្រោយ ។ មួយរយៈក្រោយមក ខ្ញុំត្រូវរបួសមកដេកពេទ្យតំបន់២០ ។

សម្រាកព្យាបាលនៅមន្ទីរពេទ្យតំបន់២០ រយៈពេលពីរខែ ខ្ញុំបានទាក់ទងជាប់ខ្មែរជាមួយ អាំ ប្រធាន “ខ” កងទ័ពតំបន់២០ ។ ពីរខែក្រោយមក ខ្ញុំក៏បានចេញពីពេទ្យរួចបានទៅអង្គភាពវិញ សារ៉ែន បានឲ្យខ្ញុំមកនៅកន្លែងសេដ្ឋកិច្ចដោយសារខ្ញុំមានរបួសដៃខាងស្តាំ ។ សារ៉ែន បានឲ្យខ្ញុំមកទាក់ទងខ្មែរគាត់នៅកន្លែងសេដ្ឋកិច្ច ដែលមានគ្នាពីរនាក់គឺ ឆាំ ប្រធានសេដ្ឋកិច្ចយោធាស្រុកពញាក្រែក និង ផន អនុសេដ្ឋកិច្ច យោធាតំបន់២០ ។ ពេលខ្ញុំមកនៅក្នុងតំបន់សេដ្ឋកិច្ច សារ៉ែន បានឲ្យខ្ញុំធ្វើសកម្មភាព ដករបបយុទ្ធជនមិនឲ្យហូបគ្រប់គ្រាន់ ។ ចំណែកម្ហូបវិញ គឺគាត់បានបញ្ជាខ្ញុំឲ្យដាក់អំបិលឲ្យយុទ្ធជន បំផុសឲ្យយុទ្ធជនរត់ចោលខ្មែរត្រៀម ។

ខែមករា ឆ្នាំ១៩៧៨ ខ្ញុំបានទាក់ទងជាប់ខ្មែរជាមួយ ស៊ុន អនុយោធា តំបន់២០ក្នុងអង្គភាពយោធាស្រុក និងអង្គភាពយោធាតំបន់២០ សហការការពារនៅតាមព្រំដែន ។ តួនាទី ស៊ុន ជាប្រធាន “គ” ក្រុមចោរព្រៃអណ្តូងព្រីង ។ ក្រៅពីនេះ ខ្ញុំបានធ្វើសកម្មភាពតាមផែនការ សារ៉ែន របូត ។ ក្រោយមក ខ្ញុំក៏រត់មកនៅផ្ទះវិញ ។ ស៊ុន បានមកជួបខ្ញុំនៅផ្ទះ ហើយនិយាយថា សភាពការណ៍មិនស្រួលទេ

ព្រោះយុទ្ធជនក្តី និងអ្នកដែលមាននាទីដូចយើង ក៏គេមិនទុកដែរ គឺចាប់យកទៅសម្លាប់ចោលទាំងអស់ ។ ដូច្នេះ មិត្តឯងនៅផ្ទះត្រូវប្រយ័ត្នឲ្យមែនទែន ។ ក្រោយពីនិយាយគ្នាចប់ គាត់លាខ្ញុំទៅវិញ ។

ពាក់កណ្តាលឆ្នាំ១៩៧៨ ស៊ុន បានមកជួបខ្ញុំ ហើយគាត់នាំខ្ញុំដើរឃោសនា បំផុសប្រជាជន យុទ្ធជន យុទ្ធនារីឲ្យរត់ចូលព្រៃ ដើម្បីតស៊ូប្រឆាំងនឹងកងភូមិភាគកណ្តាល ហើយប្រាប់ប្រជាជនថា នៅតទៅទៀតមិនបានទេ មុខជាកងទ័ពរបស់ភូមិភាគកណ្តាលសម្លាប់ចោលមិនខាន យុទ្ធនារីប្រជាជន និងកុមារតូចៗ ក៏មិនទុកដែរ ដូច្នេះ មានតែផ្លូវមួយទេ គឺត្រូវរត់ទៅព្រៃដើម្បីរួមកម្លាំងគ្នាតស៊ូឡើងវិញ ។ ក្រោយពីដើរឃោសនា ស៊ុន បានប្រាប់ខ្ញុំថា «នេះយើងត្រូវរត់ចូលព្រៃហើយ ក្នុងនេះគឺយើងត្រូវបំផុសប្រជាជនឲ្យរត់ចូលព្រៃជាមួយដែរ ដើម្បីរួមកម្លាំងរៀបចំកងទ័ពប្រយុទ្ធជាមួយបដិវត្តន៍ ។ បន្ទាប់មក ស៊ុន ចូលព្រៃមុន ហើយបាននាំក្រុមចោរព្រៃប្រាំបីនាក់មានអាវុធ អ៊ែ១៥ និងអាការមួយដើមផង មកនាំប្រជាជនទៅព្រៃអណ្តូងព្រីង ។ ប៉ុន្តែក្រោយមក មានការលំបាកដោយប្រជាជន និងក្មេងតូចៗខ្វះជម្រក ហើយភ្លៀងទឹកឃុំរងើករងៀកខ្លាំងពេកក៏នាំគ្នានៅក្នុងភូមិចាស់មួយឈ្មោះ ភូមិត្រាវ ឃុំកក់ ស្រុកពញាក្រែក ។ តែប្រជាជនទាំងអស់នេះក្រោយមក ត្រូវកងទ័ពមកកៀរទៅវិញអស់ នៅសល់តែក្រុមខ្ញុំជាង៥០នាក់ ។ ឆ្នាំដដែល ពេលដែលទៅដល់ព្រៃបានប្រហែល១០ថ្ងៃ ស៊ុន និង ស៊ីម បានហៅខ្ញុំ និងក្រុមចោរព្រៃទៅចូលរួមប្រជុំនៅអណ្តូងព្រីង ទាំងអស់៣៨នាក់ ។ ក្នុងចំណោម ៣៨នាក់ ស៊ីម រៀបចំចាត់តាំងឡើងនៅក្នុងព្រៃមានឈ្មោះ ស៊ីម ជាប្រធានទទួលរួមក្រុមចោរព្រៃ, ស៊ុន ប្រធាន «គ» ក្រុមចោរព្រៃ, ស៊ាង ហេង អនុ «គ» ចោរព្រៃ, សឿន សមាជិកចោរព្រៃ, សាវី ប្រធានវប្បធម៌ឃុំដូនតី, អៃ អនុឃុំ, ខន ប្រធាន «ខ» ក្រុមចោរព្រៃ, សន សមាជិកយោធាស្រុកកំចាយមារ, ឌួង (ខ្ញុំ) ប្រធានក្រុមទី២, ស៊ិន អនុក្រុម, ឈូក អនុក្រុមទី១, សាវី ប្រធានក្រុមទី៣ យ៉ុន អនុក្រុមទី៣ ។ ពេលជួបជុំហើយ ស៊ីម និយាយថា យើងមកនៅព្រៃ យើងចូលស្រុកវិញលែងបានហើយ យើងចូលច្បាស់ជាកងទ័ពរបស់ភូមិភាគកណ្តាលសម្លាប់ចោលទាំងអស់ ដូច្នេះ មានតែយើងធ្វើការតស៊ូឡើងវិញ ហើយយើងត្រូវតែដាច់ខាតទើបយើងទទួលបានជ័យជម្នះ ហើយត្រូវដំណើរការតាមរបៀបសង្រ្គាមឈ្លប ។ ប៉ុន្តែនៅពេលនេះ យើងអាចទាក់ទងជាមួយយួនបាន ។

នារដូវប្រាំងយើងត្រូវតែប្រយុទ្ធដាច់ខាតឡើងដើម្បីរួមជាមួយយួនឲ្យបានខ្លាំងក្លា ព្រោះលើកនេះយួនមានផែនការវាយធំណាស់ តែយើងត្រូវមានផែនការវាយឈ្លបកងទ័ពរបស់អង្គការបណ្តើរដើម្បីយកអាវុធមកបំពាក់ឲ្យខ្លួនយើង ដែលមានអាវុធមិនទាន់គ្រប់ដៃនៅឡើយទេ ។ យើងនឹងរៀបចំកសាងកម្លាំងកងទ័ពយើងឡើងវិញនៅរដូវប្រាំងនេះ នៅពេលដែលយួនវាយចូលមកកម្ពុជា ។ យើងទ្រាំតទៅទៀតឲ្យបាន ទោះការហូបចុក និងអាស្រ័យរបស់យើងមានការខ្វះខាតយ៉ាងណាក៏ដោយ គឺយើងអាចហូបបបរលាយដំឡូងបាន ។ យើងទៅពឹងអ្នកខាងក្នុង ក៏ខ្មែរយើងមិនទទួលដែរ ព្រោះយើងជាមនុស្សប្លែកពីគេ មិនហ៊ានទទួលយើងទេ ដូច្នេះយើងត្រូវនៅក្នុងព្រៃ ។ ការខ្វះខាត គឺយើងនៅមានតិចនៅឡើយ រីឯអាវុធវិញ យើងមានអាវុធអាកា៤ ដើម និង អ៊ែ១៥-៦ដើម និង បេ៤០មួយដើមគ្រាប់ និងអាវុធខ្លី ៤៥៤ដើម ។ បញ្ហានេះខ្ញុំចង់និយាយថា យើងត្រូវទៅកម្ទេចកម្លាំងរបស់ខ្មាំងតូចៗ ដើម្បីរឹបយកអាវុធមកបំពាក់ឲ្យខ្លួនយើងដើម្បីធ្វើការតស៊ូបន្តទៀត ។ ចំពោះខ្មែរយើងនៅក្នុងរដ្ឋអំណាចគឺយើងមាន តាវី, តាអៃ ជាអ្នកទាក់ទងរៀបកម្លាំងឡើងវិញ ដែលមានកងឈ្លបឃុំ និងតាមមុខព្រួញនៅក្នុងសហករណ៍ និងក្នុងឃុំ ។ ខ្មែរយើងនៅក្នុងទាំងអស់នេះបានលាក់ស្រូវ កិនយកអង្ករ និងលាក់អំបិលជួយកងទ័ពយើងវាយបដិវត្តន៍នៅរដូវប្រាំង ។ ខែសីហា ឆ្នាំ ១៩៧៨ ក្រោយពី ស៊ីម ហៅទៅប្រជុំហើយ ក៏លើកផែនការសហការជាមួយយួន ។ ពេលនោះខ្ញុំសួរ ស៊ុនថា បង ស៊ីម ទៅទាក់ទងយួនបាន តើមែនឬអីបង? ក្រោយមក ស៊ុន ឆ្លើយប្រាប់ខ្ញុំថា ដំបូងនៅដើមខែសីហានេះ បងស៊ីម បានឲ្យនីរសារគាត់ដែលចេះនិយាយភាសាយួនមាន ឈាត, សាវ៉ាត, អ៊ូ និង ចន ទៅទាក់ទងយួននៅខាងកើតភូមិត្នោតចូលទៅដីក្រហមស្រុកយួនដើម្បីដឹងគ្នាហើយ ។ ស៊ីម បានស្នើឲ្យយួនជួយក្រុមខ្ញុំដែលមានសមាជិក១០០នាក់ និងប្រជាជនមួយពាន់នាក់ ដែលរត់ចូលព្រៃដោយឲ្យវាយបើកផ្លូវដើម្បីឲ្យប្រជាជនរត់ទៅស្រុកយួន ។ ក្រោយមក ស៊ីម បានទៅទាក់ទងយួនឈ្មោះ ធីង ប្រធានកងពល ហើយ ធីង បាននិយាយថា នឹងជួយដល់រដូវប្រាំងនេះ នឹងវាយកម្ពុជាម្តងទៀត ។ នៅក្នុងមុខសញ្ញាទី១ គឺបុកខាងស្វាយរៀងដោយប្រើ

កម្លាំងពីរកងពល មុខសញ្ញាទី២ គឺនៅច្រកភូមិត្នោត និងផ្សារក្រដាស ដោយប្រើកម្លាំងពីរកងពល និងមុខសញ្ញាទី៣ នៅច្រកមេមត់ ដោយប្រើកម្លាំងបួនកងពល ។ កម្លាំងយើងនៅខាងក្នុង គឺបញ្ជាទីមួយ ឲ្យយើងត្រៀមកម្លាំង យើងមានទាំងអស់ត្រៀមវាយកងឈ្លបរបស់អង្គការពីរខាងក្រោយ ដើម្បីធ្វើឲ្យច្របូកច្របល់ ។ ក្រៅពីនេះ ខាងយួនបានឲ្យកម្លាំងប្រជាជនដែលនៅក្នុងព្រៃទាំងអស់ត្រៀមប្រមូលផលស្រូវឲ្យបានច្រើន និងរកកន្លែងដាក់ឲ្យបានស្រួលបួលសម្រាប់ផ្គត់ផ្គង់កងទ័ពយួនពេលវាយចូលក្នុងដីកម្ពុជា ។

លើកទីបី ស៊ីម បានទាក់ទងភាគីខាងយួនម្តងទៀត ។ ឯនៅខាងអង្គការវិញ អង្គការដាក់មីន និងចម្រូងជាច្រើនការពារ ។ ឈាត និង សារ៉ាត ដែលជានីរសារបានជាន់មីនស្លាប់ យើងក៏ដាច់ការទាក់ទងអស់ ។ ក្រោយមក ស៊ីម និង ស៊ុន បានរៀបចំចាត់តាំងកម្លាំងជាបីមុខសញ្ញា គឺមុខសញ្ញាទី១ មានគ្នា១០នាក់ មានអាវុធ ៣ដើម, អាកា ១ដើម, អែ១៥ និងគ្រាប់បែកពីរគ្រាប់ ។

នៅមុខសញ្ញាទី១មាន អ៊ី និង ឈូក ដោយ ស៊ីម ណែនាំឲ្យត្រៀមវាយឈ្លប នៅពេលដែលដើរដាច់ពីចំណោមគ្នាច្រើន ដើម្បីដណ្តើមយកអាវុធ ។ មុខញ្ញាទី២ គឺមានខ្ញុំ និង ស៊ុន ជាមួយនឹងយុទ្ធជន៨នាក់ទៀត ត្រៀមវាយឈ្លបរបស់អង្គការនៅភូមិធ្លក ក្នុងឃុំកក់ ស្រុកពញាក្រែក ។ មុខសញ្ញាទី៣ គឺមាន សារី និង ម៉ុន ជាមួយនឹងយុទ្ធជន៨នាក់ទៀត នៅភូមិសន្ទែ ស្ថិតក្នុងឃុំកក់ ។ បន្ទាប់មក ខ្ញុំបានដឹកនាំកម្លាំងត្រៀមចាំវាយឈ្លបដែលនៅឆ្ងាយពីភូមិធ្លក ឈៀងខាងត្បូង ប្រហែល ៥០០ម៉ែត្រ និងបានចាត់តាំងកម្លាំងឲ្យទៅតាមដានកងទ័ពរបស់អង្គការនៅក្នុងភូមិរាល់ថ្ងៃ ។

ដល់ក្រោយមកបានប្រហែល១០ថ្ងៃខ្ញុំបានចាត់តាំងឈ្មោះ អយ និង សារិន ទៅឃ្លាំចាំមើលកងទ័ពដើម្បីវាយឆ្មក់ ។ ក្រុមខ្ញុំទាំងពីរនាក់នេះទៅ គឺបានទៅលួចកាប់ដូងស៊ី មិនដឹងខ្លួនស្រាប់កងទ័ពរបស់អង្គការបាញ់របួសទាំងពីរនាក់ ហើយយើងបាញ់តប និងបានរត់រួចមកវិញ ។ ក្រោយមក ខ្ញុំបានដកក្រុមខ្ញុំមកត្រៀមនៅខាងកើតភូមិ



អ្នកទោសនៅមន្ទីរសន្តិសុខ ស-២១

ធ្លកប្រហែល៦០០ម៉ែត្រ ។ មកដល់ទីនេះបានមួយរយៈ កងទ័ពអង្គការតាមបាញ់ក្រុមខ្ញុំទៀត ពេលនោះក្រុមរបស់ខ្ញុំក៏រត់មកនៅខាងកើតព្រៃកមួយចម្ងាយពីភូមិធ្លកប្រហែល៥០០ម៉ែត្រ ។ ជាមួយនេះ ខ្ញុំបានមកជួប ស៊ិន និងឃើញមាននារី១២នាក់ និងនីសារ៤នាក់ទៀត រួចក៏បានសួរអំពីសភាពការណ៍នៅភូមិធ្លក ។ ក្រោយមកខ្ញុំរាយការណ៍ជូនថា ចំពោះសភាពការណ៍នៅភូមិធ្លក គឺមានកងទ័ពរបស់អង្គការមកបាញ់ក្រុមរបស់ខ្ញុំពីរដងហើយ និងធ្វើឲ្យរបួសក្រុមរបស់ខ្ញុំពីរនាក់ទៀត ។ ខ្ញុំប្រាប់គាត់ថា អ្នករបួសពីរនាក់នោះ អត់បាយ៦ថ្ងៃហើយ ។ ស៊ិន បានឲ្យខ្ញុំ និង ស៊ិន យកបាយរបស់គាត់ ដោយលាយជាមួយដំឡូងមួយកូនឆ្នាំងដើម្បីយកទៅឲ្យមិត្តដែលរបួសនៅក្នុងព្រៃនោះហូប ។ ពេលនិយាយចប់ហើយ ខ្ញុំ និង ស៊ិន បានយកបាយឲ្យមិត្ត អយ ដែលរបួសដើរមិនរួចហូប ។ បន្ទាប់មក អយ សួរខ្ញុំថា បងមានពេទ្យមកទេ? ខ្ញុំប្រាប់ថា អត់មានពេទ្យទេ ខ្ញុំមកនេះគឺគ្រាន់តែយកបាយមកឲ្យ ព្រោះសភាពការណ៍មានការលំបាកខ្លាំង តែចាំមើលខ្ញុំរកកន្លែងនៅបានស្រួលចាំខ្ញុំយកមិត្តទៅជាមួយ ។ ត្រឡប់មកវិញ ស៊ិន បានប្រាប់ថា ម៉េចទៅអ្នករបួស? ខ្ញុំឆ្លើយថា មិត្ត អយ មុខឡើងស្លេកស្លាំងអស់ ហើយរបួសគាត់ឡើងស្អុយ ។ លុះព្រឹកឡើង កងទ័ពអង្គការបានទៅបាញ់ក្រុមរបស់ខ្ញុំស្លាប់អស់ពីរនាក់ ដោយមាននារីម្នាក់រងរបួស ។ បន្ទាប់មក ខ្ញុំក៏បាននាំគ្នារត់ដោយមានគ្នាបីនាក់គឺ សន, ស៊ិន និង ខន ហើយខ្ញុំមកនៅក្នុងព្រៃបាក់ រួចរត់ចូលទៅព្រៃអណ្តូងព្រីងដោយបានជួប ស៊ិន, អ៊ី, សារិ, និង ក្រុម៤០នាក់ទៀត ។ ជាមួយនេះ ស៊ិន បានសួរខ្ញុំថា «មិត្ត ឌួង ទៅតាមណាក៏បាត់យូរម៉្លេះ ម៉េចក៏មិនរត់មកតាមខ្ញុំ?» ។ ខ្ញុំប្រាប់វិញថា រត់ទៅយ៉ាងម៉េចបើគ្រាប់បាញ់ដូចគេបាចអង្ករ ហើយ នៅចំពីមុខខ្ញុំ មានកាំភ្លើងម៉ាស៊ីន មួយដង ។ ចំពោះខាងគាត់ កងទ័ពអង្គការយកបានកាំភ្លើងពីរដើមហើយ គឺអាកាមួយដើម និងកាំភ្លើងបេ៤០ មួយដើម និងគ្រាប់ផង ។ ក្រោយពីក្រុមខ្ញុំបានសម្រាកនៅក្នុងព្រៃអណ្តូងព្រីងនេះ ស៊ឹម បានមកជួបជាមួយក្រុមរបស់ខ្ញុំ ដោយមាននីសារបួននាក់មកជាមួយផង ។ ស៊ឹម និយាយប្រាប់ថា អង្ករទាំងអស់នៅតែ៣០បាវទេ ។ យើងមិនអាចដោះស្រាយបានដូច្នេះ យើងត្រូវដើររកជីកដំឡូងទុកលាយហើយ ។ ម្យ៉ាងទៀត ទាល់តែយើងចាត់តាំងកម្លាំងឲ្យទៅទាក់ទងខ្មែរយើងនៅខាងរដ្ឋអំណាចទើបអាចដោះស្រាយបាន ។

បន្ទាប់មក ស៊ិន បានហៅខ្ញុំ, ស៊ិន និង ខន មកប្រជុំណែនាំថា «មិត្តឯងត្រូវទទួលភារកិច្ចទៅទាក់ទងជាមួយខ្មែរយើង នៅខាងរដ្ឋអំណាចឡើងវិញ ហើយឲ្យកម្លាំងស្នូលរបស់យើងរៀបចំកសាងកម្លាំងថែមទៀត ដើម្បីបង្កប់នៅក្នុងមូលដ្ឋាន ហើយ ត្រៀមជាអង្ករនៅតាមខ្សែនីមួយៗ និងអំបិលដើម្បីឲ្យកងទ័ពរបស់យើងនៅពេលវាយ ។ បន្ទាប់ពីណែនាំហើយ ខ្ញុំទាំងបីនាក់បានទៅទាក់ទងខ្សែរបស់ខ្ញុំគឺ



អគារឃុំឃាំងអ្នកទោសនៅមន្ទីរសន្តិសុខ ស-២១

ផន ជាប្រធានមុខព្រួញ នៅភូមិព្រៃអង្គរ ។ ពេលទៅជួប ផន និយាយថា មិត្តឯងនៅឯណា ខានជួបគ្នាយូរ ហើយនៅកងទ័ពណា? ក្រោយមក ខ្ញុំឆ្លើយប្រាប់គាត់វិញថា ខ្ញុំនៅក្នុងព្រៃ ។ ខ្ញុំក៏សួរ ផន ថា បើអ៊ីចឹង បងអាចទទួលភារកិច្ចមួយចំនួនសម្រាប់អនុវត្តនៅក្នុងភូមិបានទេ? ។ គាត់និយាយថា បើការងារនោះគាត់ធ្វើបានគឺគាត់នឹងខំធ្វើតទៅទៀត ។ ខ្ញុំប្រាប់ទៀតថា បើអ៊ីចឹងខ្ញុំសុំស្នើឲ្យបងពង្រីងខ្មែរយើងឡើងវិញ និងកសាងកម្លាំងរបស់យើងថែមទៀត ប៉ុន្តែត្រូវលាក់

ការត្រូវពិនិត្យឲ្យបានហ្មត់ចត់ ។ ក្រៅពីនេះ ខ្ញុំស្នើឲ្យបងជួយអង្ករ និងអំបិលមួយចំនួនផង ដើម្បីយកទៅឲ្យកងទ័ពយើងនៅក្នុងព្រៃ ។ ក្រោយមក ផន ក៏បានសួរខ្ញុំថា កងទ័ពយើងនៅឯណា ច្រើនឬតិច? ខ្ញុំកុហកគាត់ដើម្បីឲ្យគាត់មានជំនឿលើខ្មែររបស់ខ្ញុំថា កងទ័ពយើងនៅឆ្ងាយពីនេះ ហើយកងទ័ពយើងច្រើនណាស់ គឺរាប់កងពលនៅពេញតែព្រៃ តែឥឡូវមានការខ្វះខាតដាច់បាយមួយពេល ពីរពេលហើយ នៅក្នុងព្រៃពិបាកណាស់ ។ បើបងអាចលួចស្រូវ ហើយយក




ទៅធ្វើជាអង្ករក៏យើងអាចមានលទ្ធភាពដែរ ព្រោះបងនៅខាងក្នុងរដ្ឋអំណាច ។

ផន ប្រាប់ថា សភាពការណ៍ឥឡូវតឹងរ៉ឹងជាងមុន ព្រោះឃុំគេបើកមកត្រឹមតែប្រជាជនហូបមួយពេលៗ រាល់ពេលមិនឃើញនៅសល់ទេ តែចាំមើលខ្ញុំទៅទាក់ទងខ្មែរយើងនៅក្នុងភូមិមើលក្រែងជួយដោះស្រាយបានខ្លះ ។ ខ្ញុំសួរគាត់ថា បងផាន នៅឯណា? គាត់ប្រាប់ថា បងផាន ឥឡូវទទួលជាសមាជិកទី៤ឃុំដូនតី តាំងពីក្រោយផ្ទុះអាវុធមក និងជាខ្មែរយើងដែរ ហើយបើចង់ទាក់ទងក៏បាន មិនអីទេ ។ ក្រោយពីនិយាយចប់ហើយ ខ្ញុំបាននាំក្រុមរបស់ខ្ញុំទាំងបីនាក់ទៅលាក់ខ្លួននៅខាងត្បូងភូមិព្រៃអង្គរក្នុងចម្ងាយមួយគីឡូម៉ែត្រ ។ ដល់ថ្ងៃស្អែក ខ្ញុំ ទាំងអស់គ្នាបានទៅជួប ផន នៅកន្លែងដដែល ។ ពេលទៅជួបហើយគាត់បានឲ្យបាយមកក្រុមរបស់ខ្ញុំ និយាយប្រាប់ខ្ញុំថា សភាពការណ៍ប្រជាជនមានការតឹងរ៉ឹង ។ បន្ទាប់មកខ្ញុំ បានឆ្លងមកភូមិពរោង ឃុំដូនតីខាងលិច ខ្ញុំបានមកជួបជាមួយ អាំ នៅពេលដែលគាត់កំពុងតែបោកត្រី នៅកន្លែងពើកខាងកើតភូមិពរោង ។ ខ្ញុំបានទាក់ទង សយ ដើម្បីស្នើឲ្យបងជួយរកអង្ករ និងអំបិលមួយចំនួនដើម្បីយកទៅឧបត្ថម្ភកងទ័ពយើងដែលនៅក្នុងព្រៃ ហើយកំពុងតែមានការខ្វះខាតយ៉ាងខ្លាំងដូច្នេះហើយ ស្នើបងជួយដោះស្រាយផង ។ ចំពោះអង្ករ និងអំបិល សយ បានប្រាប់ថា នេះមានការលំបាកដែរ ព្រោះពីឃុំមក គេសុទ្ធតែបើកកំណត់ប្រជាជនត្រឹមត្រូវតែម្តងចាំពីរបីថ្ងៃទៀតមើលក្រែងខ្ញុំកិបកេងពីប្រជាជនបានខ្លះយកមកឲ្យមិត្ត ឌួង ឯង ។

មុនពេលបែកគ្នា ខ្ញុំប្រាប់ទៅ សយ ថា “បងសយ នៅពេលដែលបងទៅវិញ ខ្ញុំស្នើឲ្យទៅប្រាប់ បងផាន ផងថា ឲ្យគាត់មកជួបខ្ញុំនៅកន្លែងដើមពោធិ៍ខាងវត្តព្រៃអង្គរក្រៅ ។ ក្រោយមក សន បានរាយការណ៍ប្រាប់ទៅខ្ញុំ នៅពេលនេះក្រុមរបស់យើងត្រូវបានអង្គការចាប់អស់មួយចំនួនហើយ ។ មួយរយៈក្រោយ ផាន បានមកជួបខ្ញុំ ហើយនិយាយថា “ចាំមើលខ្ញុំទៅទាក់ទងខ្មែរយើងនៅក្នុងមូលដ្ឋានមើលក្រែងបានយកខ្លះមកឲ្យ ឌួង ហើយចាំបួនដប់ថ្ងៃទៀត បើបានខ្ញុំយកមកឲ្យមិត្ត ឌួង ឯង នៅកន្លែងនេះ” ។ ដល់ពេលព្រឹកឡើង ខន និយាយប្រាប់ខ្ញុំថា ឌួង ឯងទៅរាយការណ៍ឲ្យបងស៊ិម ទៅថា យើងបានទាក់ទងកម្លាំងដែលជាកម្លាំងស្នូលនៅខាងក្នុងបានអង្ករខ្លះហើយ នៅតែកំណត់ថ្ងៃទៅយក ឯចំពោះខ្ញុំ និង សន ទៅធ្វើការនៅភូមិពានជ្រៃ ភូមិសុវណ្ណគុម និងភូមិបុសខ្នុរហើយ ហើយមិត្ត ឌួង ឯងទៅតែបីថ្ងៃបានហើយ” ។ ក្រោយពីនិយាយគ្នាហើយ ខ្ញុំក៏ដើរកាត់តាមផ្លូវ ចាក់សំដៅទៅតាមព្រៃបាក់អាយ តែពេលនោះខ្ញុំទើបតែទៅដល់ចុងភូមិសុវណ្ណគុមខាងត្បូង អង្គការក៏បានចាប់ខ្ញុំបាន គឺចាប់នៅថ្ងៃទី១ ខែវិច្ឆិកា ឆ្នាំ១៩៧៨ ។

**ស៊ិន សុធីតា**

# អំពើប្រល័យពូជសាសន៍ប្រឆាំងនឹងជនជាតិចាម

***សេចក្ដីផ្ដើម***

ឃុំស្វាយឃ្លាំង គឺជាឃុំមួយក្នុងចំណោមតំបន់គស្ស៊ូរើបម្រះរបស់ជនជាតិចាមប្រឆាំងរបបខ្មែរក្រហម (១៩៧៥-១៩៧៩) ។ ដោយឡែកថ្ងៃនេះ ឃុំស្វាយឃ្លាំងត្រូវបានជ្រើសរើសជាកន្លែងដើម្បីប្រារព្ធកម្មវិធីវេទិកាសាធារណៈតាមភូមិ ដើម្បីចែករំលែកដល់សាធារណជននូវរឿងរ៉ាវថ្មីៗ និងការពិភាក្សាទាក់ទងទៅនឹងដំណើរការកាត់ក្ដីមេដឹកនាំជាន់ខ្ពស់ខ្មែរក្រហម នៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។ ជាក់ស្ដែង អ្នកភូមិប្រមាណជា ១០០នាក់ ជាពិសេសជាជនជាតិខ្មែរអ៊ីស្លាម ឬជនជាតិចាម បានចូលរួមស្ដាប់ការអត្ថាធិប្បាយ ដោយជំនួយការជាន់ខ្ពស់របស់ព្រះរាជអាជ្ញា ដាល លីសាក់ នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។ ការសម្រេចយកតំបន់នេះ ដោយសារតែមានការជាប់ពាក់ព័ន្ធនឹងប្រវត្តិសាស្ត្រ ក៏ដូចជាមានការចាំបាច់ខាងផ្លូវច្បាប់ ។ ដំបូង តំបន់នេះជាប់ពាក់ព័ន្ធនឹងចលនាគស្ស៊ូរើបម្រះរបស់ជនជាតិចាមក្នុងឆ្នាំ១៩៧៥ ដែលឈានទៅដល់ការកាប់សម្លាប់ជនជាតិចាមរាប់រយនាក់ ព្រមទាំងហាមឃាត់ ការមិនឲ្យគោរព



គីម និង ហាទួន ជនជាតិចាម

ប្រណិបត្តិសាសនាថែមទៀតផង ។ ទីពីរ នៅតំបន់នេះ មានការចោទប្រកាន់លើអំពើប្រល័យពូជសាសន៍ប្រឆាំងនឹងមេដឹកនាំជាន់ខ្ពស់ខ្មែរក្រហម អតីតប្រមុខរដ្ឋ ខៀវ សំផន និងជនមនោគមនវិជ្ជា នួន ជា ។ ខណៈពេលដែល កង់យុត្តិធម៌ទើបតែត្រូវបានគេបង្វិល ឆ្លើយតបទៅនឹងការចោទប្រកាន់អំពើប្រល័យពូជសាសន៍ វេទិកាសាធារណៈរៀបចំឡើងជាពិសេស ដើម្បីជួយសម្រួលដល់តុលាការក្នុងការរំពុកដល់សាធារណជនទូទៅ អំពីវឌ្ឍនាការកាត់ក្ដីចំពោះមេដឹកនាំជាន់ខ្ពស់ និងជួលជំរុញដល់ជនជាតិចាមបញ្ចេញនូវទស្សនៈផ្ទាល់ខ្លួន ស្ដីអំពីធម្មជាតិនៃអំពើប្រល័យពូជសាសន៍ប្រឆាំងនឹងជនជាតិភាគតិច ជនជាតិចាម ។ ក្នុងកម្មវិធី មានការលើកឡើងអំពីប្រវត្តិសង្ខេបនៃការតស៊ូរើបម្រះនៅតំបន់នេះផ្ទាល់ និងការជះឥទ្ធិពលជាបន្តបន្ទាប់ ។ ក្រោយមក នឹងមានការធ្វើអត្ថាធិប្បាយដោយលោក លីសាក់ និងមតិឆ្លើយតបរបស់ប្រជាជនដែលឆ្លុះបញ្ចាំងពីប្រតិកម្មរបស់អ្នកទាំងនោះ ចំពោះអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា និងចំពោះវេទិកាតាមភូមិរបស់មជ្ឈមណ្ឌលឯកសារកម្ពុជាដោយផ្ទាល់តែម្ដង ។

## ចលនាតស៊ូរើបម្រះរបស់ជនជាតិចាម និងលទ្ធផលជាក់ស្ដែង

ឃុំស្វាយឃ្លាំង ត្រូវបានគេចងចាំច្រើនអំពីប្រវត្តិស្ដីពីកម្លាំងតស៊ូប្រឈមនឹងអំណាចផ្ដាច់ការរបស់ខ្មែរក្រហម ដែលហាមមិនឲ្យគោរពប្រណិបត្តិសាសនា ។ ប្រឆាំងនឹងការដាក់បម្រាមនេះ នៅក្នុងឆ្នាំ១៩៧៥ ជនជាតិចាមស្នើសុំឲ្យបើកវិហារអ៊ីស្លាមក្នុងភូមិសម្រាប់ថ្ងៃបុណ្យរ៉ាម៉ាដន ។ នាពេលនោះ មេភូមិរបស់ខ្មែរក្រហមយល់ព្រម ប៉ុន្តែត្រូវតែចុះឈ្មោះអ្នកដែលចូលរួមជាសហធម្មចារី ។ ប្រហែលជាជនជាតិចាម១០០នាក់ បានកត់ឈ្មោះ តែបែជន្យមានព័ត៌មានតពីមាត់មួយទៅមាត់មួយថាមានការចាប់ខ្លួនអ្នកទាំងនោះ ដែលនាំឲ្យអ្នកដទៃទៀត មានការភិតភ័យ ។ ជាកិច្ចឆ្លើយតប អ្នកភូមិងើបឡើងតស៊ូប្រឆាំងនឹងការចូលឈ្លានពានរបស់សមាជិក ខ្មែរក្រហមដែលបានបញ្ជូនមកក្នុងឃុំ ។ លើសពីនេះ ចិត ដែលជាមេឃុំរងក្នុងរបបខ្មែរក្រហម ត្រូវបានអ្នកភូមិសម្លាប់ ។ រឿងហេតុបែបនេះនាំឲ្យមានការមិនពេញចិត្តដល់ខ្មែរក្រហមថ្នាក់លើ ។ ដូច្នេះ កងពលនាយទាហានប្រចាំតំបន់ ស្រុក និងឃុំ ត្រូវបានដាក់ពង្រាយជាប្រញាប់ និងមានការផ្ទុះអាវុធចេញពីទន្លេមួយទៅកាន់ឃុំស្វាយឃ្លាំង ខណៈពេលនោះដែរ កងពលមកពីតំបន់ផ្សេងៗ ក៏មកកាន់ទីនេះដែរ ។ ការផ្ទុះអាវុធ ចាប់



ដាវរបស់ជនជាតិចាម

ជនជាតិចាមភាគច្រើនមានសភាពព្រឺព្រួចក្នុងការសំណេះសំណាលអំពីព្រឹត្តិការណ៍នៃចលនាតស៊ូរើបម្រះ ចំពោះកម្លាំងខ្មែរក្រហមនាពេលនោះដែលបានបញ្ជូនមកបណ្ដេញប្រជាជនយ៉ាងប្រញាប់ប្រញាល់ក្នុងសភាពកោងកាច ។ ការតស៊ូប្រឆាំងចាប់ផ្ដើមនៅពេលដែលមានការស្នើសុំទាក់ទងនឹងសកម្មភាពសាសនា ។ លោក លី គុមាន អាយុ៦២ឆ្នាំ លោកស្រី សេ សាអ៊ីអាយុ៥៦ឆ្នាំ និងលោក ម៉ាន ស្មេះ អាយុ៦០ឆ្នាំ បាននិយាយថា ផ្ដើមតាំងពីព្រលឹម រហូតដល់ពេលពាក់កណ្ដាលរសៀល ។ បន្ទាប់មក កម្លាំងកងទ័ពចូលមកក្នុងភូមិ ហើយបណ្ដេញអ្នកភូមិទាំងអស់ឲ្យចេញពីភូមិ ។ ពេលនោះ ប្រជាជនត្រូវបែកបាក់គ្នា បុរសត្រូវបែកចែងដោយឡែកពីស្ត្រី និងកុមារ ។

លោក ម៉ាន ស្មេះ បន្តថា ក្រោយការប្រឆាំងហើយ ទិដ្ឋភាពរឹតតែមានសភាពអាក្រក់ឡើងៗ អ្នកដែលមានជីវិត រួចពីគ្រាប់កាំភ្លើង ត្រូវបានកៀងគរ ហើយដាក់ឃុំឃាំងឲ្យនៅក្នុងឡថ្នាំជក់ ។

ការចាប់ផ្តើមធ្វើបន្សុទ្ធកម្មមានជារៀងរាល់យប់ នាំឲ្យអ្នកដែលទទួលការអប់រំបានច្រើនស្លាប់ជាបណ្តើរៗ ។ មួយសប្តាហ៍ក្រោយមក អ្នកទាំងនោះត្រូវជម្លៀសទៅកាន់ស្រុកស្ទឹងត្រង់ និងស្រុកឆ្លូង ខេត្តក្រចេះ ហើយស្នាក់នៅទីនោះជាមួយអ្នកមូលដ្ឋាន ដើម្បីមានភាពងាយស្រួលដល់អ្នកមូលដ្ឋាន ក្នុងការតាមដានរាល់សកម្មភាពរបស់ជនជាតិចាម ។ បុរស និងស្ត្រីត្រូវដាក់ឲ្យនៅដោយឡែកពីគ្នា មានការដាក់ទារុណកម្ម និងការសម្លាប់ជាបន្តបន្ទាប់ ដោយសារការធ្វើបន្សុទ្ធកម្ម ។ ការសម្លាប់កើតឡើងនៅក្នុងភូមិរកាខ្នុរ ។ អ្នកមូលដ្ឋានប្រកាន់គំនិតរួចទៅហើយថា ជនជាតិចាមជាសត្រូវរបស់ខ្លួន ។ លោកស្រី ហាក់ សារី អាយុ៥៧ឆ្នាំ លើកឡើងថា គាឡុងដែលត្រូវជាមេឃុំនោះបញ្ជាឲ្យទាហានតាមចាប់សមាជិកគ្រួសារគាត់ និងជនជាតិចាមផ្សេងទៀត ។ ជាលទ្ធផលចុងក្រោយ ជនជាតិចាមភាគច្រើនត្រូវបានសម្លាប់ ចំណែកឯវប្បធម៌ និងសាសនាវិញត្រូវបានបំបិទទាំងស្រុង ។

## ការបំផ្លិចបំផ្លាញវប្បធម៌សាសនារបស់ជនជាតិចាម

ការបំផ្លិចបំផ្លាញវប្បធម៌ និងសាសនា របស់ជនជាតិចាម គឺបានចង្អុលបង្ហាញយ៉ាងច្បាស់ពីគោលបំណងជាក់ស្តែងរបស់ខ្មែរក្រហមក្នុងការលុបបំបាត់នូវអត្តសញ្ញាណរបស់ជនជាតិចាម ។ នេះ ជាករណីមួយ ដែលបណ្តាលឲ្យជនជាតិចាមងើបឡើងប្រឆាំងភ្លាមៗ ទៅនឹងខ្មែរក្រហម ។ ជាលទ្ធផល លោក ម៉ាន ស្មេះ ប្រាប់មកកាន់យើងថា វិហារកាតូលិកនៅក្នុងឃុំត្រូវបានបំផ្លាញចោល ។ ការបំផ្លាញនេះ ធ្វើឡើងក្នុងគោលបំណងកម្ចាត់រាល់អាគាររូបិយ



គ្រួសារជនជាតិចាម

នានាដែលអាចឲ្យជនជាតិចាមធ្វើការគោរពប្រណិបត្តិបាន ។ ពាក្យមួយទៀតនិយាយថា រាល់ការលើកស្ទួយសាសនា វប្បធ៌ម ប្រពៃណីទាំងអស់ត្រូវបានហាមប្រាម ។ លោក តុមាន លោកស្រី សាអ៊ី និង លោកស្រី ហាក់សារី អាយុ៥៧ឆ្នាំនោះ មានប្រសាសន៍ថា រាល់សំលៀកបំពាក់ប្រពៃណីចាមទាំងអស់ត្រូវបានហាមមិនឲ្យស្លៀក ។ ចំណែកឯគម្ពីរសាសនាត្រូវបានរឹបអូសទាំងអស់ ។ លើសពីនេះទៀត មនុស្សស្រីត្រូវតម្រូវឲ្យកាត់សក់ខ្លី ។ លោក តុមាន ចងចាំពាក្យស្លោកមួយរបស់ខ្មែរក្រហមថា «សក់វែងគឺជាគ្រឿងស្រើបស្រាលសម្រាប់ដៃគូ ចំណែកឯសក់ខ្លីគឺជាគ្រឿងសម្រាប់បូជាជូនដល់ប្រទេសជាតិ» ។ រាល់ការទំនាក់ទំនងផ្សេងៗ ភាសាចាមត្រូវបានហាមឃាត់យ៉ាងដាច់ខាត ។ លើសពីនេះទៀត មានករណីជាច្រើន ដែលត្រូវបានកត់ត្រាទុកថា ជនជាតិចាមត្រូវបានបង្ខំឲ្យញ៉ាំសាច់ជ្រូកដែលជារបស់ត្រូវបានហាមឃាត់សម្រាប់សាសនាអ៊ីស្លាម ។

តែយ៉ាងណាក៏ដោយ លោក ម៉ាន ស្មេះ មិនដឹងថាហេតុអ្វីបានជាខ្មែរក្រហមមិនកម្ទេចសើន (វិហារ) ក្នុងឃុំដែលជាកន្លែងសម្រាប់អ្នកកាន់សាសនាអ៊ីស្លាម

ប្រមូលផ្តុំគ្នាដើម្បីធ្វើពិធីបុណ្យជារៀងរាល់ថ្ងៃ ដែលនៅជិតវិហារអ៊ីស្លាម ។ នៅខណៈពេលនេះដែល ការរៀបរាប់ពីប្រវត្តិផ្ទាល់របស់ជនជាតិចាមនៅទីនេះ និងអត្តសញ្ញាណនានាដែលគម្រោងបានលើកឡើង បានដំណើរប្រកបដោយផ្លែផ្កា ក្រោមកិច្ចខិតខំប្រឹងប្រែងសម្រាប់ការយល់ឃើញថ្មីៗ និងការបក្ការផ្សេងៗ ។

## ការចោទប្រកាន់លើអំពើប្រល័យពូជសាសន៍

បន្ទាប់ពីបានចូលរួមការតាមដាន យល់ដឹងពីគោលការណ៍ជាក់ស្តែង និងការប្រយុទ្ធតទល់ ប្រឆាំងនឹងខ្មែរក្រហមដូចដែលបានរៀបរាប់ខាងលើ លោក ដាល លីសាក់ ដែលជាជំនួយការជាន់ខ្ពស់ ព្រះរាជអាជ្ញានៃការិយាល័យសហព្រះរាជអាជ្ញា បានឈានដល់ប្រធានបទសំខាន់ ។ គាត់ចាប់ផ្តើមធ្វើការអត្ថាធិប្បាយ ដោយផ្តោតសំខាន់លើករណីពិសេស ក្នុងស្រុកក្រូចឆ្មារ ខេត្តកំពង់ចាម ។ លីសាក់ និយាយថា នៅពេលដែលគាត់ឮពីជនជាតិចាមនៅក្នុងភូមិនេះ ក្នុងឆ្នាំ២០០៨ គាត់នៅក្នុងស្រុកកងមាស ។ ក្រោយមកគាត់ចាប់អារម្មណ៍តាមដានឲ្យកាន់តែស៊ីជម្រៅអំពីអ្វីដែលបានកើតឡើង ចំពោះជនជាតិចាមក្នុងអំឡុងរបបខ្មែរក្រហម ។ វាជារឿងដែលអាចទៅរួច សម្រាប់ខ្ញុំថា អំពើប្រល័យពូជសាសន៍ក៏អាចកើតមានឡើងចំពោះជនជាតិចាម ។

លោក ដាល បន្តថា ការស៊ើបអង្កេតរបស់គាត់បញ្ជាក់យ៉ាងច្បាស់ពិតជាមានចលនាប្រយុទ្ធប្រឆាំង នៅក្នុងភូមិនេះមែន ក្នុងឆ្នាំ១៩៧៥ ។ ដូច្នេះ ក្រោយមក នួន ជា និងខៀវ សំផន ត្រូវបានចោទប្រកាន់ពីបទអំពើប្រល័យពូជសាសន៍លើជនជាតិចាម និងខ្មែរក្នុងស្រុកនេះ ជាពិសេសក្នុងឆ្នាំ១៩៧៨ ។ ប្រជាជនជាច្រើនត្រូវបានកៀងគរ និងសម្លាប់តាមបណ្តោយដងទន្លេមេគង្គ ។ បទឧក្រិដ្ឋនានាផ្សេងៗទៀតត្រូវបានដាក់បញ្ចូនទៅក្នុងការកាត់ទោសនាពេលក្រោយៗទៀត ។ ប្រជាជននៅទីនោះសង្ឃឹមថាវានឹងចាប់ផ្តើមនាពេលឆាប់ៗក្នុងឆ្នាំនេះ ។ ទោះបីជាយ៉ាងណាក៏ដោយ ដាល បន្ថែមថា តុលាការនឹងសម្រេចច្បាស់ថា បទឧក្រិដ្ឋណានឹងត្រូវដាក់



ស៊ើន នៅឃុំស្វាយឃ្លាំង ស្រុកក្រូចឆ្មារ ខេត្តកំពង់ចាម

បញ្ចូលក្នុងការកាត់ក្តីបន្ទាប់នេះ ។ លោក លីសាក់ សង្កត់ធ្ងន់ថា ការិយាល័យសហព្រះរាជអាជ្ញា មានការរំពឹងទុកខ្ពស់ចំពោះការរាប់បញ្ចូលការសម្លាប់រង្គាលក្នុងស្រុកនេះក្នុងឆ្នាំ១៩៧៨ ។ តំបន់នេះត្រូវបានគេចាត់ទុកថាជា តំបន់វេទុក្ខខ្លាំង ប្រៀបធៀបទៅនឹងតំបន់វេទុក្ខដទៃទៀត ។ ការជួបប្រទះរបស់ជនជាតិចាម និងជនជាតិផ្សេងទៀត ដែលរស់នៅក្នុងស្រុកនេះ គួរតែត្រូវបានរាប់បញ្ចូលក្នុងការជំនុំជម្រះក្តីបន្ទាប់ ។

លោក លីសាក់ សង្កត់ធ្ងន់ថា ខណៈពេលដែលដំណើរការជំនុំជម្រះ ក្នុងសំណុំរឿង ០០២/០១ កំពុងបន្តការិយាល័យសហព្រះរាជអាជ្ញា ជំរុញឲ្យតុលាការជំនុំជម្រះក្តីលើកទី២ សម្រាប់ នួន ជា និង ខៀវ សំផន ។ ការចោទប្រកាន់លើកទី២នេះ នឹងរួមបញ្ចូលលើការសម្លាប់ នៅគុកទួលស្លែង អំពើប្រល័យពូជសាសន៍ប្រឆាំងនឹងជនជាតិចាម ជនជាតិវៀតណាម និងបទឧក្រិដ្ឋធ្ងន់ធ្ងរ ពីរទៅបីករណីទៀត ។ ការិយាល័យសហព្រះរាជអាជ្ញា ក៏បន្តការងារលើករណីសំណុំរឿង០០៣ និង០០៤ ។ លោក លីសាក់ មិនអាចលើកឡើងពីចំណុចលម្អិតៗបាននោះទេ ដោយសារតែវាកំពុងស្ថិតនៅក្នុងដំណាក់ការស៊ើបអង្កេត ។

ក្រោយពីសង្ខេបនៃការធ្វើអត្ថាធិប្បាយរបស់ លីសាក់ អ្នកចូលរួមជាច្រើនបានលើកជាសំណួរឡើង ។ ខណៈពេលដែលអ្នកមួយចំនួន លើកមីក្រូ សាកសួរទៅកាន់ លីសាក់ ជាសាធារណៈ អ្នកចូលរួមមួយចំនួនទៀត កត់ត្រានូវសំណួររបស់ខ្លួន និងបញ្ជូនបន្តទៅកាន់តុលាការជាផ្លូវការ ។ ជាក់ស្តែង សំណួររួមមាន ១) ហេតុអ្វីបានជាតុលាការចំណាយរយៈពេលវែងម្ល៉េះធ្វើលើរឿងនេះ? ២) តើអ្នកណានឹងត្រូវបានចោទប្រកាន់ខ្លះក្នុងសំណុំរឿង ០០៣ និង០០៤នេះ? ៣) តើមានប្រជាជនប៉ុន្មាននាក់ស្លាប់នៅក្នុងតំបន់នេះ ហើយអ្នកណាជាមេដឹកនាំ? ៤) ហេតុអ្វីបានជាខ្មែរក្រហម បែងចែកប្រព័ន្ធគ្រប់គ្រងរដ្ឋបាលជាតំបន់ ហើយមានលេខសម្គាល់នានា? ៥) តើអ្វីទៅជាកងចល័ត? ៦) ហេតុអ្វីបានជាអំពើប្រល័យពូជសាសន៍កើតមាននាពេលនោះ? ៧) តើនរណាជាអ្នកបង្កើតឈ្មោះខ្មែរក្រហម? ៨) ហេតុអ្វីបានជាខ្មែរក្រហមលុបបំបាត់សាសនា? ៩) តើអ្វីជាគោលបំណងពិតប្រាកដរបស់ខ្មែរក្រហម? តើមានតំបន់សរុបប៉ុន្មានដែលត្រូវបានគេបែងចែក? តើមានកន្លែងសរុប ប៉ុន្មានដែលខ្មែរក្រហមយកធ្វើជាតំបន់សម្លាប់ ហើយតើហេតុអ្វីបានជានៅក្នុងតំបន់នេះមានកន្លែងសម្លាប់ច្រើនម្ល៉េះ? ១០) តើមានសំណាងជួសជុលសមូហភាពទេ បន្ទាប់ពីករណីសំណុំរឿង០០២ ត្រូវបញ្ចប់? បន្ទាប់ពីមានការលើកឡើងសំណួរទាំងនេះហើយ លោក ដាល លីសាក់ ធ្វើការឆ្លើយតបទៅនឹងសំណួរទាំងនោះម្តងមួយៗ ។

## បញ្ចប់សេចក្តី

វេទិកានេះផ្តល់ឱកាសដ៏ល្អសម្រាប់អ្នកភូមិ ជាពិសេសសម្រាប់ជនជាតិចាម បញ្ចេញទស្សនៈផ្ទាល់ខ្លួន ក្នុងកិច្ចពិភាក្សាប្រកបដោយតម្លាភាព អំពីដំណើរការកាត់ទោសមេដឹកនាំជាន់ខ្ពស់ខ្មែរក្រហម ។ ទោះបីជាករណីសំណុំរឿង០០២/០១ ត្រូវបានបញ្ចប់ក៏ដោយ ការបន្តសាលក្រមលើករណីសំណុំរឿង០០២/០២ នៅតែបន្ត ជាករណីសំខាន់ទៀត ដែលពាក់ព័ន្ធផ្ទាល់នឹងឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ ប្រឆាំងនឹងជនជាតិចាម និងជនជាតិវៀតណាម ។ ដែលអ្នកទាំងនោះគឺជាក្រុមគោលដៅ ក្រុមជនជាតិភាគតិចដែលត្រូវបានសម្លាប់ ។ គួរបញ្ជាក់ថា ប្រជាជនដែលរស់នៅក្នុងឃុំស្វាយឃ្លាំងពេញចិត្តនឹងការទទួលព័ត៌មាននេះ ដោយសារតែតំបន់នេះពាក់ព័ន្ធនឹងការចោទប្រកាន់នៃអំពើប្រល័យពូជសាសន៍ប្រឆាំងនឹងមេដឹកនាំជាន់ខ្ពស់ខ្មែរក្រហមដែលនៅរស់នឹងត្រូវកាត់ទោសឆាប់ៗនេះ ។

ការប្រារព្ធវេទិកានៅក្នុងឃុំស្វាយឃ្លាំងនេះធ្វើឡើងអស់រយៈពេលស្ទើរតែពេញមួយថ្ងៃ ដោយមានការចូលរួមពីសំណាក់ប្រជាជនលើសពី២០០នាក់ នាពេលព្រឹក និងជាង១០០នាក់ នាពេលរសៀលថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ២០១៤នេះ ។ ការចង់ដឹង និងឆន្ទៈក្នុងការចូលរួមនេះបានចូលរួមចំណែកដល់ការប្រព្រឹត្តទៅប្រកបដោយផ្លែផ្កា ទទួលបានលទ្ធផលល្អសម្រាប់លោក ដាល លីសាក់ ។ ប្រជាជនទទួលស្គាល់នូវកិច្ចខិតខំប្រឹងប្រែងរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា និងសារប្រយោជន៍នៃការប្រឹងប្រែងនេះ ប៉ុន្តែអ្នកទាំងនេះនៅតែទទូចសុំឲ្យអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាពន្លឿននូវដំណើរការជាងនេះ ។ តុលាការត្រូវតែមានការប្រុងប្រយ័ត្នខ្ពស់ចំពោះករណីសំណុំរឿង ០០៣ និង០០៤ ។ **លី សុខឃាង**

# ថ្នាក់រៀននៅទួលស្លែង

មជ្ឈមណ្ឌលឯកសារកម្ពុជាបានបង្កើតថ្នាក់រៀនសាធារណៈមួយនៅសារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង ។ ថ្នាក់រៀននេះត្រូវបានបង្កើតឡើងក្នុងខែវិច្ឆិកា ឆ្នាំ២០១១ ដោយមានកិច្ចសហការរវាងមជ្ឈមណ្ឌលឯកសារកម្ពុជា និងក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ។ សារមន្ទីរទួលស្លែងគឺជាអតីតសាលារៀនដ៏ទំនើបមួយដែលបានសង់ឡើងជាលើកដំបូងនៅក្នុងឆ្នាំ១៩៦២ ។ ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ខ្មែរក្រហមបានប្រែក្លាយសាលារៀននេះទៅជាគុកដ៏សម្ងាត់បំផុតមួយក្នុងចំណោមគុកចំនួន១៩៦ទូទាំងប្រទេស ។ អ្នកទោសភាគច្រើនដែលត្រូវបញ្ជូនទៅទួលស្លែងគឺជាកម្មាភិបាលខ្មែរក្រហមដែលត្រូវបានចោទប្រកាន់ពីបទប្រព្រឹត្តអំពើក្បត់ជាតិដូចជា ការសហការជាមួយរដ្ឋាភិបាលបរទេស ឬធ្វើជាអ្នកស៊ើបការណ៍ឲ្យសេ.អ៊ី.អា ឬ កា.ហ្សេ.បេ ជាដើម ។



ចាប់តាំងពីការប្រែក្លាយពីកន្លែងរៀនសូត្រមួយទៅជាកន្លែងដ៏គួរឲ្យរន្ធត់ និងមហន្តរាយមួយ ទួលស្លែងមិនដែលទទួលបានមុខងាររបស់ខ្លួនដូចកាលពីដើមវិញឡើយ ។ ទោះជាយ៉ាងនេះក្តី នៅពេលអនាគត ដើម្បីទាមទារមកវិញនូវកេរដំណែលអប់រំដែលមានលក្ខណៈវិជ្ជមានរបស់ទួលស្លែង និងដើម្បីបន្ថែមសមាសភាពអប់រំមួយទៅក្នុងសារមន្ទីរនេះ ថ្នាក់រៀននេះត្រូវបានបង្កើតឡើងដើម្បីផ្តល់ការបង្រៀន និងការពិភាក្សាដោយឥតគិតថ្លៃអំពីប្រវត្តិសាស្ត្ររបបខ្មែរក្រហម និងប្រធានបទដែលជាប់ទាក់ទងដូចជា អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។ ថ្នាក់រៀននេះក៏ជាវេទិកាសាធារណៈមួយសម្រាប់ឲ្យអ្នកមកទស្សនា និងអ្នកដែលនៅរស់រានមានជីវិតចែករំលែកព័ត៌មានគ្នាក្នុងការថែរក្សារយៈកាលនៃប្រវត្តិសាស្ត្រកម្ពុជាដ៏មានសារសំខាន់មួយទុកឲ្យអ្នកជំនាន់ក្រោយបានរៀនសូត្រ ។

បុគ្គលិកមជ្ឈមណ្ឌលឯកសារកម្ពុជា និងសារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង ដែលមានសញ្ញាបត្រមកពីបរទេស និងបានទទួលវិញ្ញាបនបត្រពីក្រសួងអប់រំ យុវជន និងកីឡា ផ្នែកការបង្រៀនប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-៧៩) ព្រមទាំងមានការចូលរួមពីអ្នកជំនាញជាតិនិងអន្តរជាតិដែលមានជំនាញលើប្រវត្តិសាស្ត្រប្រទេសកម្ពុជា និងអ្នកដែលនៅរស់រានមានជីវិតពីមន្ទីរស-២១ នឹងបង្រៀននៅថ្នាក់រៀននេះ ។ ព័ត៌មានទាក់ទងនឹងថ្នាក់រៀននេះ សូមទាក់ទង ម៉ែន ពិចិត្រ តាមរយៈទូរស័ព្ទលេខៈ ០២៣ ២១១ ៨៧៥ ឬអ៊ីម៉ែល : truthpechet@dccam.org ។

**◆ ទីកន្លែង : អាគារ "ក" ជាន់លើ ◆ ពេលវេលា : ច័ន្ទ ២-៣រសៀល, ពុធ ៩-១០ព្រឹក, សុក្រ ២-៣រសៀល**

# សន្យាឫស្សី ៖ គុកឥតជញ្ជាំង សៀវភៅរៀបរាប់ពីជីវិតក្នុងរបបខ្មែរក្រហម

ការសម្លាប់រង្គាលនៅក្នុងប្រទេសកម្ពុជា នៅតែជាប់ជាកំណត់ហេតុនៅក្នុងពិភពលោកចំពោះអំពើបំភិតបំភ័យដែលបង្កើតឡើងដោយរដ្ឋ ។ មិនមានរដ្ឋាភិបាលណាមួយបានសម្លាប់ប្រជាជនរបស់ខ្លួនយ៉ាងច្រើនដូចគ្នានឹងរបបខ្មែរក្រហម ហើយក្នុងនោះ ១ភាគ៥ នៃប្រជាជន ស្មើទៅនឹងជាង១លាន ៥សែននាក់ បានស្លាប់ក្រោមកណ្តាប់ដៃខ្មែរក្រហម ។ យើងពិបាកយល់ដឹងអំពីចំនួនអ្នកស្លាប់ និងផលប៉ះពាល់លើប្រជាជន សង្គម សេដ្ឋកិច្ច និងវប្បធម៌ណាស់ ។ អត្ថបទ បំប៊ូប្រូមីស (Bomboo Promise) របស់ វិជ្ជារ៉ា ហួន គឺជាការក្រើនរំឭកដល់អ្នកស្លាប់នៅក្នុងរបបខ្មែរក្រហមដែលមានន័យចំពោះអ្នករស់រានមានជីវិតនាពេលបច្ចុប្បន្ន ។ ដោយសារអត្ថបទនេះ ត្រូវបានសរសេរជាច្រើនឆ្នាំបន្ទាប់ពីរបបខ្មែរក្រហមបានកើតឡើង ទោះបីជាយ៉ាងណាក៏ដោយ អត្ថបទរបស់គាត់មានលក្ខណៈថ្មីសន្ធាង និងមានព្រឹត្តិការណ៍ពាក់ព័ន្ធជាច្រើន ។ សាច់រឿងរបស់គាត់បង្ហាញអំពីសេចក្តីក្លាហាន និងការរស់រានមានជីវិត និងជាសាច់រឿងដែលគួរឲ្យចាប់អារម្មណ៍ ។ ចុងបញ្ចប់ដូចដែល យើងដឹង វិជ្ជារ៉ា បានរស់រានមានជីវិតដើម្បីប្រាប់ពីសាច់រឿងនៃការសម្លាប់រង្គាលនោះ ។ ការរស់រានមានជីវិត និងជីវិតថ្មីរបស់គាត់នៅសហរដ្ឋអាមេរិកបានធ្វើឲ្យគាត់ចង់យល់ដឹងអំពីបទពិសោធន៍របស់គាត់ពាក់ព័ន្ធនឹងការបង្អត់អាហារ និងការស្លាប់មួយផ្នែកដើម្បីគោរពចំពោះអ្នកដែលបានស្លាប់ ។ អត្ថបទ បំប៊ូប្រូមីស បំពេញបន្ថែមដល់ការកើនឡើងនៃចំនួនសៀវភៅដែលបោះពុម្ពផ្សាយជាភាសាអង់គ្លេស ដោយអ្នកដែលបានរស់នៅឆ្លងកាត់ការភ័យខ្លាច អស់រយៈពេលជាច្រើនឆ្នាំ នៅពេលដែលខ្មែរក្រហមបានដៅធ្វើទារុណកម្ម និងសម្លាប់បញ្ញវន្តជាច្រើននាក់ ។ អត្ថបទ បំប៊ូប្រូមីស បញ្ជាក់យ៉ាងច្បាស់ថា យើងនឹងមិនភ្លេចអ្វីដែលបានកើតឡើងនៅក្នុងប្រទេសកម្ពុជា ក្នុងទសវត្សរ៍៧០ នោះទេ ។



សន្យាឫស្សី ៖ គុកឥតជញ្ជាំង សៀវភៅរៀបរាប់ពីជីវិតក្នុងរបបខ្មែរក្រហម

ផ្នែកទី១ នៃសន្យាឫស្សី ពិពណ៌នាអំពីកុមារភាពរបស់ វិជ្ជារ៉ា នៅសម័យក្រោយប្រទេសកម្ពុជា

ទទួលបានឯករាជ្យ ហើយផ្នែកទីពីនៃសៀវភៅនេះជីកកកាយនូវសាច់រឿងអំពីភាពអត់ឃ្លាន និងការធ្វើការហួសកម្លាំងអស់រយៈពេលជាច្រើនឆ្នាំនៅក្នុងរបបខ្មែរក្រហម ។ ផ្នែកចុងក្រោយរៀបរាប់អំពីការត្រឡប់មករកសភាពធម្មតា និងការសម្រេចចិត្តចុងក្រោយរបស់ វិដ្ឋារ៉ា ដើម្បីរត់គេចទៅប្រទេសថៃ។ អំពើប្រល័យពូជសាសន៍នៅក្នុងប្រទេសកម្ពុជាបន្តស្វែងយល់ការស្រមើស្រមៃរបស់យើងដ៏អាថ៌កំបាំងមួយនេះ ។ សម្រាប់ទិដ្ឋភាពមួយនោះ ខ្មែរក្រហមបានចូលកាន់អំណាចនៅពេលដែលជនបរទេសនៅក្នុងទីក្រុង ។ ជាងនេះទៅទៀត មានជនជាតិអឺរ៉ុប និងជនជាតិអាមេរិកកាំងមួយចំនួនមាន ទំនាក់ទំនងជាមួយនឹងខ្មែរក្រហមកាលពីដំបូង ហើយបានស្វែងយល់អំពីវិធីសាស្ត្រនៃការឃោសនារបស់ខ្មែរក្រហមទាំងនោះដែលផ្តល់ជាតម្រុយនូវការកកើតឡើងនៅអំពើបំភិតបំភ័យ ។ អត្ថបទបោះពុម្ពផ្សាយនេះ បង្ហាញនូវទិដ្ឋភាពលម្អិតនៃការជម្លៀសប្រជាជនចេញពីទីក្រុង ហើយអ្នកមានអំណាចបានគ្រប់គ្រងសមូហភាវូបនីយកម្មដោយផ្អែកលើការកាត់បន្ថយចំនួនប្រជាជន ។ ខ្មែរក្រហមបានប្រាប់អ្នករាយការណ៍កាសែតញ៉ូវរីក បន្ទាប់ពីការដួលរលំទីក្រុងថា អ្នកទីក្រុង និងធ្វើស្រែ ហើយជាងនេះទៅទៀត អ្នកទាំងនោះនឹងធ្វើការងារ ឬអត់អាហារ ។

ខ្មែរក្រហមបានធ្វើតាមការសន្យា នៅពេលដែលខ្មែរក្រហមទាំងនោះអាចគ្រប់គ្រងទីក្រុងភ្នំពេញ នៅខែមេសា ឆ្នាំ១៩៧៥ ។ ខ្មែរក្រហមទាំងនោះបានបង្ខំឲ្យបញ្ញវន្តភ្ជួរស្រែ បង្ខំឲ្យជនម៉ូស្លីមបរិភោគសាច់ជ្រូក ។ ពួកគេបានចិញ្ចឹមជ្រូកនៅក្នុងបណ្ណាល័យជាតិ បានបំផ្លាញទ្រព្យសម្បត្តិឯកជន រួមមានប្រាក់កាក់ ។ ចាប់តាំងពីការចាប់ផ្តើម ជនភៀសខ្លួនកម្ពុជា ដែលអាចរត់គេចទៅប្រទេសថៃ បានពិពណ៌នាអំពីភាពវឹកវរ និងការច្របូកច្របល់នៅតាមផ្ទះ ប៉ុន្តែសាច់រឿងរបស់ជនភៀសខ្លួន ទាំងនោះត្រូវបំភ្លេចចោលថាជាសាច់រឿងចម្លែកនិងមិនគួរឲ្យជឿ ។ សាច់រឿងអំពីការប្រើពលកម្មទាសករ ការសម្លាប់ឪពុកម្តាយ និងក្មេងៗត្រូវអ្នកគាំទ្ររបបខ្មែរក្រហមនៅលោកខាងលិច ព្រងើយកន្តើយ ។ ទោះបីជាយ៉ាងណាក៏ដោយ ១ឆ្នាំក្រោយមក មន្ទីររដ្ឋរបស់ប្រទេសអាមេរិក បានបញ្ជាក់ថា ខ្មែរក្រហមបានបង្កើតប្រព័ន្ធវាលស្រែ ដែលមនុស្សក្មេង មនុស្សចាស់ធ្វើស្រែ ដូចជាទាសករ ចាប់តាំងពីព្រឹកព្រលឹមរហូតដល់ពេលយប់ ដោយមិនមានប្រើឧបករណ៍ទំនើប និងត្រូវស្ថិតក្រោមការឃ្លាំមើលរបស់យោធាខ្មែរក្រហមដែលគួរឲ្យខ្លាច ។ មន្ទីររដ្ឋបានកត់សម្គាល់ថា របបខ្មែរក្រហមបានសម្លាប់មន្ត្រីរដ្ឋាភិបាលនិងអ្នកជំនាញ ព្រមទាំងសាច់ញាតិរបស់ពួកគេ ។ ប៉ុន្តែបញ្ញវន្តដែលសិក្សានៅបរទេសជាច្រើនបានបោះបង់ចោលសាច់រឿងដ៏គួរឲ្យភ័យខ្លាចនេះ ដូច្នេះហើយបញ្ញវន្តទាំងនោះ បានគាំទ្ររបបខ្មែរក្រហមដោយប្រយោល ។

កងទ័ពវៀតណាមបានឈ្លានពានរបបកម្ពុជាប្រជាធិបតេយ្យ ហើយបានបណ្តេញខ្មែរក្រហម ចេញពីអំណាចនៅខែមករា ឆ្នាំ១៩៧៩ ។ ជាអកុសល ការឈ្លានពានដើម្បីរំដោះយកសេរីភាពរបស់កងទ័ពវៀតណាមបានធ្វើឲ្យប្រជាជនកម្ពុជាបញ្ចប់នូវភាពភ័យខ្លាចអស់រយៈពេលជាច្រើនឆ្នាំ និងបាននាំយកអ្នកទទួលខុសត្រូវចំពោះអំពើឧក្រិដ្ឋកម្មមកផ្តន្ទាទោស ។ រដ្ឋាភិបាលវៀតណាមមានរបៀបវារៈផ្ទាល់ខ្លួន ដែលត្រូវគ្រប់គ្រងនិងត្រួតត្រាប្រទេសកម្ពុជា ។ ទន្ទឹមពេលដែលវៀតណាមបានបង្កើតសារមន្ទីរប្រល័យពូជសាសន៍ទួលស្លែង (ដែលជាអតីតគុក ជាទីដែលមនុស្សរាប់ពាន់នាក់ត្រូវបានធ្វើ ទារុណកម្ម និងសម្លាប់) មិនមានតុលាការឧក្រិដ្ឋកម្មសង្គ្រាម ឬកិច្ចខិតខំប្រឹងប្រែង ដើម្បីស្វែងរកដំណោះស្រាយចំពោះជនរងគ្រោះ និងអ្នករស់រានមានជីវិត ពីអំពើប្រល័យពូជសាសន៍បានធ្វើឡើងនោះទេ ។ ទាល់តែឆ្នាំ២.០០០ ទំរាំដែលតុលាការខ្មែរក្រហមត្រូវបានបង្កើតឡើងដើម្បីជំនុំជម្រះមេដឹកនាំខ្មែរក្រហម ។

សៀវភៅរបស់ វិដ្ឋារ៉ា ហួន បានដើរតួនាទីយ៉ាងសំខាន់ក្នុងការរំឭកដល់សហគមន៍អន្តរជាតិ ដែលថាការដាក់ទណ្ឌកម្មមិនគួរត្រូវបានលើកលែងនោះទេ ទោះបីជាត្រូវបានពន្យារពេលជាច្រើនទសវត្សរ៍ក៏ដោយ ។ ពិតប្រាកដណាស់ អ្នករស់រានមានជីវិតពីអំពើប្រល័យពូជសាសន៍ជាច្រើន បានស្លាប់ក្នុងរយៈពេលប៉ុន្មានទសវត្សរ៍នៃដំណាក់កាលធ្វើអន្តរាគមន៍របស់អន្តរជាតិ ។ ទោះបីជាយ៉ាងណាក៏ដោយ អត្ថបទ បំប៊ូ ប្រូមមីស ជួយជីកកកាយនូវអាថ៌កំបាំងនៃអំពើប្រល័យពូជសាសន៍ និងផលប៉ះពាល់នៃរបបប្រល័យពូជសាសន៍មកលើអ្នករស់រានមានជីវិត ។

អត្ថបទ បំប៊ូ ប្រូមមីស បានចាប់ផ្តើមនៅទសវត្សរ៍៥០

នៅពេលដែលជីវិតហាក់បីដូចជា មានភាពសុខស្រួលនិងមានភាពជោគជ័យ ។ ការចាប់កំណើតរបស់ វិដ្ឋារ៉ា ស្របពេលជាមួយនឹងការផ្លាស់ប្តូរសង្គមនិងសេដ្ឋកិច្ចយ៉ាងលឿន ដែលបានកើតឡើងក្រោមរដ្ឋាភិបាល សម្តេច សីហនុ (ឆ្នាំ១៩៥៤ដល់ឆ្នាំ១៩៧០) ។ ការអប់រំកម្រិតឧត្តមសិក្សាត្រូវបានពង្រីក ។ ក្មេងៗគ្រប់អាយុចូលរៀនរាប់លាននាក់បានចូលរៀនសាលាបឋមសិក្សា ហើយទទួលបានការបណ្តុះបណ្តាលថ្នាក់មូលដ្ឋាន ទន្ទឹមពេលដែលបច្ចេកទេសផលិតកម្មថ្មីបានបង្កើនទិន្នផលស្រូវយ៉ាងច្រើន ហើយបានដាក់ប្រាក់បម្រុងក្នុងធនាគារមជ្ឈិមរបស់កម្ពុជា ។

វិដ្ឋារ៉ា ត្រូវបានចិញ្ចឹមបីបាច់នៅក្នុងផ្ទះចាស់ដែលឆ្លងកាត់អស់ច្រើនជំនាន់នៅចំកណ្តាលទីក្រុងភ្នំពេញ ។ ឪពុករបស់ វិដ្ឋារ៉ា ធ្វើការនៅក្រុមហ៊ុនផលិតឱសថ ហើយបានក្លាយជាអ្នកជំនួញដ៏ជោគជ័យ និងមានទ្រព្យសម្បត្តិ ។ ភាពជោគជ័យខាងជំនួញរបស់គាត់បាននាំទៅរកការងារខាងនយោបាយ ហើយគាត់បានធ្វើជាសមាជិកសភាជាច្រើនឆ្នាំចាប់ផ្តើមនៅដើមទសវត្សរ៍៦០ ។ ទោះបីជាយ៉ាងណាក៏ដោយ កុមារភាពរបស់ វិដ្ឋារ៉ា ត្រូវបានបំភិតបំភ័យដោយព្រឹត្តិការណ៍ពីរ ។ ទី១) នៅពេលដែលគាត់ មានអាយុ ៨ឆ្នាំ ម្តាយរបស់គាត់បានស្លាប់ បន្ទាប់ពីការវះកាត់ដោយមិនមានជំនាញច្បាស់លាស់ ដើម្បីយកដុំសាច់ចេញ ។ ភ្លាមៗបន្ទាប់ពីនោះមក ឪពុករបស់ វិដ្ឋារ៉ា បានយកប្រពន្ធថ្មីដែលមិនអាចបង្កើតកូនផ្ទាល់ខ្លួនបាន ។ កំហឹងច្រណែនរបស់ម្តាយចុងទៅលើកូនស្រីដើមរបស់ខ្លួន បង្កឲ្យមានអំពើឃោរឃៅ ដូចដែលបានបង្ហាញនូវក្នុងរឿងនិទាននៅជុំវិញពិភពលោក ។ វិដ្ឋារ៉ា បានរស់នៅជិតស្និទ្ធជាមួយក្រុមគ្រួសារមានសមាជិកច្រើនរបស់ខ្លួន ហើយបានពឹងផ្អែកលើការមើលថែពីជីដូនជីតាខាងម្តាយ និងសាច់ញាតិផ្សេងៗ ដើម្បីប៉ះប៉ូវនូវជីវិតដែលជួបបញ្ហានៅក្នុងផ្ទះ ។ កាលពីក្មេង ការប្រឈមទី២កើតឡើងចេញពីទំនាក់ទំនងដ៏លំបាករបស់ឪពុករបស់ វិដ្ឋារ៉ា ជាមួយនឹងគ្រួសាររបស់គាត់ ។ ឪពុករបស់ វិដ្ឋារ៉ា បានបាត់បង់ម្តាយរបស់គាត់កាលពីគាត់នៅក្មេង ហើយជីតារបស់គាត់បានរៀបការជាមួយស្ត្រីម្នាក់ដែលមានកូនជាច្រើន ។ សាច់ញាតិឪពុក វិដ្ឋារ៉ា ជាញឹកញាយខឹង និងច្រណែន វិដ្ឋារ៉ា ដែលជាកូនស្រីតែម្នាក់គត់របស់អ្នកជំនួញមានទ្រព្យសម្បត្តិនោះ ។

វិដ្ឋារ៉ា បានចូលរៀននៅសកលវិទ្យាល័យ នៅកន្លែងដែលខ្លួនបានជួបជាមួយមិត្តប្រុសដំបូងរបស់ខ្លួន ។ ចំពេលដែល វិដ្ឋារ៉ា កំពុងសិក្សានៅសកលវិទ្យាល័យ ពេលនោះចំពេលដែលយោធាអាមេរិក ខិតខំប្រឹងប្រែងទប់ស្កាត់ជនកុម្មុយនីស្តវៀតណាមមិនឲ្យជ្រកកោននៅតាមទីជនបទក្នុងប្រទេសកម្ពុជា ។ ការទម្លាក់គ្រាប់បែកដោយសម្ងាត់បានចាប់ផ្តើមនៅក្នុងឆ្នាំ១៩៦៦ ប៉ុន្តែបានកើនឡើងនៅក្នុងចន្លោះឆ្នាំ១៩៦៩-១៩៧៣ ។ ការទម្លាក់គ្រាប់បែកជាបន្តបន្ទាប់មកលើភូមិនិងវាលស្រែ បានធ្វើមានអស្ថិរភាពនៅក្នុងប្រទេសកម្ពុជា និងបានបង្កើតភាពតានតឹងផ្នែកនយោបាយសង្គម និងសេដ្ឋកិច្ច ។

ការស្លាប់របស់ជនស៊ីវិលដោយសារការទម្លាក់គ្រាប់បែកបានជំរុញឲ្យប្រជាជននៅតាមជនបទ ចូលរួមប្រយុទ្ធជាមួយខ្មែរក្រហម ដែលបានទទួលការគាំទ្រតិចតួចរហូតដល់ការទម្លាក់គ្រាប់បែក បានចាប់ផ្តើមដោយធ្វើឲ្យមានការពង្រីកសង្គ្រាមវៀតណាមចូលក្នុងប្រទេសកម្ពុជា ការធ្វើរដ្ឋប្រហារក្នុងឆ្នាំ១៩៧០ដែលទម្លាក់ សម្តេច សីហនុ ការងើបឡើងយ៉ាងលឿនរបស់ខ្មែរក្រហមនិងចុងក្រោយអំពើប្រល័យពូជសាសន៍ក្នុងប្រទេសកម្ពុជា ។

នៅដើមទសវត្សរ៍៧០ វិដ្ឋារ៉ា និងមិត្តប្រុស បានផ្សារភ្ជាប់ទំនាក់ទំនងស្នេហារួចហើយ ។ ប៉ុន្តែគ្រួសាររបស់ វិដ្ឋារ៉ា បានព្យាយាមផ្គូរផ្គងជាមួយកូនអ្នកមានទ្រព្យសម្បត្តិ និងកិត្តិយស ។ ទន្ទឹមពេលដែល វិដ្ឋារ៉ា រង់ចាំឪពុករបស់ខ្លួនទទួលយកមិត្តប្រុសបច្ចុប្បន្នរបស់ខ្លួន វិដ្ឋារ៉ា បានសម្រេចចិត្ត ព្យាយាមបញ្ចប់ការសិក្សារបស់ខ្លួននៅប្រទេសបារាំង ។ ឪពុករបស់ វិដ្ឋារ៉ា មានការស្ទាក់ស្ទើរយល់ស្របជាមួយការសិក្សារបស់ វិដ្ឋារ៉ា នៅប្រទេសបារាំង ។ ដូច្នេះហើយ វិដ្ឋារ៉ា បានបន្តការសិក្សានៅសកលវិទ្យាល័យទន្តសាស្ត្រ និងឱសថសាស្ត្រក្នុងទីក្រុងភ្នំពេញវិញ ។ ការសម្រេចចិត្តនោះ បានបង្កើតទៅជាកម្មវាសនា ។ សូម្បីតែក្នុងឆ្នាំ១៩៧៤ដែលសញ្ញាណនៃការគំរាមកំហែង បានកើតឡើងជាច្រើននៅទីក្រុងភ្នំពេញ ហើយបន្ទាប់ពីគ្រួសារដែលមានទ្រព្យសម្បត្តិជាច្រើនបានបញ្ជូនកូនរបស់ខ្លួនទៅបរទេសដើម្បីសុវត្ថិភាពនោះ ឪពុករបស់ វិដ្ឋារ៉ា មិនមានភាពប្រាកដប្រជាចំពោះការបញ្ជូនកូនទៅប្រទេសបារាំងនោះឡើយ ។ អាពាហ៍ពិពាហ៍របស់

វិជ្ជារ៉ា បានប្រព្រឹត្តឡើងប៉ុន្មានឆ្នាំបន្ទាប់ពីមានការភ្ជាប់ពាក្យជាផ្លូវការ នៅពេលដែលឪពុករបស់ វិជ្ជារ៉ា ទន់ចិត្ត ទោះបីជាពិធីរៀបការត្រូវបានរំខានដោយយោធាខ្មែរក្រហមដែលខិតជិតចូលមកទីក្រុង និងភាពវឹកវរនៅក្នុងទីក្រុងក៏ដោយ ។

វិជ្ជារ៉ា ព្រមទាំងប្តី ឪពុក និងម្តាយក្រោយ និងសាច់ថ្លៃត្រូវបានជម្លៀសចេញពីទីក្រុងភ្នំពេញ ។ ខ្មែរក្រហមបានបញ្ចប់ជីវភាពអ្នករស់នៅក្នុងទីក្រុង បិទមន្ទីរពេទ្យ សាលារៀន និងសារមន្ទីរ ។ រោងចក្រត្រូវបានបិទ ។ ព្រះសង្ឃត្រូវបានបណ្តេញចេញពីវត្ត ។ ប្រជាជនទាំងអស់ត្រូវផ្លាស់ទីទៅជនបទដោយមានឧបករណ៍ធ្វើស្រែចម្ការ និងរស់នៅក្នុងទីជម្រកថ្មី ។ ប្រទេសកម្ពុជាបានក្លាយទៅជាគុកដ៏ធំមួយ ។ គោលបំណងនោះគឺដើម្បីគ្រប់គ្រងប្រទេសទាំងមូលដោយទប់ស្កាត់ការរស់នៅជាលក្ខណៈបុគ្គល ឬការគិតបែបឯករាជ្យ ។ ក្នុងទិដ្ឋភាពនេះ នរណាក៏ដោយដែលកើតចេញពីវណ្ណៈដែលមានការអប់រំរៀនសូត្រ គឺជាជនសង្ស័យ ។ ដូច្នេះហើយគ្រួសារ វិជ្ជារ៉ា ប្រឈមមុខទៅនឹងមហន្តរាយទ្វេដង ដោយសារអ្នកទាំងនោះគឺជាអ្នកទីក្រុងដែលមិនទាន់រៀបចំខ្លួនរស់នៅតាមស្រែចម្ការ ហើយក៏ជាក្រុមមានទ្រព្យសម្បត្តិ និងមានការអប់រំដែលត្រូវដៅជាមុខសញ្ញា ។

វិជ្ជារ៉ា និងឪពុក ត្រូវបានបង្ខំឲ្យផ្លាស់ទីលំនៅពីភូមិដាច់ស្រយាលមួយទៅមួយទៀត ហើយបានរស់នៅក្នុងផ្ទះដ៏តូចនៅជិតសាច់ថ្លៃរបស់ខ្លួន ។ វិជ្ជារ៉ាបានបែកចេញពីប្តីរបស់ខ្លួន ដែលត្រូវយោធាខ្មែរក្រហមនាំយកទៅសម្លាប់ ។ ចាប់តាំងពីពេលនោះមក វិជ្ជារ៉ា លេងឃើញប្តីរបស់ខ្លួនតទៅទៀត ។

ក្មេងៗ និងមនុស្សចាស់ជាមនុស្សដំបូងដែលស្លាប់ ។ ឪពុករបស់ វិជ្ជារ៉ា បានស្លាប់បន្ទាប់ពីការរស់នៅក្នុងជីវភាពក្រខ្សត់ ការខ្វះអាហារូបត្ថម្ភ ខ្វះថ្នាំសង្កូវ ។ បន្ទាប់ពីឪពុករបស់ វិជ្ជារ៉ា ស្លាប់ដោយការឈឺចាប់ វិជ្ជារ៉ា បានមករស់នៅជាមួយសាច់ថ្លៃដែលមិនចូលចិត្តចែករំលែកអាហារជាមួយអ្នកដទៃ ទន្ទឹមពេលដែលសាច់ថ្លៃទាំងនោះចងសងសឹកឪពុករបស់ វិជ្ជារ៉ា ចំពោះការពន្យាពេលការរៀបការរបស់ វិជ្ជារ៉ា និងប្តីអស់រយៈពេលជាច្រើនឆ្នាំ ។ នៅពេលដែលស្ថានភាពការហូបចុកបន្តយ៉ាប់យ៉ឺន វិជ្ជារ៉ា យល់ឃើញថាខ្លួនមិនត្រូវបានស្វាគមន៍ លែងត្រូវការហើយក៏សម្រេចចិត្តតស៊ូដោយខ្លួនឯង ។ វិជ្ជារ៉ា ចូលទៅសម្រាកព្យាបាលរបួសក្នុងមន្ទីរពេទ្យនៅចុងឆ្នាំ១៩៧៨ នៅពេលដែលទាហានវៀតណាម ដេញខ្មែរក្រហមទៅព្រំដែនហើយបង្កើតរដ្ឋាភិបាលថ្មីនៅក្នុងទីក្រុងភ្នំពេញ ។

ផ្នែកទី៣នៃសៀវភៅនេះ ដឹកកកាយនូវដំណើរវិលត្រឡប់មកទីក្រុងភ្នំពេញរបស់ វិជ្ជារ៉ា ។ ក្នុងឆ្នាំ១៩៧៩ វិជ្ជារ៉ា បានទំនាក់ទំនងជាមួយមិត្តភក្តិចាស់ និងសាច់ញាតិចាស់មួយចំនួនសាជាថ្មី ។ វិជ្ជារ៉ា បានមកលេងផ្ទះរបស់ខ្លួន ដែលត្រូវបានរុករើ និងត្រូវយកវត្ថុមានតម្លៃចេញទាំងអស់ ។ ដោយសារតែមានជំនាញផ្នែកភាសា វិជ្ជារ៉ា បានក្លាយជាអ្នកបកប្រែឲ្យជនជាតិវៀតណាម និងសមាគមន៍ជនជាតិបរទេស ។ ពេលនោះ វិជ្ជារ៉ា ក៏បានបញ្ចប់បរិញ្ញាបត្រផ្នែកឱសថសាស្ត្រដែរ ។ ទោះបីជាយ៉ាងណាក៏ដោយ ទុក្ខព្រួយបានញាំញីជីវិតរបស់ វិជ្ជារ៉ា រាល់ពេលដែល វិជ្ជារ៉ា នឹកដល់ការបាត់បង់ និងការបាត់ខ្លួនមនុស្សជាទីស្រលាញ់របស់ខ្លួន ។ បន្ទាប់ពីអស់រយៈពេលជាច្រើនឆ្នាំដែលបានរសាត់អណ្តែតហើយព្យាយាមស្វែងរកតួនាទីសម្រាប់ខ្លួនឯងផ្ទាល់ វិជ្ជារ៉ា បានធ្វើការសម្រេចចិត្តយ៉ាងច្បាស់ និងប្រថុយប្រថានរត់គេចទៅប្រទេសថៃ ។

នៅដើមឆ្នាំ១៩៨៣ វិជ្ជារ៉ា បានទៅដល់ជំរុំជនភៀសខ្លួននៅតាមព្រំដែនប្រទេសថៃ ។ យ៉ាងហោចណាស់ វិជ្ជារ៉ា មានសេរីភាពក្នុងការស្រមៃឃើញអនាគតដ៏ប្រសើរ ។ សៀវភៅនេះបានបញ្ចប់ទៅដោយការរត់គេចទៅប្រទេសថៃ ។ យើងដឹងថា វិជ្ជារ៉ា បានទៅដល់សហរដ្ឋអាមេរិកនៅក្នុងឆ្នាំ១៩៨៥ ។ យើងនឹងរង់ចាំមើលសៀវភៅទី២ ដើម្បីស្តាប់អំពីការរត់គេចទៅជំរុំជនភៀសខ្លួន និងរស់នៅសហរដ្ឋអាមេរិក ។ ស្របពេលជាមួយគ្នានេះដែរ យើងមានសំណាងដែលថា វិជ្ជារ៉ា សម្រេចចិត្តបោះពុម្ពផ្សាយជីវប្រវត្តិរបស់ខ្លួន ។ វិជ្ជារ៉ា គឺជាអ្នកនិពន្ធដែលមានលក្ខណៈ ជំរុញលើកទឹកចិត្ត ហើយបានបង្ហាញនូវសាច់រឿងដ៏សោកសៅ និងទាក់ទាញស្តីពីការរងទុក្ខអស់រយៈពេលជាច្រើនឆ្នាំក្នុងនាមជាជនរងគ្រោះនៃអំពើប្រល័យពូជសាសន៍ក្នុងប្រទេសកម្ពុជា ។ សៀវភៅរបស់គាត់គឺប្រវត្តិស្តីពីការលើកទឹកចិត្ត និងការប្តេជ្ញាចិត្តដែលប្រឈមនឹងការអត់ឃ្លាន និងការភ័យខ្លាច ។

**ផុះលេខ គូស័រ**

# ក្លាយជាខ្មែរក្រហមដោយមិនដឹងខ្លួន



រី ផល

ដោយសារតែរត់គេចពីសង្គ្រាម និងរត់គេចពីកងទ័ពវៀតណាមដែលវាយចូលប្រទេសកម្ពុជា នៅចុងឆ្នាំ១៩៧៨ រី ផល បានទៅចូលរួមជាមួយខ្មែរក្រហមដោយមិនដឹងខ្លួន។ ផល ចំណាយពេលអស់ជាច្រើនខែរស់នៅក្នុងព្រៃ ដោយគ្មានស្បៀងអាហារ និងទីជម្រក នៅមុនពេលគាត់ចាកចេញពីស្រុកកំណើតទៅតស៊ូតាមបណ្តោយព្រំដែនខ្មែរ-ថៃ។

ផល សព្វថ្ងៃមានអាយុ៥៣ឆ្នាំ មានស្រុកកំណើតនៅភូមិត្រពាំងក្រហម ឃុំត្រពាំងក្រហម ស្រុកកូនមុំ ខេត្តរតនគិរី។ ឪពុករបស់ ផល ស្លាប់ឆ្នាំ១៩៧៩ ពេលរត់គេចពីសង្គ្រាម និងម្តាយឈ្មោះ ម៉ៅ (ស្លាប់ឆ្នាំ១៩៨៥) និងបងស្រីម្នាក់ ដែលបានបែកគ្នានៅឆ្នាំ១៩៧៦។

ផល រៀនបានត្រឹមថ្នាក់ទីពីរនៅពេលខ្មែរក្រហមចូលមកគ្រប់គ្រង។ ក្រោយពីឈប់នៅឆ្នាំ ១៩៧៧ ខ្មែរក្រហមបានចាត់តាំងផល ឲ្យចូលកងកុមារនៅភូមិត្រពាំងក្រហម។ ខ្មែរក្រហមបានបែកឲ្យ ផល ធ្វើការទៅតាមរដូវ ដូចជា នៅរដូវវស្សាគាត់ត្រូវជញ្ជូនកណ្តាប់ឲ្យកងចល័តស្ទូង ហើយនៅ រដូវប្រូតជញ្ជូនស្រូវដាក់រទេះ។ ក្រៅពីនោះ ខ្មែរក្រហមឲ្យគាត់ជីកប្រឡាយ លើកទំនប់ជីកអណ្តូងទឹក ហើយពេលខ្លះគាត់ធ្វើរហូតដល់ម៉ោង១០យប់។ ខ្មែរក្រហមមិនអនុញ្ញាតឲ្យផលមកលេងផ្ទះទេគឺគាត់ត្រូវស្នាក់នៅកងកុមារ ហើយពេលដែលគាត់ចង់ទៅលេងឪពុកម្តាយម្តងៗទាល់តែគាត់ទៅសុំការអនុញ្ញាតពីប្រធានកងជាមុនសិន។

រហូតមកដល់ឆ្នាំ១៩៧៩ នៅពេលវៀតណាមវាយចូលមក ផល និងឪពុកម្តាយរបស់គាត់ បានរត់ភៀសខ្លួនពីផ្ទះទៅនៅក្នុងព្រៃ ខេត្តមណ្ឌលគិរី។ ផល បានធ្វើដំណើរដោយគ្មានគោលដៅជាមួយប្រជាជនបីគ្រួសារទៀត ក្រោមការដឹកនាំរបស់កងយោធាខ្មែរក្រហមនៅកងពល៨០១។ នៅពេលនោះ គ្រួសារ ផល បានដេកនៅក្រោមដើមឈើ ហើយហូបតែដំឡូង និងក្តួចប៉ុណ្ណោះ។ ដូច្នេះ ប្រជាជន ដែលមានមាសនៅជាប់នឹងខ្លួនបានលួចយកទៅដូរប្រជាជននៅក្នុងភូមិ យកអង្ករ និងអំបិលមកចែកគ្នាហូប។ ក្រោយមក មានប្រជាជនខ្លះបានកើតជំងឺគ្រុនចាញ់ ហើយនៅពេលនោះគឺ មានតែយកសម្បកស្តៅយកមកដាំទឹកផឹកដើម្បីព្យាបាលជំងឺប៉ុណ្ណោះ។

នៅឆ្នាំ១៩៧៩ ដដែល ផល បានបែកចេញពីឪពុកដែលក្រោយមកបានទទួលដំណឹងថា ស្លាប់។ នៅខែមិថុនា ឆ្នាំ១៩៨០ ផល និងម្តាយរបស់គាត់បានរត់ភៀសខ្លួនទៅស្រុកសៀមបូក ខេត្តស្ទឹងត្រែង។ នៅពេលយប់ ផល និងម្តាយ ព្រមទាំងប្រជាជនភៀសខ្លួនផ្សេងទៀតបានឆ្លងទន្លេមេគង្គសំដៅទៅខេត្តព្រះវិហារ។ នៅពេលនោះ មានប្រជាជនជាច្រើន បានស្លាប់ដោយសារអាកាសធាតុត្រជាក់ខ្លាំង ហើយអ្នកខ្លះទៀតទឹកបានកួចយកទៅបាត់។ បន្ទាប់ពីឆ្លងទន្លេរួច ផល និងម្តាយរបស់គាត់ធ្វើដំណើរកាត់តាមព្រៃរយៈពេល៣ខែទើបទៅដល់ទន្លេរពៅ។ នៅទីនោះ ផល បានសង់ខ្ទមស្នាក់នៅជាមួយម្តាយ និងទទួលជំនួយស្បៀងអាហារពីកងទ័ព។

ក្រោយមក ខ្មែរក្រហមបានជ្រើសរើស ផល ឲ្យចូលកងវរសេនាធំលេខ៨១ ដែលមាននារី ជ្រឿនជាអ្នកគ្រប់គ្រង។ ផល មានតួនាទីជញ្ជូនអង្ករ និងគ្រាប់កាំភ្លើងដោយថ្មើរជើងទៅឲ្យកងទ័ពខ្មែរក្រហម ដែលឈរជើងនៅអូរជុញ, របុញ ក្នុងខេត្តព្រះវិហារ។ នៅថ្ងៃខ្លះ ផល ត្រូវកងទ័ពវៀតណាមស្ទាក់ផ្លូវ ដូច្នេះគាត់ត្រូវរត់គេចខ្លួនទៅតាមយោធាខ្មែរក្រហមដែលនាំផ្លូវចូលទៅក្នុងព្រៃ។ នៅទីនោះ ផល បានរៀបការជាមួយប្តីឈ្មោះ អ៊ឹ នឿន ធ្វើជា

*យោធានៅកងវរសេនាធំ៨១ កងពល ៨០១ ជាមួយគាត់ដែរ ។ រហូតដល់ឆ្នាំ១៩៨៥ កងទ័ពវៀតណាមធ្វើការវាយលុកចូលមកខ្លាំងធ្វើឲ្យប្រជាជន ស្រ្តីឆ្លងទន្លេ និងគ្រួសារកងទ័ពស្លាប់ជាច្រើន និងមួយចំនួនទៀតស្លាប់ដោយសារជាន់មីន ។ ចំណែក ផល និងកូនព្រមទាំងម្តាយ បានរត់គៀសខ្លួនទៅនៅចំបក់កោង នៅក្នុងទឹកដីរបស់ថៃ ។ នៅទីនោះ ផល មានជីវភាពជាប្រជាជនសាមញ្ញ និងរស់នៅចល័តនៅក្នុងព្រៃ ។ រយៈពេលពីរខែក្រោយមក គឺនៅអំឡុងខែកុម្ភៈ ឆ្នាំ១៩៨៥ ម្តាយគាត់បានស្លាប់ដោយសារជំងឺ ។*

*នៅខែតុលា ឆ្នាំ១៩៨៥ ផល បានទៅរស់នៅជំរំអូរត្រាវ (ស្ថិតក្នុងទឹកដីរបស់ថៃ) ក្រោមការគ្រប់គ្រងរបស់ខ្មែរក្រហម ។ ផល បានសាងសង់ខ្ទមស្នាក់នៅក្នុងភូមិ៨១ ដែលមានយាយ រុន ជាអ្នកគ្រប់គ្រង ចំណែករបបអាហារគាត់ ទទួលបានការឧបត្ថម្ភពីតាម៉ុក និងអង្គការកាកបាទក្រហម ។*

*រហូតដល់ឆ្នាំ១៩៩២ ផល និងកូន បានចាកចេញពីជំរំមករស់នៅក្នុងទឹកដីតាមបណ្តោយជើងភ្នំក្នុងទឹកដីខ្មែរវិញ ដោយគាត់នៅកងចាស់ៗ ។ នៅក្នុងភូមិ ផល មានភារកិច្ចបិតចម្រូង ដែលមានប្រវែងបីតឹក ដោយរដ្ឋ (ខ្មែរក្រហម) កំណត់ឲ្យធ្វើក្នុងមួយខែបិទឲ្យបានចំនួន៥០០ចម្រូង ។ បន្ទាប់ពី ផល បិតរួច ទើបទាហានយោធាដើរប្រមូលនៅតាមផ្ទះ ។ ក្រៅពីការងារបិតចម្រូង ផល ត្រូវធ្វើស្រែ និងចម្ការបន្ថែមដើម្បីផ្គត់ផ្គង់ជីវភាព ។ ចំណែកការស្នាក់នៅគាត់ត្រូវចល័តទៅតាមកន្លែង ព្រោះនៅមានការវាយប្រយុទ្ធគ្នា ។*

*រហូតដល់ឆ្នាំ១៩៩៨ ពេលខ្មែរក្រហមធ្វើសមាហរណកម្មជាមួយរដ្ឋាភិបាល ទើប ផល មករស់នៅជាប្រជាជននៅភូមិទួលចារ ឃុំទំនប់ដាច់ ស្រុកត្រពាំងប្រាសាទ ខេត្តឧត្តរមានជ័យ ។ ចំណែក ប្តីរបស់គាត់ក្រោយមកត្រូវរដ្ឋាភិបាលរំសាយមកជាទាហានចូលនិវត្តន៍វិញ ។*

*សព្វថ្ងៃផល ប្រកបរបរ ធ្វើស្រែ និងចម្ការ និងមានកូនចំនួនប្រាំនាក់នៅក្នុងបន្ទុក ។ ផល បានមានប្រសាសន៍ថា គាត់បានបែកចេញពីស្រុកកំណើតរយៈពេលជាង៣០ឆ្នាំហើយ ចាប់តាំងពីគាត់ចូលរួមជាមួយចលនាតស៊ូខ្មែរក្រហម ហើយទើបតែរយៈពេលបីឆ្នាំកន្លងទៅនេះដែលគាត់បានជួបជាមួយបងរបស់គាត់វិញ ។ ដូច្នេះហើយ គាត់ចង់ទៅលេងស្រុកកំណើត ប៉ុន្តែដោយសារជីវភាពគាត់ខ្វះខាតទើបធ្វើឲ្យគាត់មិនអាចទៅបាន ។* **សោម ប៊ុនថន**



*ផ្លូវភ្ជាប់ពីឃុំទំនប់ដាច់ ទៅច្រកជប់រុន ក្នុងស្រុកត្រពាំងប្រាសាទ ខេត្តព្រះវិហារ*

# ការសោកស្តាយ និងសំណង


ឆឹង សារ៉េង

ឆឹង សារ៉េង អាយុ ៤៧ឆ្នាំ សព្វថ្ងៃជាកសិករ រស់នៅស្រុកភ្នំស្រួច ខេត្តកំពង់ស្ពឺ ។ សារ៉េង មានអាយុដប់ឆ្នាំប៉ុណ្ណោះពេលខ្មែរក្រហមឡើងកាន់អំណាច ។ កម្មាភិបាលខ្មែរក្រហមពុំអនុញ្ញាតឲ្យ សារ៉េង រស់នៅជាមួយឪពុកម្តាយទេ ហើយចាត់តាំងម្តាយរបស់គាត់ឲ្យចិញ្ចឹមដង្កូវនាងនិងបេះកប្បាស ។ ចំណែកឪពុករបស់គាត់ត្រូវធ្វើខាងសិប្បកម្ម ។ ក្រោយធ្វើរួច ឪពុកម្តាយគាត់ត្រូវបញ្ជូនរបស់ដែលផលិតបានទៅសហករណ៍ ។ ដោយឡែក សារ៉េង ខ្មែរក្រហមចាត់តាំងឲ្យធ្វើជាមេកងកងកុមារចល័ត ។ ពេលនោះការងារដែលត្រូវធ្វើ រួមមានកាប់ដីដំបូក, លើកបាវស្រូវដាក់ជង្រុក និងចិញ្ច្រាំដើមទន្ទ្រានខែត្រជាដើម ។ សារ៉េង ត្រូវក្រោកធ្វើការនៅម៉ោងបួនព្រឹក រហូតដល់ម៉ោង១១ ទើបឈប់សម្រាក និងចាប់ផ្តើមធ្វើបន្តនៅម៉ោងមួយរសៀល ។ គាត់ធ្វើការបែបនេះជារៀងរាល់ថ្ងៃ តែជួនកាលគាត់ចាប់ផ្តើមបន្តការងារពីម៉ោងប្រាំមួយល្ងាចដល់ម៉ោងប្រាំបួនយប់ក៏មាន ប្រសិនបើមានការរវល់បន្ថែម ។

សារ៉េង មានចិត្តរីករាយនៅពេលដែលគាត់មកមើលសវនាការពិភាក្សាដេញដោល និងបិទបញ្ចប់ការសន្និដ្ឋានសំណុំរឿង០០២/០១ វគ្គមួយកាលពីថ្ងៃ១៦ ខែតុលា ។

សារ៉េង យល់ថាការកាត់ក្តីរបស់តុលាការកាត់ក្តីខ្មែរក្រហមគឺមានគោលបំណងរកយុត្តិធម៌សម្រាប់ប្រជាជន ដែលថ្នាក់ដឹកនាំជាន់ខ្ពស់ក្នុងរបបខ្មែរក្រហមធ្វើបាប ។ សារ៉េង មិនអស់ចិត្តទេចំពោះការស្លាប់របស់ជនជាប់ចោទ ជាឧទាហរណ៍ អៀង សារី ដែលស្លាប់មុនការកាត់ក្តី ព្រោះគាត់មានទោសកំហុសច្រើនណាស់ ។

សារ៉េង ពុំបានយល់ពីទំហំនៃការកាត់ក្តីដល់កម្រិតណានោះទេ តែគាត់គិតថានេះជារឿងគួរឲ្យស្តាយ ។ សារ៉េង ក៏មានការអន់ចិត្តដែរនៅពេលជនជាប់ចោទ នួន ជា សុំសម្រាកពេលដំណើរការសវនាការសរុបសេចក្តីសន្និដ្ឋានបញ្ចប់ការដេញដោលក្នុងសំណុំរឿង ព្រោះថានេះជាលើកដំបូងសម្រាប់គាត់ដែលបានមកស្តាប់សវនាការ ហើយគាត់សង្ឃឹមថា នឹងបានឮពាក្យបកស្រាយរបស់ជនចាប់ចោទ ។

សារ៉េង បន្ថែមទៀតថា ចំពោះរឿងតុលាការស្រុកក្រៅមានអភ័យឯកសិទ្ធិនិងស្ថាប័នរបស់ខ្លួនផ្ទាល់ ពុំមានការជ្រៀតជ្រែកពីរដ្ឋាភិបាលទេ ។ តុលាការមានសិទ្ធិគ្រប់បែបយ៉ាងក្នុងការដាក់ទោសទៅលើបុគ្គលណាមួយ ដោយផ្អែកទៅលើភ័ស្តុតាងនៃការស្រាវជ្រាវ ។ សម្រាប់ សារ៉េង ក៏ដូចជាប្រជាជននិងប្រទេសកម្ពុជាផ្ទាល់ ការរកយុត្តិធម៌គឺមានសារសំខាន់ណាស់ ព្រោះប្រជាជនទាំងអស់សុទ្ធតែជាអ្នករងគ្រោះដោយសាររបបបីឆ្នាំនោះ ។ អ្នកដែលបង្កឲ្យរងគ្រោះបែបនេះ មានតែអ្នកដឹកនាំធំៗប៉ុណ្ណោះ ហើយប្រសិនបើអ្នកទាំងនោះពុំទទួលទោសនោះទេ គឺអាចនឹងមានឥទ្ធិពលអាក្រក់សម្រាប់អ្នកដឹកនាំក្រោយៗទៀត ។

សារ៉េង នឹងពុំអស់ចិត្តទេ ប្រសិនបើតុលាការពុំបានកាត់ក្តីជនឧក្រិដ្ឋទាំងនោះ ។ សំណងដែលជនជាប់ចោទគួរតែសងនោះ គឺទទួលទោសទណ្ឌទៅតាមអ្វីដែលគាត់បានធ្វើ ហើយសំណងទីពីរគឺជាសំណងសម្រាប់ប្រជាជនទាំងអស់ដែលគួរតែទទួលបានគ្រប់ៗគ្នា មានជាអាទិ៍គឺ សំណង់ ផ្លូវសាធារណៈ ឬក៏អ្វីផ្សេងទៀតដែលជាប្រយោជន៍ជាតិ ។ ជាការពិត អ្នកដែលបង្កឲ្យមានសោកនាដកម្មនោះឡើងមានច្រើនណាស់ តែប្រសិនបើយើងកាត់ទោសទាំងអស់គ្នានោះ នឹងអាចបង្កឲ្យមានភាពច្របូកច្របល់ ដូច្នេះ សារ៉េង សំណូមពរឲ្យតុលាការកាត់ទោសតែមេដឹកនាំជាន់ខ្ពស់ ព្រោះថាការដឹកនាំរបស់រដ្ឋាភិបាលក្នុងរបបខ្មែរក្រហមតម្រូវឲ្យកម្មាភិបាលទាំងអស់ធ្វើអំពើឃោរឃៅបែបនេះ ។ **ឆាយ ជាទីន**

# ជីវិតកសិករបស់ សួង ដុស ក្នុងរបបខ្មែរក្រហម

ប្រសិនបើយើងធ្វើដំណើរពីទីរួមខេត្តបាត់ដំបង ប្រហែល ២៨គីឡូម៉ែត្រ ឆ្ពោះទៅទិសខាងលិច យើងនឹងទៅដល់រមណីយដ្ឋានទេសចរណ៍ប្រវត្តិសាស្ត្រមួយគឺ អាងទឹកកំពីងពួយដែលបានសាងសង់នៅក្នុងរបប ប៉ុល ពត ។ ចេញពីអាងកំពីងពួយប្រវែង៧គីឡូម៉ែត្រ យើងនឹងទៅដល់ភូមិមួយនៅជាប់ជើងភ្នំ គឺភូមិអារ៉ៃ ឃុំតាក្រាម ស្រុកបាណន់ ខេត្តបាត់ដំបង ។ ពេលទៅដល់ទីនោះភ្លាម មានបុរសចំណាស់ម្នាក់កំពុងអង្គុយជីកទឹកតែនៅក្រោមផ្ទះឈើសង់ជាប់ជើងភ្នំ ខ្ញុំក៏បានចូលសំណេះសំណាល និងសាកសួរពីប្រវត្តិរបស់គាត់ ។ គាត់មានឈ្មោះ សួង ដុស ជាអតីតទាហានលន់ នល់ ដែលបានរួចរស់ជីវិតពីរបបខ្មែរក្រហម ។

ដុស បានរៀបរាប់ថា គាត់មានអាយុ៧៥ឆ្នាំ មានប្រពន្ធនិងកូនពីរនាក់រស់នៅជាមួយ ។ គាត់មានស្រុកកំណើតនៅភូមិថ្នល់ដាច់ ឃុំក្រាំងលាវ ស្រុកបាទី ខេត្តតាកែវ ។ កាលពីតូច គាត់រស់នៅជាមួយឪពុកម្តាយ រហូតដល់ឆ្នាំ១៩៥២ គាត់បានទៅបួសជាព្រះសង្ឃបានរយៈពេលពីរវស្សា នៅវត្តអង្គជុំ ទើបលាសឹកមកជាគ្រហស្ថវិញ ។ បន្ទាប់មក គាត់បានចូលរៀននៅសាលាវត្តដល់ថ្នាក់មធ្យមដ្ឋានទីពី (ចប់មធ្យមដ្ឋាន គឺឧត្តមដ្ឋាន) ក៏ឈប់ រួចហើយបានទៅនៅខេត្តពោធិ៍សាត់ជាមួយឪពុក ។ គាត់បានរស់នៅខេត្តពោធិ៍សាត់បានមួយឆ្នាំ ទើបផ្លាស់ទៅនៅឃុំតាក្រាម ស្រុកបាណន់ ខេត្តបាត់ដំបងវិញ នៅក្នុងអំឡុងឆ្នាំ ១៩៥៨ ។

ដុស បាននិយាយថា នៅអំឡុងឆ្នាំ១៩៧០ ប្រជាជនមានទំនោរពីរ គឺមួយមានទំនោរទៅរករដ្ឋាភិបាល ចំណែកមួយទៀត



អាងកំពីងពួយ ដែលមានចម្ងាយប្រមាណ២៨គីឡូម៉ែត្រពីទីរួមខេត្តបាត់ដំបង



ជុំ ម៉ាប់ (រូបខាងឆ្វេង) និង សួង ជុស

មានទំនោរប្រឆាំងរដ្ឋាភិបាល (មានទំនោរទៅរកខ្មែរក្រហម) ។ គាត់បានបញ្ជាក់ថា «អ្នកណាគាំទ្រខ្មែរក្រហមត្រូវចូលធ្វើជាយោធាខ្មែរក្រហម ជួយខ្មែរក្រហម ចំណែកអ្នកគាំទ្រ លន់ នល់ គឺរត់ចូលធ្វើទាហាន លន់ នល់» ។ នៅអំឡុងឆ្នាំ១៩៧០ ជុស មានអាយុ៣១ឆ្នាំ គាត់បានសម្រេចចិត្តចូលធ្វើជាទាហានរដ្ឋាភិបាល លន់ នល់ ដោយទទួលបានប្រាក់ខែគោល៧.០០០រៀល ក្នុងមួយខែ ។ នៅពេលនោះ គាត់បានឡើងប្រយុទ្ធជាមួយទាហានខ្មែរក្រហមជាច្រើនសមរភូមិ ដោយគាត់មានតួនាទីជាមេកងគ្រប់គ្រងទាហាន១០០នាក់ ។ ពេលគាត់ឡើងទៅប្រយុទ្ធម្ដងៗ គាត់តែងតែទាក់ទងទ័ពអាកាសមកទម្លាក់គ្រាប់បែកមុន ដើម្បីឲ្យទាហានខ្មែរក្រហមបាក់ទ័ព ធ្វើឲ្យគាត់មានភាពងាយស្រួលក្នុងការវាយយកជ័យជម្នះ ។ គាត់បានបន្តថា «ការទម្លាក់គ្រាប់នោះ បណ្ដាលឲ្យខូចខ្ទីផ្ទះសម្បែង និងផ្សារដែលស្ថិតនៅតាមបណ្ដោយផ្លូវជាតិលេខ៥ ។ ប៉ុន្តែការវាយប្រហារ ភាគច្រើនកងរបស់គាត់នៅពេលនោះក៏ទទួលបរាជ័យដែរ ។

គាត់បានលើកឡើងអំពីកត្តាមួយចំនួនដែលធ្វើឲ្យទាហានរបស់រដ្ឋាភិបាលបរាជ័យ ដោយសារតែកងទ័ព លន់ នល់ ខ្វះបទពិសោធ មិនស្គាល់ទីតាំងភូមិសាស្ត្រ និងការវាយឆ្មក់ពីសំណាក់ខ្មែរក្រហម ។ ម្យ៉ាងវិញទៀត ប្រជាជនមិនពេញចិត្តនឹងយន្តហោះរបស់រដ្ឋាភិបាលដែលទម្លាក់គ្រាប់បែកបំផ្លាញផ្ទះសម្បែង និងឈឺចាប់ចំពោះការស្លាប់ និងរបួសរបស់សមាជិក ឬសាច់ញាតិដោយសារការទម្លាក់គ្រាប់បែកនេះ ។ គាត់បានបន្ថែមថា «ប្រជាជនភាគច្រើនបានគាំទ្រ សម្ដេច សីហនុ ហើយបើកុំមានរដ្ឋប្រហារទម្លាក់ព្រះអង្គ នោះខ្មែរក្រហមនឹងគ្មានថ្ងៃឈ្នះទេ» ។

ជាការពិត សម្ដេច សីហនុ គឺជាបុគ្គលដែលមានប្រជាប្រិយភាពនិងឥទ្ធិពលម្នាក់ដែលមានប្រជាជនគោរពស្រឡាញ់យ៉ាងខ្លាំង ទាំងនៅក្នុងប្រទេស និងនៅក្រៅប្រទេស ។ ប្រជាជនគិតថា ប្រសិនបើ សម្ដេច សីហនុ ត្រឡប់មកវិញ នោះប្រទេសនឹងមានសន្តិភាព ដូចកាលពីសម័យសង្គមរាស្ត្រនិយមមិនខាន ។

ជុស បានបន្តថា នៅក្នុងសមរភូមិពន្លៃ យន្តហោះរបស់រដ្ឋាភិបាលបានទម្លាក់គ្រាប់បែកចំផ្សារ បណ្ដាលឲ្យខូចខាតយ៉ាងដំណំ ។ ប៉ុន្តែនៅសមរភូមិពន្លៃនោះ និងនៅត្រពាំងចន្ទ កងទ័ពរបស់ លន់ នល់ ក៏បានស្លាប់ច្រើនដែរ ។ ពេលនោះគាត់ទទួលបញ្ជាឲ្យទៅជួយគាំទ្រ ហើយវាយបើកផ្លូវដើម្បីជួយសង្គ្រោះទាហាននៅក្នុងបន្ទាយត្រពាំងច័ន្ទ ។ គាត់បានចំណាយពេលអស់ពីរថ្ងៃទើបវាយបាន ប៉ុន្តែទាហាននៅក្នុងនោះបានស្លាប់អស់ទៅហើយ ហើយសាកសពទាហានមួយចំនួនស្អុយរលួយ ។ លុះក្រោយមកគាត់បានទៅការពារស្រុកបរិបូរណ៍ ដើម្បីកុំឲ្យខ្មែរក្រហមចូលមក តែត្រូវបរាជ័យ ។ ដូច្នេះហើយ ទើបគាត់ត្រូវបានផ្លាស់ឲ្យទៅសាលាលេខ៥ រួចហើយហួសទៅដល់ហែករមាស ដែលនៅទីនោះត្រូវយោធាខ្មែរក្រហមព័ទ្ធជាប់ ។ ពេលនោះ គាត់បានតេអូហៅកងទ័ពប៉ារ៉ាមកជួយអន្តរាគមន៍ ប៉ុន្តែគ្រាន់តែចុះពីយន្តហោះភ្លាម ក៏ត្រូវយោធាខ្មែរក្រហមព័ទ្ធបាញ់សម្លាប់ទាំងអស់ នៅរស់តែបីនាក់តែប៉ុណ្ណោះ ។

កងរបស់ ជុស មិនមានបន្ទាយទេ គឺគាត់ដើរវាយចល័ត

ដែលនៅពេលនោះមានពីរក្រុមគឺ ក្រុមក្បាលខ្វា និងក្រុមក្បាលខ្មោចដែលមានមេកងឈ្មោះ ហង្ស និង ចិន នារី តែអ្នកទាំងពីរនាក់បានស្លាប់ក្នុងសមរភូមិពេលប្រយុទ្ធជាមួយយោធាខ្មែរក្រហម ។

រហូតដល់ឆ្នាំ១៩៧៣ ដុស ត្រូវយោធាខ្មែរក្រហមចាប់ខ្លួនគាត់បាននៅស្រុកមេមត់ តែខ្មែរក្រហមមិនបានសម្លាប់គាត់ទេ ។ ខ្មែរក្រហមបានយកគាត់ទៅឃុំនៅកន្លែងមួយ ដោយដាក់ខ្នោះជើងដែលបន្សល់ស្លាកស្នាមរហូតមកដល់សព្វថ្ងៃ ។ ក្រោយមក ទើបខ្មែរក្រហមដោះលែងគាត់វិញ ។

ក្រោយថ្ងៃរំដោះ ថ្ងៃ១៧ ខែមេសា ឆ្នាំ១៩៧៥ ដុស ត្រូវខ្មែរក្រហមនាំទៅនៅសហករណ៍ ដោយប្រាប់ថាទៅធ្វើផ្ទះ ប៉ុន្តែបែរជានាំគាត់ទៅឃុំឃាំងនៅបន្ទាយគោលទៅវិញ ។ គាត់បានបញ្ជាក់ថាបន្ទាយគោល នៅក្នុងស្រុកបាកាន ខេត្តពោធិ៍សាត់ (ធ្វើដំណើរពីភ្នំពេញនៅហួសផ្សារត្រពាំងជង ហើយនៅខាងឆ្វេងដៃ) ។ គាត់និយាយថា នៅទីនេះ មានមនុស្សស្លាប់ច្រើនណាស់ ។ គាត់ឃើញខ្មែរក្រហមនាំទាហានទាំងខ្សែៗ ដោយក្នុងមួយខ្សែមានទាហានប្រមាណពី២០-៣០នាក់ យកទៅសម្លាប់នៅកន្លែងមួយ ដែលមានចម្ងាយប្រមាណ៤០០ម៉ែត្រពីបន្ទាយគោល ។ អ្នកដែលស្លាប់ភាគច្រើនជាសិស្ស និស្សិត មន្ត្រីរាជការ និងគ្រូបង្រៀន ។ ចំណែកដុស បានរួចរស់ជីវិត ក៏ដោយសារភ័ព្វសំណាងគាត់ ព្រោះដំបូងខ្មែរក្រហមយកគាត់ទៅឃុំ ហើយបង្ខំឲ្យគាត់ធ្វើពលកម្មធ្ងន់ធ្ងរ និងមិនឲ្យចំណីអាហារហូបឆ្អែតទេ ។ មួយព្រឹក ខ្មែរក្រហមកំណត់ឲ្យគាត់កាប់រណ្តៅដាំដូងឲ្យបាន១០០ដើម ហើយពេលនោះ ដោយចុងភៅឃើញគាត់ធ្វើការសកម្មជាងគេ ក៏លួចយកបាយឲ្យហូប ។ ចាប់ពីពេលនោះ គាត់បានខិតខំធ្វើការងារមិនឈប់ ទើបក្រោយមក កម្មាភិបាលខ្មែរក្រហមដោះលែងគាត់ ។

បន្ទាប់មក ដុស បានទៅនៅសហករណ៍ភូមិព្រាល ឃុំព្រះម្លូ ស្រុកបាកាន ដោយនៅទីនោះគាត់ទទួលបានរបបអាហារហូបគ្រប់គ្រាន់ ។ លុះនៅទីនោះរយៈពេលបីខែ ខ្មែរក្រហមបានផ្លាស់គាត់ឲ្យទៅនៅខាងជាងធ្វើផ្ទះ ។ ក្រោយមក មានកម្មាភិបាលពីរនាក់ គឺ មិត្តខន និង មិត្តគន់ បាននាំគាត់ទៅយកឃ្មុំ ។ ពេលដើរទៅក្នុងព្រៃគាត់ក៏ឃើញដើមឈើមួយធំ និងមានកម្ពស់ប្រមាណ២៥ម៉ែត្រ និងមានសំបុកឃ្មុំធំមួយ ។ ពេលនោះ ដុស បានគិតថា កម្មាភិបាលទាំងពីរនេះនឹងសម្លាប់បើគាត់បដិសេធ ហើយប្រសិនបើគាត់ឡើងយកឃ្មុំនោះ អាចត្រូវឃ្មុំទិច ឬក៏ធ្លាក់ប៉ុណ្ណោះ ។ ដូច្នេះហើយ ទើបគាត់សម្រេចចិត្តថាត្រូវតែប្រថុយឡើង ។

ដុស បានទម្លាក់ទឹកមុខ ហើយនិយាយថា “ភ័យខ្លាំងណាស់ព្រោះមួយជីវិតគាត់មិនដែលយកឃ្មុំទេ” ។ បន្ទាប់ពីនិយាយរួចគាត់យកគុបភ្លើងចងជាប់នឹងចង្កេះ រួមជាមួយធុងមួយសម្រាប់ដាក់ទឹកឃ្មុំ ។ ពេលឡើងដល់ គាត់ក៏កាត់ផ្ទិតទម្លាក់ ហើយត្រងយកក្បាលទឹកចុះមកវិញ ។

ក្រោយមកខ្មែរក្រហមបានផ្លាស់គាត់ឲ្យទៅធ្វើការនៅកងនេសាទ ហើយក្រោយមកបានចាត់តាំងឲ្យធ្វើជាមេកងភ្ជួរស្រែ ។ ប៉ុន្តែដោយសារខ្វះខាតអាហារខ្លាំង គាត់បានចាប់ក្តាម ខ្យង ហូបទាំងឆៅ ។ រៀងរាល់ថ្ងៃ គាត់ស្លៀកពាក់ខោអាវមួយបន្ទាស់ប៉ុណ្ណោះទាំងធ្វើការទាំងដេក ។ ពេលត្រឡប់មកធ្វើការវិញ គាត់ដេកទាំងមិនងូតទឹកដោយសារតែអស់កម្លាំង ។ នៅពេលកំពុងធ្វើការ ហើយគាត់ឈប់សម្រាក ក៏មានកម្មាភិបាលក្មេងៗយកដុំដីគប់ក្បាលប្រាប់ឲ្យធ្វើការវិញដែរ ។

គាត់បានរៀបរាប់ថា “មេកង និង កម្មាភិបាលដែលធ្លាប់ធ្វើបាបប្រជាជន ត្រូវបានប្រជាពលរដ្ឋដេញស្ទាក់វាយ ក្រោយពេលរំដោះ ថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩ ។ ក្រោយឆ្នាំ១៩៧៩ ដុស បានចូលនៅក្នុងកងទ័ពរបស់រដ្ឋាភិបាលភ្នំពេញវិញ ។

ដុស បាត់បង់សមាជិកគ្រួសារ និងសាច់ញាតិ៥នាក់ គឺ ទី១) ចន្ទឌី ត្រូវជាកូនស្លាប់ដោយសារអត់អាហារ ។ ទី២) ទ្រី ម៉ាន ត្រូវជាបងថ្លៃ ធ្វើគ្រូបង្រៀន ខ្មែរក្រហមនាំយកទៅសម្លាប់ ។ ទី៣) សេង ប៊ិន (ប្រពន្ធរបស់ ទ្រី ម៉ាន) ជាប្អូនស្រីបង្កើតធ្វើគ្រូបង្រៀន ខ្មែរក្រហមយកទៅសម្លាប់ ។ ទី៤) សំអាត (កូនរបស់ ទ្រី ម៉ាន) ជាសិស្ស ។ ទី៥) ស៊ុយ ត្រូវជាបងប្អូនជីដូនមួយខ្មែរក្រហមយកទៅសម្លាប់ចោទថា មិនស្មោះត្រង់នឹងអង្គការ និងទី៦) ភោរ (ត្រូវជាតា) ខ្មែរក្រហមយកទៅសម្លាប់ដោយបានចោទថា ធ្វើពុតជាឈឺ ។

ចុងក្រោយគាត់បានសំណូមពរឲ្យមានការទប់ស្កាត់កុំឲ្យរបបនេះវិលមកវិញម្តងទៀត ព្រោះគាត់មិនចង់ឲ្យកូនចៅជំនាន់ក្រោយលំបាកដូចគាត់ទេ ។ **ឌី ម៉ាប់**

# ពិធីចែកសៀវភៅប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ ដល់សិស្សវិ











# វិទ្យាល័យក្រចេះក្រុង និង ព្រះកុសុមៈ ថ្ងៃទី៥ ខែមីនា ឆ្នាំ២០១៤











# ការរៀបចំសំណង ការប្រឈមរបស់ ដើមបណ្តឹងរដ្ឋប្បវេណីក្នុងសំណុំរឿង០០២

**(តចប់)**

តុលាការព្រហ្មទណ្ឌអន្តរជាតិយល់ឃើញថាដំណើរការផ្តល់សំណងស្ថិតនៅក្នុងអាណត្តិរបស់តុលាការ ។ តុលាការព្រហ្មទណ្ឌអន្តរជាតិបានលើកឡើងនៅក្នុងសំណុំរឿង ឡូបានហ្គា ថា កិច្ចដំណើរនីតិវិធីផ្តល់សំណង គឺជាផ្នែកមួយនៃដំណើរការសវនាការទាំងស្រុង ។ ដូច្នេះហើយ តុលាការព្រហ្មទណ្ឌអន្តរជាតិមានភាពប្រាកដប្រជាថា ការត្រួតពិនិត្យដំណើរការនោះដោយតុលាការមានសារសំខាន់ដើម្បីធានាថា សំណងនៅតែអនុលោមតាមការបង្គាប់ និងអាណត្តិរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិ ។ ក្រៅពីនេះថ្មីបើមានការសន្សាអំពីការត្រួតពិនិត្យមើលរបស់តុលាការមួយចំនួននោះ ការផ្ទេរតួនាទីផ្នែកតុលាការទៅមូលនិធិសំណងជនរងគ្រោះ ព្រមទាំងការត្រួតពិនិត្យមើលសំណងតាមរយៈអង្គជំនុំជម្រះដែលបង្កើតឡើងថ្មីនេះ បច្ចុប្បន្ន កំពុងត្រូវប្តឹងខទូរណ៍នៅតុលាការព្រហ្មទណ្ឌអន្តរជាតិ ។ ទាំងជនរងគ្រោះ និងក្រុមមេធាវីការពារក្តីបានជំទាស់ ដោយថ្លែងថា ដើម្បីបំពេញអាណត្តិរបស់ខ្លួនដោយជោគជ័យ និងដើម្បីផ្តល់សំណងសមស្រប អង្គជំនុំជម្រះដដែល ត្រូវតែត្រួតពិនិត្យមើលដំណើរការផ្តល់សំណង ។ ទន្ទឹមពេលដែលអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដែលជាតុលាការពិសេសនោះមានអាណត្តិផ្សេងគ្នាពីតុលាការព្រហ្មទណ្ឌអន្តរជាតិ ហើយខ្លួននឹងបញ្ឈប់តួនាទីនោះ អាណត្តិសំណងតុលាការគឺតួនាទីមួយក្នុងចំណោមតួនាទីដ៏សំខាន់របស់ខ្លួន ។

មានការរារាំងផ្នែកផ្លូវច្បាប់ដល់អង្គជំនុំជម្រះវិសាមញ្ញក្នុង



អ្នកភូមិចូលរួមវេទិកាសាធារណៈ នៅខេត្តស្ទឹងត្រែង

តុលាការកម្ពុជា ដែលបន្តត្រួតពិនិត្យដំណើរការផ្តល់សំណង ទោះបីជាមានការព្រួយបារម្ភជាក់ស្តែងជាច្រើនយ៉ាងណាក៏ដោយ ។ មិនមានថវិកាច្រើនណាស់ណាដែលត្រូវបានទាមទារធ្វើឲ្យតុលាការដំណើរការនោះទេ ។ ដោយអនុលោមតាមមាត្រា៤៧នៃច្បាប់បង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជានឹងត្រូវបានរំលាយចោល បន្ទាប់ពីបញ្ចប់ដំណើរការនីតិវិធីរបស់ខ្លួន ។ វាមិនច្បាស់លាស់ទាល់តែសោះដែលការបញ្ចប់ត្រូវបានកំណត់ ។ វាហាក់បីដូចជាមិនអាចស្នើឲ្យតុលាការបកស្រាយសេចក្តីសន្និដ្ឋាន នៅពេលដែលមានការបញ្ចប់ការអនុវត្តសំណង ជាពិសេសការត្រួតពិនិត្យមើលគម្រោងសំណង ។ វិធានផ្ទៃក្នុងមិនបានផ្តល់ការចង្អុលបង្ហាញថាតើអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា អាចដើរតួនាទីក្នុងការត្រួតពិនិត្យមើលសំណង ។ ដូចដែលតុលាការព្រហ្មទណ្ឌអន្តរជាតិបានលើកឡើង «កិច្ចដំណើរការនីតិវិធីផ្តល់សំណង គឺជាផ្នែកខាងក្នុងនៃដំណើរការជំនុំជម្រះទាំងមូល» ។ តុលាការព្រហ្មទណ្ឌអន្តរជាតិយល់ឃើញថា ការត្រួតពិនិត្យ និងការគ្រប់គ្រងសំណងស្ថិតនៅក្នុងការទទួលខុសត្រូវ និងតួនាទីរបស់តុលាការ ។

វិធានផ្ទៃក្នុងបានផ្តល់ការចង្អុលបង្ហាញលើការជំរុញសេចក្តីសម្រេចរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា លើកលែងតែគម្រោងផ្តួចផ្តើមនៃសំណងដែលបានផ្តល់ថវិកាពីខាងក្រៅ ។ សំណងដែលជនជាប់ចោទអាចរ៉ាប់រងបាន ត្រូវតែធ្វើឡើងដោយអាជ្ញាធរជាតិដ៏សមស្រប ដោយអនុលោមតាមច្បាប់ប្រទេសកម្ពុជា ។ នៅក្នុងសំណុំរឿង០០១ អង្គជំនុំជម្រះតុលាការកំពូលបាននិយាយថា តុលាការក្នុងស្រុកនឹងផ្តល់ការគាំទ្រដល់ការបង្គាប់សំណងរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ប្រឆាំងទៅនឹងជនជាប់ចោទ ដែលស្រដៀងគ្នាទៅនឹងការបង្គាប់សំណងដទៃដោយតុលាការក្នុងស្រុក ។ ទោះបីជាយ៉ាងណាក៏ដោយ គម្រោងសំណងស្ថិតនៅឆ្ងាយពីក្របខ័ណ្ឌនេះ ហើយមិនបានបង្កឲ្យមានការផ្តល់សំណងនោះឡើយ ។ វិធានផ្ទៃក្នុងមិនបានផ្តល់ព័ត៌មានថាតើដើមបណ្តឹងរដ្ឋប្បវេណីអាចធ្វើការទាមទារសំណង បន្ទាប់ពីអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាបានបញ្ចប់ ហើយវិធានផ្ទៃក្នុងនោះមិនបានផ្តល់ការចង្អុលបង្ហាញអំពីរបៀបដែលធានាថា ដើមបណ្តឹងរដ្ឋប្បវេណីនឹងទទួលបានអត្ថប្រយោជន៍នៃគម្រោងសំណងដែលបង្គាប់ដោយតុលាការ ។ មធ្យោបាយមួយដើម្បីធានាថា សំណងមានលក្ខណៈសំខាន់ ហើយមានប្រសិទ្ធភាពនោះ គឺត្រូវផ្តល់ឲ្យមានការត្រួតពិនិត្យរបស់តុលាការ ទាំងតាមរយៈអង្គជំនុំជម្រះដែលបង្កើតឡើងនាពេលបច្ចុប្បន្ន ឬអង្គជំនុំជម្រះដោយឡែកនៅក្នុងដំណើរការអនុវត្តសំណង ។ សូម្បីតែសំណងជាក់លាក់បំផុតនឹងបង្កឲ្យមានបញ្ហានៅពេលដែលសំណងជាក់លាក់នោះត្រូវបានអនុវត្ត ។

*ឃ) ជម្រើសទីពី ដោយផ្អែកលើអ្វីដែលធ្លាប់មាន ដែលបង្កើតឡើងដោយគណៈកម្មាធិការស្វែងរកការពិត និងផ្សះផ្សា តុលាការអាចស្នើឲ្យមានការបង្កើតគណៈកម្មាធិការត្រួតពិនិត្យរួមមាន រដ្ឋាភិបាល, អង្គការក្រៅរដ្ឋាភិបាល និងសង្គមស៊ីវិល ដើម្បីគ្រប់គ្រងគម្រោងសំណង ។*

ប្រសិនបើអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាពិបាកបង្កើតអង្គភាពផ្លូវច្បាប់ដើម្បីត្រួតពិនិត្យមើលអំពីការអនុវត្តសំណង តុលាការគួរតែស្នើឲ្យមានការបង្កើតគណៈកម្មាធិការទាំងក្នុងវង្វង់រដ្ឋាភិបាល ឬគ្រប់គ្រងដោយសង្គមស៊ីវិលចម្រុះ ដើម្បីត្រួតពិនិត្យមើលគម្រោងសំណង ។ សមាជិកគណៈកម្មាធិការស្វែងរកការពិត និងផ្សះផ្សាមួយចំនួនបានគ្រប់គ្រងសំណងតាមរយៈអង្គភាពដទៃ បន្ទាប់ពីគណៈកម្មាធិការបានបញ្ចប់តួនាទីរបស់ខ្លួន ។ ក្នុងសំណុំរឿងមួយចំនួន អង្គភាពគ្រប់គ្រងមួយចំនួនរួមមាន



គ្រួសារជនជាតិកាវ៉ែត

គណៈកម្មាធិការត្រួតពិនិត្យ ដែលមានផ្នែករដ្ឋាភិបាល, ជនរងគ្រោះ និងសម្ព័ន្ធមិត្តអង្គការក្រៅរដ្ឋាភិបាល ។ រដ្ឋាភិបាលមួយចំនួនដូចគ្នាទៅនឹងរដ្ឋាភិបាល ប្រទេសសេរ៉ាឡេអូន បានព្យាយាមបង្កើតមូលនិធិសំណង ដើម្បីផ្តល់ថវិកា និងត្រួតពិនិត្យមើលគម្រោងសំណងរយៈពេលវែង ។ ទោះបីជាយ៉ាងណាក៏ដោយ មូលនិធិសំណងជនរងគ្រោះ ទំនងជាខ្វះខាតថវិកា ។ ដោយមិនមានការគាំទ្រពីរដ្ឋាភិបាលក្នុងស្រុក រួមមាន ការគាំទ្រផ្នែកហិរញ្ញវត្ថុសម្រាប់គម្រោងសំណង កម្មវិធីផ្តល់សំណងជារឿយៗនៅតែខ្វះថវិកា ។ ប្រសិនបើរដ្ឋាភិបាលកម្ពុជាដើរតាមលម្អានរបស់ប្រទេសដែលងើបចេញពីជម្លោះ ហើយបង្កើតស្ថាប័នរដ្ឋាភិបាលដើម្បីត្រួតពិនិត្យមើលសំណង ព្រមទាំង ដើម្បីគ្រប់គ្រងថវិកាបដិភាគរបស់រដ្ឋាភិបាលនៅក្នុងកម្មវិធីផ្តល់សំណង គណៈកម្មាធិការត្រួតពិនិត្យ អាចជួយគុលាការក្នុងការគ្រប់គ្រងមូលនិធិសំណង ។

ប្រទេសប៉េរូ ប្រទេសសេរ៉ាឡេអូន ប្រទេសម៉ារ៉ុក និងប្រទេសហ្គាតេម៉ាឡា បានជ្រើសរើសជម្រើសផ្សេងសម្រាប់គ្រប់គ្រងកម្មវិធីសំណង ។ បទពិសោធរបស់ប្រទេសទាំងនោះផ្តល់ព័ត៌មានយ៉ាងសំខាន់ដល់ភាពខ្លាំង និងភាពខ្សោយនៃក្របខ័ណ្ឌរបស់ស្ថាប័នផ្សេងៗគ្នា ។ ប្រទេសម៉ារ៉ុក បានផ្តល់គំរូយ៉ាងល្អបំផុតអំពីតួអង្គពាក់ព័ន្ធរបស់រដ្ឋាភិបាល និងផ្នែកផ្សេងនៃសង្គមស៊ីវិល ។ ម្យ៉ាងវិញទៀត ប្រទេសហ្គាតេម៉ាឡាបង្ហាញនូវភាពលំបាករបស់ខ្លួននៅក្នុងការសម្របសម្រួលភាគីសង្គមស៊ីវិល ។ ទោះបីជាយ៉ាងណាក៏ដោយ ប្រទេសទាំងបួនបានបង្កើតស្ថាប័នជាតិដើម្បីត្រួតពិនិត្យ គ្រប់គ្រង និងជួយអនុវត្តកម្មវិធីសំណង ។ ក្រៅពីនេះ ប្រទេសទាំងបួនបានទទួលអត្ថប្រយោជន៍ពីច្បាប់ដែលបានអនុម័ត ដើម្បីបង្កើតឲ្យមានកម្មវិធីសំណង និងការគាំទ្ររបស់រដ្ឋាភិបាល ទោះបីជាមិនជានិច្ចជាកាលនាំមកជាមួយនឹងការគាំទ្រផ្នែកហិរញ្ញវត្ថុសម្រាប់កម្មវិធីសំណង ។

សំណុំរឿងរបស់ប្រទេសហ្គាតេម៉ាឡា បានក្រើនរំឭកអំពីចំណាប់អារម្មណ៍របស់សង្គមស៊ីវិល និងតម្រូវការសម្រាប់ការត្រួតពិនិត្យ និងការគ្រប់គ្រងដើម្បីដោះស្រាយកាត់សេចក្តីលើជម្លោះនៅពេលដែលជម្លោះទាំងនោះបានកើតឡើងក្នុងចំណោមភាគីផ្សេងៗ ដែលជាប់ពាក់ព័ន្ធនៅក្នុងការអនុវត្តសំណង ។ ប្រទេសហ្គាតេម៉ាឡា បានបង្កើតគណៈកម្មាធិការសំណងជាតិ ដែលស្រដៀងទៅនឹងគណៈកម្មាធិការសំណងជាតិរបស់ប្រទេសប៉េរូ ។ គណៈកម្មាធិការរួមមានសមាជិកមកពីរដ្ឋាភិបាល និងសង្គមស៊ីវិល ។ ទោះបីជាយ៉ាងណាក៏ដោយ អ្នកតំណាងសង្គមស៊ីវិលរបស់គណៈកម្មាធិការ រួមមានក្រុមសិទ្ធិមនុស្ស និងក្រុមជនជាតិភាគតិច ដែលមានជម្លោះជាមួយគ្នាលើបញ្ហាមួយចំនួន ។ បច្ចុប្បន្ន អ្នកតំណាងមកពីខាងរដ្ឋាភិបាលបានបម្រើការនៅក្នុងគណៈកម្មាធិការ ។ ប្រទេសប៉េរូ ប្រទេសម៉ារ៉ុក និងប្រទេសសេរ៉ាឡេអូន មានភាពជោគជ័យក្នុងការនាំយកភាគីផ្សេងៗមកធ្វើកាងាររួមគ្នាក្នុងកម្មវិធីសំណង ។

ប្រទេសប៉េរូបានបង្កើតគណៈកម្មាធិការស្វែងរកការពិត និងផ្សះផ្សា ដើម្បីសម្លឹងមើលការរំលោភបំពានសិទ្ធិមនុស្សធ្ងន់ធ្ងរ ដែលប្រព្រឹត្តឡើងក្នុងអំឡុងពេលជម្លោះ ដោយប្រដាប់អាវុធរយៈពេល ២០ឆ្នាំ ។ ក្នុងឆ្នាំ២០០៣ នៅពេលដែលបញ្ចប់ការងាររបស់ខ្លួនគណៈកម្មាធិការស្វែងរកការពិត និងការផ្សះផ្សា បានផ្តល់អនុសាសន៍ដល់គម្រោងសំណងយ៉ាងទូលំទូលាយ ។ ក្នុងឆ្នាំ២០០៥ រដ្ឋាភិបាលប្រទេសប៉េរូបានអនុម័តអនុសាសន៍នៃសំណងមួយចំនួនឲ្យទៅជាច្បាប់ ។ ជាងនេះទៅទៀត បទបញ្ញាធ្វើឡើងនៅក្នុងឆ្នាំ២០០៦ ដែលរួមមានការពិពណ៌នាលម្អិតអំពីកម្មវិធីសំណង ។ រដ្ឋាភិបាលបានដាក់ស្ថាប័នជាតិឲ្យទទួលខុសត្រូវក្នុងការបង្កើត, អនុវត្ត និងគ្រប់គ្រងគម្រោងសំណងតាមរយៈរដ្ឋាភិបាល ។ ស្ថាប័នជាតិមានអ្នកតំណាងខាងរដ្ឋាភិបាលចំនួន១០នាក់ មកពីភ្នាក់ងារដែលជាប់ពាក់ព័ន្ធ និងអ្នកតំណាងសង្គមស៊ីវិលបួនរូប រួមមានពីរនាក់មកពីអង្គភាពរបស់ជនរងគ្រោះ ។ ស្ថាប័នជាតិបានផ្តល់អនុសាសន៍ដល់ប្រធានាធិបតីប្រទេសប៉េរូចំពោះផែនការសំណងសមូហភាព ហើយស្ថាប័នជាតិនោះ ទទួលបន្ទុកគ្រប់គ្រងគោលនយោបាយរដ្ឋាភិបាល និងចំណាត់ការលើសំណង ។

សម្រាប់រយៈពេល២ឆ្នាំដំបូង ផលប៉ះពាល់របស់ស្ថាប័នជាតិកើតឡើងដោយសារតែថវិកាមានកំណត់ ហើយមិនអាចសម្របសម្រួលរវាងភ្នាក់ងាររដ្ឋាភិបាល និងអង្គការក្រៅរដ្ឋាភិបាល ហើយជួបផលវិបាកស្វែងរកការសហការពីរដ្ឋាភិបាលក្នុងតំបន់ ។ ស្ថាប័នរដ្ឋបានផ្តល់សច្ចាប័នលើក្របខណ្ឌចូលរួមជាមួយសហគមន៍

ក្នុងតំបន់ដើម្បីបង្កើតគម្រោងសំណង ប៉ុន្តែបរាជ័យក្នុងការបែងចែកសំណងពីគម្រោងអភិវឌ្ឍ ហើយខ្លួនមិនមានទំនាក់ទំនងល្អជាមួយនឹងសហគមន៍ក្នុងតំបន់ ទាំងការពន្យល់ថា តើគម្រោងនោះត្រូវបានជ្រើសរើស និងផ្តល់អាទិភាព និងផ្តល់ជំនួយផ្នែកបច្ចេកទេសដល់សហគមន៍ដោយរបៀបណា ។ ស្ថាប័នជាតិត្រូវបានញាំញីដោយថវិកាតិចតួចរហូតដល់មិនអាចអនុវត្តសំណងពេញលេញផងដែរ ។

គណៈកម្មាធិការស្វែងរកការពិត និងផ្សះផ្សារបស់ប្រទេសសេរ៉ាឡេអូន ត្រូវបានបង្កើតឡើងនៅក្នុងឆ្នាំ២០០០ ។ នៅក្នុងរបាយការណ៍ចុងក្រោយរបស់គណៈកម្មាធិការស្វែងរកការពិត និងផ្សះផ្សាបានចេញនៅក្នុងឆ្នាំ២០០៥ គណៈកម្មាធិការស្វែងរកការពិត និងផ្សះផ្សាបានផ្តល់អនុសាសន៍ថា សំណងគួរតែត្រូវបានផ្តល់ឲ្យជនរងគ្រោះ ។ ស្ទើរតែពីរឆ្នាំបន្ទាប់ពីការផ្តល់អនុសាសន៍របស់គណៈកម្មាធិការស្វែងរកការពិត និងផ្សះផ្សា រដ្ឋាភិបាលរបស់ប្រទេសសេរ៉ាឡេអូន បានបង្កើតគណៈកម្មាធិការជាតិទទួលបន្ទុកកិច្ចការងារសង្គម ដែលជាអង្គភាពខាងរដ្ឋាភិបាលនាំមុខដើម្បីអនុវត្តមធ្យោបាយសំណងតាមអនុសាសន៍ ។ ទោះបីជាយ៉ាងណាក៏ដោយ កម្មវិធីសំណងមិនបានចាប់ផ្តើមភ្លាមៗនោះទេ ។ ក្នុងឆ្នាំ២០០៧ មូលនិធិកសាងសន្តិភាពរបស់អង្គការសហប្រជាជាតិ *(UN Peace Building Fund)* បានផ្តល់ជំនួយបីលានដុល្លារអាមេរិក ដល់ប្រទេសសេរ៉ាឡេអូន ដើម្បីធ្វើឲ្យដំណើរការដល់សំណងដែលជាប់គាំង ។ គម្រោងមូលនិធិកសាងសន្តិភាពរបស់អង្គការសហប្រជាជាតិ ត្រូវបានបង្កើតឡើងដើម្បីជួយកសាងសមត្ថភាពសម្រាប់គណៈកម្មាធិការជាតិទទួលបន្ទុកសកម្មភាពសង្គម ។ ក្រោមកម្មវិធីនេះ គណៈកម្មាធិការទទួលបន្ទុកសកម្មភាពសង្គមបានបង្កើតប្រធានគ្រប់គ្រងសំណង, គណៈកម្មាធិការត្រួតពិនិត្យជាតិ, មូលនិធិសំណង ពិសេសសម្រាប់ជនរងគ្រោះដោយសារសង្គ្រាម និងយុទ្ធសាស្ត្ររយៈពេល៥ឆ្នាំសម្រាប់ការអនុវត្តគម្រោងសំណង ។

គណៈកម្មាធិការជាតិទទួលបន្ទុកសកម្មភាពសង្គមបានធ្វើការងារដ៏ល្អប្រសើរក្នុងការដាក់បញ្ចូលសង្គមស៊ីវិលនៅក្នុងកម្មវិធីសំណង ។ ដោយសារលក្ខខណ្ឌដែលដាក់ដោយមូលនិធិកសាងសន្តិភាពរបស់អង្គការសហប្រជាជាតិ មុនពេលផ្តល់ថវិកានេះ អង្គការអន្តរជាតិទទួលបន្ទុកការធ្វើចំណាកស្រុក បានចូលរួមត្រួតពិនិត្យមើលកម្មវិធីសំណងរបស់គណៈកម្មាធិការជាតិទទួលបន្ទុកសកម្មភាពសង្គម ។ គណៈកម្មាធិការជាតិទទួលបន្ទុកសកម្មភាពសង្គម និងអង្គការអន្តរជាតិទទួលបន្ទុកការធ្វើចំណាកស្រុកធ្វើជាសហប្រធាននៅក្នុងគណៈកម្មាធិការត្រួតពិនិត្យជាតិ រួមមានអ្នកតំណាងរដ្ឋាភិបាលជាច្រើន, អ្នកតំណាង៧រូបមកពីសង្គមស៊ីវិល, ក្រុមជនរងគ្រោះដែលជាប្រធានមូលនិធិសំណង និងអ្នកតំណាងមកពីសមាគមអ្នកកាសែតប្រទេសសេរ៉ាឡេអូន ។ ក្រៅពីនេះ នៅក្នុងឆ្នាំ២០០៨ ដើម្បីធានាឲ្យមានការចូលរួមដ៏ល្អប្រសើរជាមួយនឹងភាគីពាក់ព័ន្ធគណៈកម្មាធិការជាតិទទួលបន្ទុកសកម្មភាពសង្គមបានបង្កើតរចនាសម្ព័ន្ធនៅទូទាំងប្រទេស ។ រចនាសម្ព័ន្ធទាំងនេះរួមមាន គណៈកម្មាធិការពាក់ព័ន្ធសំណង, អ្នកតំណាងដែលមកពីក្រុមប្រឹក្សាក្នុងតំបន់, មេដឹកនាំសាសនា, សង្គមស៊ីវិល, អង្គភាពជនរងគ្រោះ និងដៃគូដទៃ ។ ចុងបញ្ចប់ គណៈកម្មាធិការជាតិទទួលបន្ទុកសកម្មភាពសង្គម បានធ្វើកិច្ចព្រមព្រៀងជាមួយនឹងអង្គការក្រៅរដ្ឋាភិបាលដើម្បីអនុវត្តគម្រោងសំណង ។ ទោះបីជាយ៉ាងណាក៏ដោយ ក្នុងចំណោមកត្តាគន្លឹះនៃកម្មវិធីសំណងរបស់ប្រទេសសេរ៉ាឡេអូន គឺជាមូលនិធិសំណងជនរងគ្រោះដោយសារសង្គ្រាមរបស់ប្រទេសសេរ៉ាឡេអូន ។ មិនមានអ្នកតំណាងរបស់អង្គការក្រៅរដ្ឋាភិបាលទទួលបន្ទុកជានាយកគ្រប់គ្រងមូលនិធិសំណងនោះឡើយ ។

ប្រទេសម៉ារ៉ុក បានផ្តល់គំរូដ៏ល្អក្នុងការប្រមូលផ្តុំភ្នាក់ងាររដ្ឋាភិបាល និងសង្គមស៊ីវិលមកធ្វើការងាររួមគ្នា ។ ប្រទេសម៉ារ៉ុកនៅក្នុងឆ្នាំ២០០៤ ស្តេចមូហាម៉ាតទី៦ បានបង្កើតគណៈកម្មាធិការសមធម៌ និងផ្សះផ្សា ។ ក្នុងឆ្នាំ២០០៥ គណៈកម្មាធិការសមធម៌និងផ្សះផ្សា បានដាក់របាយការណ៍ និងអនុសាសន៍របស់ខ្លួន ។ នៅពេលដែលគណៈកម្មាធិការសមធម៌ និងផ្សះផ្សាត្រូវបានផ្តល់សិទ្ធិអំណាចតាមរយៈលក្ខន្តិកៈរបស់ខ្លួនក្នុងការផ្តល់សំណងគណៈកម្មាធិការសមធម៌ និងផ្សះផ្សា បានធ្វើសេចក្តីសម្រេចបន្ទាប់សំណងហិរញ្ញវត្ថុដល់ជនរងគ្រោះ៩.៧៧៩នាក់ ហើយបានផ្តល់អនុសាសន៍ដល់មធ្យោបាយផ្សេងៗ រួមមានការស្តារនីតិសម្បទា

ផ្នែកវេជ្ជសាស្ត្រ និងផ្នែកចិត្តសាស្ត្រ ។ គណៈកម្មាធិការសមធម៌ និងផ្សះផ្សា បានខិតខំចេញសេចក្តីសម្រេចលើសំណងសមូហភាព ហើយបានរៀបចំវេទិកាជាតិស្តីពីសំណង រួមមានជាង២០០ អង្គភាព ទាំងអង្គភាពរដ្ឋាភិបាល និងអង្គការក្រៅរដ្ឋាភិបាល ហើយ អ្នកជំនាញជាតិ និងអន្តរជាតិ៥០នាក់ ដើម្បីជួយខ្លួនបង្កើតកម្មវិធីសំណង ។

ក្នុងអំឡុងពេលអនុវត្តគម្រោងសំណងឆ្នាំដំបូង កម្មវិធីសំណងត្រូវបានធ្វើឡើងរួមគ្នា តាមរយៈក្រុមប្រឹក្សាជំនួយទទួលបន្ទុកសិទ្ធិមនុស្ស, ស្ថាប័នរដ្ឋាភិបាល និងអង្គការក្រៅរដ្ឋាភិបាល ។ ក្រុមប្រឹក្សាជំនួយទទួលបន្ទុកសិទ្ធិមនុស្ស ទទួលខុសត្រូវក្នុងការគាក់តែងគោលនយោបាយ ទន្ទឹមពេលដែលមូលនិធិហ្វេសស៊ីឌីជី ទទួលខុសត្រូវចំពោះការគ្រប់គ្រងគម្រោង ។ ក្រុមប្រឹក្សាជំនួយទទួលបន្ទុកសិទ្ធិមនុស្ស បានដើរតួនាទីជាគំរូទាក់ទងទៅនឹងការបង្រួបបង្រួមផ្សេងៗ នៅពេលដែលក្រុមប្រឹក្សានោះបានដាក់បញ្ចូលអង្គភាពរដ្ឋាភិបាល, សមាជិករបស់សង្គមស៊ីវិល រួមមានមេដឹកនាំសាសនា, មេធាវី, វេជ្ជបណ្ឌិត និងសមាជិកមកពីអង្គការក្រៅរដ្ឋាភិបាល រួមមានអ្នកដឹកនាំក្នុងការងារសិទ្ធិមនុស្ស ។ កម្មវិធីសំណងបច្ចុប្បន្នរបស់ប្រទេសម៉ារ៉ុក រួមមាន គណៈកម្មាធិការត្រួតពិនិត្យជាតិ, អង្គភាពគ្រប់គ្រងមជ្ឈិម និងអង្គភាពសម្របសម្រួលក្នុងតំបន់ ។ គណៈកម្មាធិការត្រួតពិនិត្យជាតិ មានអ្នកតំណាងមកពីក្រុមប្រឹក្សាជំនួយទទួលបន្ទុកសិទ្ធិមនុស្ស, មូលនិធិហ្វេសស៊ីឌីជី, ក្រសួង, ម្ចាស់ជំនួយ និងអង្គភាពសម្របសម្រួលក្នុងតំបន់ ។ គណៈកម្មាធិការត្រួតពិនិត្យទទួលបន្ទុកត្រួតពិនិត្យដោយធានាថា កម្មវិធីនោះ ផ្សារភ្ជាប់ទៅនឹងអនុសាសន៍នៃគណៈកម្មាធិការសមធម៌ និងផ្សះផ្សា ហើយបានទាក់ទាញការគាំទ្រផ្នែកហិរញ្ញវត្ថុពីអន្តរជាតិ ។ អង្គភាពគ្រប់គ្រងមជ្ឈិមដែលបង្កើតឡើងដោយមូលនិធិហ្វេសស៊ីឌីជី ទទួលខុសត្រូវចំពោះការគ្រប់គ្រងគម្រោងនោះ ។ ជាចុងបញ្ចប់ គណៈកម្មាធិការសម្របសម្រួល រួមមាន អាជ្ញាធរក្នុងតំបន់ និងអង្គការក្រៅរដ្ឋាភិបាលក្នុងតំបន់ ទទួលបន្ទុកសម្របសម្រួលទំនាក់ទំនងរវាងប្រជាជនក្នុងតំបន់ និងរដ្ឋាភិបាលមជ្ឈិម ដោយតាមដានគម្រោងនៅក្នុងតំបន់របស់ខ្លួន ហើយធានាថាគម្រោងនោះមិនត្រូវឲ្យត្រួតស៊ីគ្នានោះឡើយ ។ គម្រោងនោះត្រូវបានធ្វើឡើងដោយអង្គភាពរដ្ឋាភិបាល ឬតាមរយៈអង្គការក្រៅរដ្ឋាភិបាល ដែលបានដាក់សំណើសម្រាប់ការពិចារណា ។ ផែនការត្រួតពិនិត្យ និងគ្រប់គ្រងរបស់កម្មវិធីសំណងប្រទេសម៉ារ៉ុក មានលក្ខណៈស្មុគស្មាញ ហើយបានធ្វើឲ្យមានលក្ខណៈពិបាកដល់ការសម្របសម្រួលក្នុងចំណោមផ្នែកពាក់ព័ន្ធផ្សេងៗ ។ ទោះបីជាយ៉ាងណាក៏ដោយ កម្មវិធីសំណងនោះបានដាក់បញ្ចូលផ្នែកពាក់ព័ន្ធយ៉ាងសំខាន់ទាំងអស់ ផ្តល់សិទ្ធិដល់ផ្នែកពាក់ព័ន្ធក្នុងតំបន់ និងជួយកសាងសមត្ថភាពរបស់ក្រសួង និងអង្គការក្រៅរដ្ឋាភិបាលតាមរយៈការផ្លាស់ប្តូរបទពិសោធ ។

ប្រទេសកម្ពុជាអាចទាញយកគំរូគណៈកម្មាធិការត្រួតពិនិត្យតាមរយៈបទពិសោធរបស់ប្រទេសទាំងនេះ ។ ប្រទេសម៉ារ៉ុក ទំនងជានឹងផ្តល់នូវគំរូដ៏ល្អដល់ប្រទេសកម្ពុជា ។ ឧទាហរណ៍ ប្រទេសកម្ពុជាអាចបង្កើតគណៈកម្មាធិការត្រួតពិនិត្យជាតិរបស់ខ្លួនទទួលបន្ទុកត្រួតពិនិត្យគម្រោងសំណង ។ ដោយសារសំណងក្នុងប្រទេសកម្ពុជា មានលក្ខណៈស្របច្បាប់ដោយផ្នែកដែលផ្សារភ្ជាប់ទៅនឹងការបង្គាប់របស់តុលាការ គណៈកម្មាធិការត្រួតពិនិត្យរបស់ប្រទេសកម្ពុជានឹងត្រូវដាក់បញ្ចូលអ្នកជំនាញផ្នែកច្បាប់ ប្រហែលជាអតីតចៅក្រមរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដើម្បីធ្វើការងារជាអ្នកជំនាញ និងដើម្បីត្រួតពិនិត្យមើលការអនុវត្តសំណងដើម្បីឲ្យស្របជាមួយនឹងតម្រូវការដែលដាក់ចេញនៅក្នុងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។ ទន្ទឹមពេលដែលចៅក្រមអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជានឹងមិនបម្រើមុខងារជាចៅក្រមនៅក្នុងតុលាការ ហើយមិនអាចផ្តល់ទស្សនៈផ្លូវច្បាប់ដល់គណៈកម្មាធិការនោះ ចៅក្រមទាំងនោះនឹងបម្រើមុខងារជាយន្តការត្រួតពិនិត្យដ៏សំខាន់ ។ ក្រៅពីនេះ ដោយសារដៃគូអនុវត្តនោះទំនងជានឹងបង្គាប់ឲ្យអនុវត្តគម្រោងនោះ អង្គការក្រៅរដ្ឋាភិបាលជាច្រើនទំនងជានឹងអនុវត្តគម្រោងហួសពីការផ្តល់ថវិកាមកអនុវត្ត ដូច្នេះហើយគណៈកម្មាធិការអាចប្រើប្រាស់តម្រូវការទាមទារស្របជាមួយនឹងតម្រូវការទាមទាររបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ក្នុងនាមជាវិធានការមួយសម្រាប់កំណត់ ថាតើត្រូវបន្តភាពជាដៃគូជាមួយនឹងអង្គការក្រៅរដ្ឋាភិបាលឬយ៉ាងណា ។ សង្គមស៊ីវិលនឹងក្លាយជាការលើក

ទឹកចិត្តសម្រាប់ដៃគូអនុវត្ត ដើម្បីពិចារណាអំពីទស្សនៈរបស់អ្នកជំនាញផ្នែកច្បាប់ស្តីពីគណៈកម្មាធិការ និងធ្វើការគោរពនូវទស្សនៈទាំងនោះ ។

អង្គភាពគ្រប់គ្រងដាច់ដោយឡែកដូចជា អង្គភាពគ្រប់គ្រងមជ្ឈិមរបស់ប្រទេសម៉ារ៉ុក ដូចជា អង្គភាពគាំពារជនរងគ្រោះ អាចត្រួតពិនិត្យមើលកិច្ចការងាររដ្ឋបាលរបស់គម្រោង និងធ្វើការងារដើម្បីកំណត់នូវថវិកាបន្ថែម ដើម្បីផ្តល់ថវិកាដល់គម្រោង ។ ការបែងចែកកាតព្វកិច្ចពីរ ដូចជា ការរៃអង្គាសថវិកា និងការត្រួតពិនិត្យមើលការអនុវត្តគម្រោងនឹងជួយដោះស្រាយបញ្ហាអំពីចេញសេចក្តីបង្គាប់ប្រឆាំងទៅនឹងភាគីទី៣ដែលមិនអាចទទួលរ៉ាប់រងសំណងបាននោះ ។ ការចេញសេចក្តីបង្គាប់ប្រឆាំងទៅនឹងភាគីទីបីដែលមិនអាចរ៉ាប់រងសំណងបាននោះ គឺជាការព្រួយបារម្ភដ៏ចម្បងរបស់តុលាការនៅក្នុងសំណុំរឿង០០១ និងបញ្ហាផ្លូវច្បាប់ដ៏ចម្រូងចម្រាស ដែលថាតើតុលាការអាចដាក់កាតព្វកិច្ចបង្គាប់ដល់ម្ចាស់ជំនួយ ដែលបរិច្ចាគថវិកាបដិភាគតាមការស្ម័គ្រចិត្តដល់ការធ្វើសំណងដែលខ្លួនមិនអាចរ៉ាប់រងចំពោះអំពើឧក្រិដ្ឋកម្មណាមួយនោះ ។ ថវិការបស់ម្ចាស់ជំនួយនឹងត្រូវផ្តល់ដល់គម្រោងសំណងទាំងស្រុង ប្រហែលជាតាមរយៈមូលនិធិសំណងដែលនឹងកើតឡើងសម្រាប់គម្រោងជាក់លាក់មួយចំនួន ។ ដោយសារអង្គភាពគ្រប់គ្រងធ្លាប់ត្រូវបានផ្តល់ដល់គម្រោងសំណង ទោះបីជាយ៉ាងណាក៏ដោយ អង្គភាពគ្រប់គ្រងនឹងទទួលខុសត្រូវចំពោះការកំណត់ដៃគូអនុវត្តគម្រោង ហើយគណៈកម្មាធិការត្រួតពិនិត្យនឹងទទួលបន្ទុកការធានាដែលថា ការបង្កើត និងការអនុវត្តគម្រោងស្របគ្នាទៅនឹងតម្រូវការសំណងដែលបង្គាប់ដោយតុលាការ ។ គណៈកម្មាធិការដែលបានចុះហត្ថលេខាលើកិច្ចព្រមព្រៀងថ្មីជាមួយនឹងដៃគូអនុវត្ត អាចអនុវត្តស្របទៅនឹងការបង្គាប់សំណងរបស់តុលាការ ដែលជាផ្នែកមួយនៃកិច្ចព្រមព្រៀងដែលផ្សារភ្ជាប់ជំនួយសម្រាប់គម្រោងតាមការអនុលោម ។ មិនដូចគ្នាទៅនឹងម្ចាស់ជំនួយ ដៃគូអនុវត្តនឹងត្រូវយល់ស្របទៅនឹងកាតព្វកិច្ចទាំងនេះ ដែលជាផ្នែក១នៃកិច្ចព្រមព្រៀង ដែលអនុញ្ញាតឲ្យដៃគូអនុវត្តទទួលបានថវិកា ។

កម្មវិធីគ្រប់គ្រងសំណង មានលក្ខណៈស្មុគស្មាញ ហើយការរៃអង្គាសថវិកាដ៏មានប្រសិទ្ធភាពមានលក្ខណៈសំខាន់ ។ ប្រទេសផ្សេងៗបានប្រើនីតិវិធីផ្សេងៗគ្នា ។ កម្មវិធីប្រកបដោយប្រសិទ្ធភាពជាច្រើនត្រូវបានផ្គត់ផ្គង់ផ្នែកហិរញ្ញវត្ថុមួយភាគធំពីរដ្ឋ ទោះបីជាប្រទេសម៉ារ៉ុកផ្តល់គំរូស្តីពីថាតើ ពេលណាដែលថវិកាអន្តរជាតិបម្រើមុខងារយ៉ាងសំខាន់ដល់ការបង្កើតកម្មវិធីសំណងប្រកបដោយប្រសិទ្ធភាពនោះ ។ យោងទៅតាម រូបេន ការ៉ានហ្សា នៃមជ្ឈមណ្ឌលអន្តរជាតិទទួលបន្ទុកស្វែងរកយុត្តិធម៌ក្នុងសម័យអន្តរកាល មូលនិធិសំណងជនរងគ្រោះមានលក្ខណៈប្រសើរក្នុងការធានានូវសំណងមួយពេល ប៉ុន្តែជាការគាំទ្រដល់ការគាំពារសុខភាព និងអប់រំ ។ យុទ្ធសាស្ត្រផ្តល់ថវិកាត្រូវតែស្របជាមួយនឹងគោលបំណងសំណង ហើយមូលនិធិសំណងជនរងគ្រោះមិនបានស្តែងឲ្យឃើញនូវប្រព័ន្ធថវិកាដែលមាននិរន្តរភាព ។ ថវិកាបដិភាគពីម្ចាស់ជំនួយ និងផ្នែកឯកជន ជារឿយៗ មានតិចជាងការរំពឹងទុក ។ ឧទាហរណ៍ ថវិកានៅក្នុងប្រទេសសេរ៉ាឡេអូនបានទទួលថវិកាបដិភាគតិចតួច ហើយកម្មវិធីសំណងនោះនឹងខិតខំប្រឹងប្រែងទៅមុខទោះបីជាមានកង្វះខាតថវិកាក៏ដោយ ។

ថ្វីបើមានការបង្កើតមូលនិធិសំណងនៅក្នុងប្រទេសសេរ៉ាឡេអូន គណៈកម្មាធិការជាតិទទួលបន្ទុកសកម្មភាពសង្គមបានជួបប្រទះបញ្ហាថវិកាក្នុងទ្រង់ទ្រាយធំ ដោយសារតែខ្វះការប្តេជ្ញាចិត្តពីរដ្ឋាភិបាលប្រទេសសេរ៉ាឡេអូន ក្នុងការផ្តល់ធនធានហិរញ្ញវត្ថុដល់កម្មវិធី ។ មូលនិធិសំណងជនរងគ្រោះត្រូវបានបង្កើតឡើងនៅក្នុងកិច្ចព្រមព្រៀងសន្តិភាពក្នុងឆ្នាំ១៩៩៩ នៅក្នុងមាត្រាដែលបង្កើតឡើងដោយគណៈកម្មាធិការស្វែងរកការពិតនិងការផ្សះផ្សា ក្នុងឆ្នាំ២០០០ ហើយត្រូវបានផ្តល់ជាអនុសាសន៍តាមរយៈរបាយការណ៍ចុងក្រោយរបស់គណៈកម្មាធិការស្វែងរកការពិត និងការផ្សះផ្សា ក្នុងឆ្នាំ២០០៥ ។ ទោះបីជាយ៉ាងណាក៏ដោយ រហូតទាល់តែឆ្នាំ២០០៩ ទើបរដ្ឋាភិបាលប្រទេសសេរ៉ាឡេអូន បង្កើតមូលនិធិសំណងពិសេសសម្រាប់ជនរងគ្រោះដោយសង្គ្រាម ។ គណៈកម្មាធិការជាតិទទួលបន្ទុកសកម្មភាពសង្គមទទួលបន្ទុកបង្កើតអាណត្តិ រចនាសម្ព័ន្ធ និងក្របខណ្ឌប្រតិបត្តិសម្រាប់មូលនិធិ ។ បច្ចុប្បន្ន មូលនិធិសំណងជនរងគ្រោះមានគណៈគ្រប់គ្រងដែលមានសមាជិក៧នាក់ រួមមានសមាជិកសភា មេដឹកនាំ

សាសនាពីរនាក់ អ្នកប្រឹក្សាស្តីពីសំណង និងសមាជិកដែលតំណាងឲ្យក្រសួងសុខាភិបាល និងអប់រំ ។

មូលនិធិសំណងនៅតែខ្វះថវិកាយ៉ាងច្រើន ។ នៅក្នុងឆ្នាំ២០១១ មានតែថវិកា៨សែនដុល្លារអាមេរិកប៉ុណ្ណោះ ត្រូវបានទទួលពីរដ្ឋាភិបាល ដោយមានថវិកាសម្រាប់ជនរងគ្រោះដែលរងការរំលោភបំពានផ្លូវភេទ ។ ថវិកានោះមិនអាចឆ្លើយតបទៅនឹងជនរងគ្រោះនៃជម្លោះដែលបានចុះបញ្ជី៣២.០០០នាក់នោះឡើយ ។ ផ្នែកពាក់ព័ន្ធនៅក្នុងប្រទេសសេរ៉ាឡេអូន បានរិះគន់រដ្ឋាភិបាលពីការកង្វះថវិកា ដោយលើកឡើងថា ការបរាជ័យរបស់រដ្ឋាភិបាលចំពោះការផ្តល់ជំនួយដល់មូលនិធិសំណងជនរងគ្រោះ ព្រមទាំងការគាំទ្រផ្នែកហិរញ្ញវត្ថុដល់សំណងអាចជាការបន្ទាក់ដល់អង្គការអន្តរជាតិដទៃដែលផ្តល់ជំនួយ ។ មកដល់ពេលបច្ចុប្បន្ន គ្មានម្ចាស់ជំនួយ លើកលែងតែ យូនីហ្វាម (Unifam) បានរួមចំណែកដល់កម្មវិធីសំណងទាំងមូល ។ គណៈកម្មាធិការជាតិទទួលបន្ទុកការងារសន្តមមិនមានថវិកាគ្រប់គ្រាន់ដើម្បីអនុវត្តកញ្ចប់សំណងតាមផែនការនោះឡើយ ។ ក្នុងបរិបទជាច្រើនបានបង្ហាញថា ការគាំទ្រផ្នែកហិរញ្ញវត្ថុរបស់រដ្ឋាភិបាលចំពោះកម្មវិធីសំណងមានលក្ខណៈសំខាន់ក្នុងការធានាឲ្យមានភាពជោគជ័យរបស់កម្មវិធី និងបញ្ចុះបញ្ចូលម្ចាស់ជំនួយអន្តរជាតិឲ្យរួមចំណែក ។ មានម្ចាស់ជំនួយតិចតួចដែលផ្តល់ថវិកាដល់កម្មវិធីសំណង ។

នៅក្នុងប្រទេសម៉ារ៉ុក ជំនួយពីសហគមន៍អន្តរជាតិ បានផ្តល់ការជំរុញដល់ការអនុវត្តសំណង ។ គណៈកម្មាធិការអឺរ៉ុបបានផ្តល់ជំនួយប្រហែល១លាន៨សែនដុល្លារ ដែលជំរុញដល់ដំណើរការសំណងឆ្ពោះទៅមុខ ។ ប្រទេសម៉ារ៉ុក មានទំនាក់ទំនងល្អជាមួយនឹងគណៈកម្មាធិការអឺរ៉ុប ។ ទោះបីជាយ៉ាងណាក៏ដោយ វាមិនទំនងជាថា ការគាំទ្រទ្វេភាគីក្នុងទ្រង់ទ្រាយធំនឹងកើតឡើងក្នុងបរិបទផ្សេងៗ ។ រដ្ឋាភិបាលប្រទេសម៉ារ៉ុក និងស្ថាប័នរដ្ឋបានឆ្លើយតបចំពោះថវិការបស់គណៈកម្មាធិការអឺរ៉ុប តាមរយៈការចាប់ផ្តើមយ៉ាងសកម្មក្នុងការចូលរួមដល់ការផ្តល់ហិរញ្ញវត្ថុដល់កម្មវិធីនោះ ។ ប្រទេសម៉ារ៉ុកមិនបានបង្កើតមូលនិធិសំណងជនរងគ្រោះ ហើយភាគច្រើននៃថវិកានៃកម្មវិធីបានមកពីរដ្ឋ ។

យោងទៅតាមតុលាការយុត្តិធម៌ក្នុងសម័យអន្តរកាលរបស់អន្តរជាតិ ប្រភពដែលអាចពឹងផ្អែកបានភាគច្រើនសម្រាប់កម្មវិធីសំណងជាថវិកា គឺជាថវិកាជាតិ ។ ប្រទេសអាហ្សង់ទីន និងប្រទេសឈីលី ជារឿយៗបានរៃអង្គាសថវិកាដែលជាគំរូអនុវត្តដ៏ល្អប្រសើរបំផុត ក្នុងការផ្តល់កម្មវិធីសំណងយ៉ាងទូលំទូលាយ, បានផ្តល់ធនធានរបស់រដ្ឋសំខាន់ទៅឲ្យកម្មវិធីសំណង ។ ឧទាហរណ៍ ប្រទេសឈីលី បានបរិច្ចាគថវិកាប្រហែល៣.០០០លានដុល្លារអាមេរិកនៅក្នុងគម្រោងសំណង ។ គំរូនោះមានទំនាក់ទំនងទៅនឹងប្រទេសដែលស្ថិតនៅក្នុងភាគខាងត្បូង ដែលមិនមានភាពរឹងមាំផ្នែកសេដ្ឋកិច្ចគ្រប់គ្រាន់ដើម្បីផ្តល់សំណងជាថវិកា ។ ឧទាហរណ៍ដូចបានបង្ហាញពីខាងលើ ប្រទេសសេរ៉ាឡេអូន ពឹងផ្អែកលើជំនួយ៣លានដុល្លារអាមេរិកពីមូលនិធិកសាងសន្តិភាពរបស់អង្គការសហប្រជាជាតិដើម្បីចាប់ផ្តើមកម្មវិធីសំណង ។ ប្រទេសនេប៉ាល់ និងប្រទេសទីម័រ ពឹងផ្អែកលើជំនួយមួយភាគធំពីធនាគារពិភពលោក ។

ប្រទេសកម្ពុជា ទំនងជានឹងមិនត្រូវការម្ចាស់ជំនួយសំខាន់ដើម្បីចាប់ផ្តើមកម្មវិធីសំណង ។ ប្រទេសកម្ពុជាអាចនៅតែត្រូវបានចាត់ទុកថាជាប្រទេសដែលមានចំណូលតិចតួចដែលតស៊ូជាមួយនឹងការជំរុញលើបញ្ហាអភិវឌ្ឍ ។ វាជាការលំបាកក្នុងការបញ្ចុះបញ្ចូលរាជរដ្ឋាភិបាលកម្ពុជាដើម្បីបង្វែរធនធានដែលបានកំណត់មួយចំនួនឲ្យទៅជាសំណងជាជាងគម្រោងអភិវឌ្ឍ ។ ទោះបីជាយ៉ាងណាក៏ដោយ ប្រទេសកំពុងអភិវឌ្ឍមួយចំនួនបានប្រើលក្ខខណ្ឌចំណូលទាបដើម្បីទទួលបានការលើកលែងនូវកម្ចីដើម្បីផ្តល់ថវិកាដល់សំណង ។ ទោះបីជាយ៉ាងណាក៏ដោយ ដូចជាតាមរយៈគំរូនៃប្រទេសម៉ារុក និងប្រទេសសេរ៉ាឡេអូន ភាពជោគជ័យរយៈពេលវែងនៃកម្មវិធីនោះនឹងផ្អែកលើការទទួលយកគោលនយោបាយ ភាពម្ចាស់ការ និងការគាំទ្រផ្នែកហិរញ្ញវត្ថុពីរាជរដ្ឋាភិបាលកម្ពុជា ។

**សេចក្តីសន្និដ្ឋាន**

សំណងគឺជាផ្នែកដ៏សំខាន់នៃអាណត្តិ និងបេសកកម្មរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។ ប្រសិនបើតុលាការខកខានផ្តល់សំណងសំខាន់ដល់ជនរងគ្រោះ ខ្លួននឹងទទួលបរាជ័យចំពោះការរក្សាការសន្យារបស់ខ្លួនដែលតុលាការព្រហ្មទណ្ឌអន្តរជាតិដំបូង អនុញ្ញាតឲ្យមានសំណងជនរងគ្រោះ ។ ដើម្បីផ្តល់សំណង

ដ៏សំខាន់ អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា នឹងត្រូវបន្ទាបតម្រូវការលក្ខខណ្ឌជាក់លាក់ និងកម្រិតថវិកាដែលខ្លួនបង្កើតនៅក្នុងសំណុំរឿង០០១ដែលកើតចេញមកពីការអនុវត្តរបស់អន្តរជាតិ ។ មធ្យោបាយដើម្បីឆ្លើយតបទៅនឹងកង្វល់របស់តុលាការអំពីការចេញសេចក្តីសម្រេចបង្គាប់សំណងប្រកបដោយប្រសិទ្ធភាព និងការរារាំងដល់ការដាក់កាតព្វកិច្ចផ្លូវច្បាប់លើភាគីទីបីដែលមិនទទួលខុសត្រូវ (ឧទាហរណ៍ម្ចាស់ជំនួយ) អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាអាចកសាងយន្តការដើម្បីត្រួតពិនិត្យមើលគម្រោងសំណង ដើម្បីធានាឲ្យមានការអនុលោមតាមការទាមទារដែលបង្គាប់ដោយតុលាការ និងគ្រប់គ្រងការអនុវត្តគម្រោងសំណងនោះ ។ យន្តការនេះអាចប្រើប្រាស់ទម្រង់មួយចំនួន ។ ទម្រង់ដ៏ល្អបំផុតទំនងជាយន្តការដែលញែកដំណើរការវែអង្គាសថវិកាចេញពីដំណើរការត្រួតពិនិត្យ ។ ក្នុងន័យនេះថវិកាអាចត្រូវបានវែអង្គាសហើយអាចតម្កល់ នៅក្នុងមូលនិធិសំណង ។ មានម្តងនោះ តុលាការអាចនឹងប្រកាសជ្រើសរើសរកដៃគូអនុវត្តគម្រោង ដោយធ្វើកិច្ចព្រមព្រៀងជាមួយនឹងដៃគូទាំងនេះលើលក្ខខណ្ឌទាមទារសម្រាប់គម្រោងសំណង ដែលដាក់ចេញដោយតុលាការ ។ កិច្ចព្រមព្រៀងទាំងនេះ និងកិច្ចការងារនៃយន្តការគ្រប់គ្រងអាចត្រូវបានត្រួតពិនិត្យដោយអង្គជំនុំជម្រះ ដែលលក្ខណៈស្រដៀងគ្នាទៅនឹងការត្រួតពិនិត្យមើលមូលនិធិសំណងជនរងគ្រោះរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ឬតាមរយៈគណៈកម្មាធិការត្រួតពិនិត្យ ។ អង្គជំនុំជម្រះ ឬគណៈកម្មាធិការនោះនឹងមិនធ្វើការគ្រប់គ្រងតាមផ្លូវច្បាប់លើដៃគូអនុវត្តគម្រោងសំណងនោះឡើយ ជាជាងខ្លួនធ្វើឲ្យដៃគូឈប់ផ្តល់ថវិកា ឬបង្គាប់ឲ្យមានកិច្ចព្រមព្រៀងដូចជា កិច្ចព្រមព្រៀងដទៃណាមួយនោះនៅក្នុងតុលាការកម្ពុជា ។

**គ្រីស្ទីន ប៉ាក់រលី**

# ខ្សែភាពយន្តឯកសាររឿង «ក្បង់ទឹកទន្លេ»

"ក្បង់ទឹកទន្លេ" គឺជាខ្សែភាពយន្តឯកសាររបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ដែលទទួលបានការគាំទ្រ និងទិដ្ឋាការពីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ។ មកដល់ពេលនេះ ខ្សែភាពយន្ត "ក្បង់ទឹកទន្លេ" ទទួលបានពានរង្វាន់លំដាប់ពិភពលោកចំនួន១២ហើយ ។ "ក្បង់ទឹកទន្លេ" បង្ហាញនូវដំណើរជីវិតមួយដ៏វិសេសវិសាល និងមិនធ្លាប់មានពីមុនមក ដែលផ្តើមចេញពីតំបន់ជនបទ ចុងកាត់មាត់ញែកព្រៃភ្នំ និងភូមិនេសាទនៅលើផ្ទៃទឹករបស់តួអង្គទាំងបី ។ ខ្សែភាពយន្តនេះបានចាក់បញ្ចាំងនៅសារមន្ទីរសិល្បៈទំនើប សហរដ្ឋអាមេរិក ចាប់ពីថ្ងៃទី១២ ដល់ថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០១៣ និងប្រទេសអូទ្រីស ប៊ែលហ្ស៊ិក អាល្លឺម៉ង់ កូរ៉េខាងត្បូង អ៊ីតាលី និងប្រទេសអង់គ្លេស ។ ខ្សែភាពយន្តឯកសារនេះ ក៏គ្រោងនឹងដាក់បញ្ចាំងតាមសាកលវិទ្យាល័យ និងភូមិចំនួន៦០ ទូទាំងប្រទេសកម្ពុជាដើម្បីបើកឲ្យមានការពិភាក្សាស្តីពីការផ្លាស់ប្តូរបរិស្ថាន ដើម្បីស្វែងរកដំណោះស្រាយ ។

ខ្សែភាពយន្តនេះក៏មានចាក់បញ្ចាំងជូនទស្សនារៀងរាល់ថ្ងៃសុក្រនៅមជ្ឈមណ្ឌលឯកសារកម្ពុជា ។

ព័ត៌មានបន្ថែមសូមទាក់ទង កញ្ញា សា ហ្វាទីលី តាមរយៈទូរស័ព្ទលេខៈ ០១២ ៥១១ ៩១៤ ។

អ៊ីម៉ែល : truthfatily.s@dccam.org គេហទំព័រ : www.ariverchangescourse.com





# ការចងចាំនៃការជម្លៀសដោយបង្ខំ

នៅថ្ងៃទី២០ ខែធ្នូ ឆ្នាំ១៩៧៦ ប៉ុល ពត បានអះអាងថា «មានជំងឺនៅក្នុងបក្ស» ដែលបណ្ដាលមកពី «មេរោគ» ហើយបានគំរាមកំហែងដល់ភាពបរិសុទ្ធរបស់បដិវត្តន៍ខ្មែរក្រហម ។ «មិនមានក្រសួងសុខាភិបាលបានស្រាវជ្រាវរកមេរោគនោះទេ» ប៉ុល ពត បានព្រមានថា វាមានសារសំខាន់សម្រាប់បដិវត្តន៍ដើម្បី «កម្ចាត់» មេរោគទាំងនោះ ។ ពិតប្រាកដណាស់ ខ្មែរក្រហមបានសម្រាលពាក្យទង្វើប្រល័យពូជសាសន៍ ដោយពាក្យប្រៀបធៀបអំពីជំងឺដែលជារឿយៗ សំដៅទៅរកមនុស្សដែលត្រូវបំពុលគំនិត ។ ពាក្យស្លោកខ្មែរក្រហមមួយឃ្លាពោលថា «យើងត្រូវកម្ចាត់សត្រូវខាងក្រៅ និងសត្រូវស៊ីរូងផ្ទៃក្នុង និងសត្រូវសតិអារម្មណ៍» ។ ដូច្នេះហើយ ដោយសារខ្មែរក្រហម ព្យាយាមលុបបំបាត់ដានប្រទេសកម្ពុជាមុនបដិវត្តន៍ ខ្មែរក្រហមបានរកឃើញថា «ជំងឺសតិអារម្មណ៍» ជាទុក្ខព្រួយដ៏ធំសម្បើម ។

នៅពេលដែលបដិវត្តន៍របស់ខ្មែរក្រហមបានក្ដោបក្ដាប់ទីក្រុងភ្នំពេញ នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ និងបានប្រកាសនូវជ័យជម្នះបន្ទាប់ពីសង្គ្រាមស៊ីវិលរយៈពេល៥ឆ្នាំជាមួយរបបសាធារណរដ្ឋខ្មែរដែលគាំទ្រដោយសហរដ្ឋអាមេរិក ភ្លាមៗនោះខ្មែរក្រហមបានចាប់ផ្ដើមបណ្ដេញអ្នកទីក្រុង និងជនភៀសខ្លួនទៅកាន់ជំរំពលកម្មនៅតាមជនបទ ។ ខ្មែរក្រហមបានប្រកាសថា «មិត្តបងទាំងអស់គ្នាត្រូវបានស្នើឲ្យចាកចេញពីទីក្រុងភ្នំពេញរយៈពេលបីថ្ងៃ ដោយសារអង្គការត្រូវសម្អាតសត្រូវលាក់ខ្លួនក្នុងផ្ទះ និងសម្អាតទីក្រុង ។ អាមេរិកមិនបានបំភ្លេចចោលការបរាជ័យរបស់



ប្រជាជនដែលខ្មែរក្រហមជម្លៀសឲ្យទៅរស់នៅជនបទ

ខ្លួននោះទេ ។ ជនបដិវត្តន៍បានប្រាប់ថា ដោយសារតែប្រជាជននឹងត្រឡប់មកវិញក្នុងពេលឆាប់ៗ ដូច្នេះប្រជាជនទាំងនោះមិនគួរយករបស់របរច្រើនទៅជាមួយខ្លួននោះទេ ។ ប៉ុន្តែ ទោះបីជាយ៉ាងណាក៏ដោយរបស់របរ ទាំងនោះត្រូវបានរឹបអូសយក ។ ទាំងអំឡុងពេល និងបន្ទាប់ពីការជម្លៀសខ្មែរក្រហមបានបញ្ជាឲ្យប្រជាជនលុបបំបាត់ចោលភស្តុតាងស្តីពីអតីតកាលរបស់ប្រទេសកម្ពុជា ។ “អ្នកដែលមានរូបថត ឬ កេរមរតកពីដូនតា អាចត្រូវបានចោទប្រកាន់ថា មានជំងឺសតិអារម្មណ៍” ម៉ម ប៊ុតធីតា ដែលអ្នករស់រានមានជីវិតបានពន្យល់ថា “សំណេររបស់ឪពុករបស់ខ្ញុំបានបង្ហាញពីការព្រួយបារម្ភចំពោះអតីតកាល” ។

ការជម្លៀសប្រជាជនប្រមាណពីរលាននាក់ចេញពីទីក្រុងភ្នំពេញដោយបង្ខំ និងជាប្រព័ន្ធដោយធ្វើឲ្យមានការចាប់ផ្តើមនូវអ្វីដែលរបបដែលបំពាក់បំប៉នដោយមនោគមវិជ្ជា ម៉ៅ ឬហៅថា មហាលោតផ្លោះ ដែលប្រជាជនត្រូវធ្វើដំណើរចាកចេញរយៈពេលយូរតាមរយៈរថភ្លើង ថ្មើរជើង រទេះគោ ឡាន ត្រាក់ទ័រ និងទូកដោយមិនគិតអំពីអាយុ និងស្ថានភាពរាងកាយ ។ សូម្បីតែមន្ទីរពេទ្យក៏គ្មានអ្នកជំងឺនៅសម្រាកព្យាបាលដែរ ។ មានភស្តុតាងដែលថា ថ្នាក់ដឹកនាំរបស់បក្សកុម្មុយនីស្តកម្ពុជាបានចូលរួមដោយផ្ទាល់ក្នុងការសម្រេចចិត្តក្នុងការចាត់ចែងទីតាំងថ្មីសម្រាប់ប្រជាជន និងការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ ព្រមទាំងដំណាក់កាលនៃការបន្ទាស់ទីប្រជាជនដោយបង្ខំទៅកាន់តំបន់ជាក់លាក់នោះ គឺជាការផ្តោតដោយសំខាន់ក្នុងសំណុំរឿង០០២/០១ ។ ខ្មែរក្រហមដែលអនុវត្តការជម្លៀសដោយបង្ខំ បានផ្តល់ជំនួយតិចតួច ឬក៏គ្មានដល់អ្នកជម្លៀសដែលត្រូវទទួលរងលក្ខខណ្ឌអាក្រក់ជាច្រើន រួមមានការបែកបាក់គ្រួសារ ការបាត់ខ្លួន ជំងឺ ការអត់ឃ្លាន ការវាយធ្វើបាប អំពើហិង្សាផ្លូវភេទ និងការសម្លាប់ ។ ការដៅ និងការធ្វើបាបក្រុមជាក់លាក់ គឺជារឿងសាមញ្ញអំឡុងពេលនៃការជម្លៀស ។ ខ្មែរក្រហមបានបែងចែកប្រជាជនជាពីរវណ្ណៈ គឺ ប្រជាជនថ្មី និងប្រជាជនមូលដ្ឋាន ។ ប្រជាជនថ្មី ឬប្រជាជន ១៧ មេសា គឺជាអតីតអ្នកទីក្រុង និងជនភៀសខ្លួនរីឯប្រជាជនមូលដ្ឋាន គឺជាមនុស្សដែលនៅទីជនបទ អំឡុងពេលសង្គ្រាមស៊ីវិល ។ មន្ត្រីមកពីរដ្ឋាភិបាលសាធារណរដ្ឋខ្មែរ ជនជាតិភាគតិច ជនជាតិចាមម៉ូស្លីម ជនជាតិវៀតណាម និងជនជាតិចិន ព្រះសង្ឃ និងយាយជី ស្ថិតក្នុងចំណោមមនុស្សដែលត្រូវដៅបំបែក និងការធ្វើបាប ។ អ្នករស់រានមានជីវិតពីរបបនោះ បានរងការប៉ះទង្គិចផ្លូវចិត្ត និងរាងកាយដែលបន្តដល់ពេលបច្ចុប្បន្ន ។

ដោយអនុវត្តតាមវិធានផ្ទៃក្នុង២៣របស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដើមបណ្តឹងរដ្ឋប្បវេណីមានសិទ្ធិទាមទារសំណងសមូហភាព និងសំណងផ្លូវចិត្ត ។ នៅក្នុងសំណុំរឿង ០០២/០១ ដើមបណ្តឹងរដ្ឋប្បវេណីបានស្វែងរកការទទួលស្គាល់នៃគម្រោងសំណងទាំង១៣ ដែលទទួលស្គាល់ជនរងគ្រោះនៃរបបខ្មែរក្រហម ហើយជាផ្នែកមួយដ៏សំខាន់នៃកេរដំណែលរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។ ការចូលរួមរបស់អ្នករស់រានមានជីវិតក្នុងដំណើរការស្វែងរកយុត្តិធម៌ មានសារសំខាន់ចំពោះការគោរពជនរងគ្រោះ ហើយក៏លើកស្ទួយសហគមន៍ និងការពិភាក្សា ។ ការតាំងពិពណ៌ទាំងប្រាំស្តីពីការជម្លៀសដោយបង្ខំដែលមានសក្ខីកម្មរបស់ជនរងគ្រោះ និងជនដៃដល់ ព្រមទាំងប្រវត្តិរបស់ភូមិ កន្លែងកប់សាកសព និងគុក នឹងរួមចំណែកដល់ការរំឭកអំពីអំពើប្រល័យពូជសាសន៍ ព្រមទាំងការអប់រំមនុស្សសម័យបច្ចុប្បន្ន និងសម័យក្រោយអំពីអ្វីដែលបានកើតឡើងក្នុងរបបខ្មែរក្រហម ។ ការតាំងពិពណ៌នេះនឹងឆ្លុះបញ្ចាំងអំពីអំពើឃោរឃៅរបស់ខ្មែរក្រហមដែលត្រូវបានថ្កោលទោសថាជាភស្តុតាងស្តីពីជំងឺក្នុងរបបខ្មែរក្រហម ។

**ហ៊ុយ សម្ផស្ស, ហ័តសុន ម៉ាក់ហ្វាន និង ផាត កុសល**

# អានទស្សនាវដ្ដីតាមគេហទំព័រ

ទស្សនាវដ្តីស្វែងរកការពិតទាំងអស់ត្រូវបានផ្សព្វផ្សាយតាមគេហទំព័ររបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ។ អ្នកអានអាចរកបានតាមៈ http://d.dccam.org/Projects/Magazines/Magazine_Searching.htm . ព័ត៌មានបន្ថែម សូមទាក់ទង ញាណ សុជាតិ ទូរស័ព្ទលេខ ០១៦ ៨៧៦ ៦៩២ ឬ ០២៣ ២១១ ៨៧៥ ។

# តើសំណងអ្វីខ្លះដែលដើមបណ្តឹងរដ្ឋប្បវេណីអាចនឹងទទួលបានសម្រាប់សំណុំរឿង០០២/០១?

***សេចក្តីផ្តើម***

*វិធាន២៣ស្ទួនបួន នៃវិធានផ្ទៃក្នុងរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការបានចែងថា "នៅពេលដែលអង្គជំនុំជម្រះរកឃើញអំពីពិរុទ្ធភាពរបស់ជនជាប់ចោទ អង្គជំនុំជម្រះអាចសម្រេចផ្តល់តែសំណងផ្លូវចិត្ត និងជាសមូហភាពដល់ភាគីដើមបណ្តឹងរដ្ឋប្បវេណីតែប៉ុណ្ណោះ" ។ នៅក្នុងបរិបទនៃការជំនុំជម្រះក្តីលើអតីតមេដឹកនាំខ្មែរក្រហម អង្គជំនុំជម្រះពុំមានសមត្ថកិច្ចផ្តល់សំណងជាប្រាក់ក្នុងលក្ខណៈជាបុគ្គលទៅឲ្យដើមបណ្តឹងរដ្ឋប្បវេណីដូចជាករណីតុលាការក្នុងស្រុកឡើយ ។*

*នៅក្នុងអំឡុងពេលសវនាការក្នុងសំណុំរឿង០០២/០១ សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីបានដាក់ឯកសារជូនអង្គជំនុំជម្រះសាលាដំបូងស្តីពីគម្រោងសំណងដែលទាមទារដោយដើមបណ្តឹងរដ្ឋប្បវេណីដើម្បីឲ្យអង្គជំនុំជម្រះទទួលស្គាល់គម្រោងទាំងអស់នោះថាជាសំណងសម្រាប់ដើមបណ្តឹងរដ្ឋប្បវេណី ។ គម្រោងសំណងដែលដាក់ជូនដោយសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីមានចំនួន៣ជំពូក និងត្រូវបានបែងចែកជា១៣គម្រោងសំខាន់ៗ ។ ជំពូកទាំងបីនោះ រួមមាន ទី១) ការរំឭក និងការគោរពវិញ្ញាណក្ខន្ធ ទី២) ការស្តារនីតិសម្បទា និង*



*ទស្សនកិច្ចរបស់ប្រជាជននៅគុកទួលស្លែង ឬសារមន្ទីរប្រល័យពូជសាសន៍ទួលស្លែង*

ទី៣) ការចងក្រងឯកសារ និងការអប់រំ ។

គម្រោងសំណង ដែលស្នើសុំដោយដើមបណ្តឹងរដ្ឋប្បវេណី នាពេលនេះ ពុំមែនបង្កើតឡើងក្នុងន័យឆ្លើយតបទៅនឹងការទាមទារសំណងប្រឆាំងនឹងជនជាប់ចោទទេ ក៏ប៉ុន្តែដើម្បីធានាថា សំណងជាក់ស្តែង ដែលឧបត្ថម្ភថវិកាដោយប្រភពខាងក្រៅ ទទួលស្គាល់ព្យសនកម្មរបស់ដើមបណ្តឹងរដ្ឋប្បវេណីអាចត្រូវបានអនុវត្តដោយឆាប់រហ័ស បន្ទាប់ពីសាលក្រមចូលជាស្ថាពរ ។ គម្រោងសំណងមួយចំនួនកំពុងត្រូវបានអនុវត្តដោយអង្គការមិនមែនរដ្ឋាភិបាល ទោះបីជាពុំទាន់មានសាលក្រមស្ថាពរពីអង្គជំនុំជម្រះក៏ដោយ ។ ប៉ុន្តែគម្រោងសំណងទាំងនោះនៅពុំទាន់ក្លាយជាសំណងនៅឡើយទេ ដោយត្រូវរង់ចាំការទទួលស្គាល់ជាផ្លូវការពីសំណាក់អង្គជំនុំជម្រះជាមុនសិន ដើម្បីឲ្យគម្រោងសំណងទាំងអស់នោះអាចក្លាយទៅជាសំណងសម្រាប់ដើមបណ្តឹងរដ្ឋប្បវេណី ។

ដើម្បីទទួលបានសំណងដែលស្នើសុំ អង្គជំនុំជម្រះបានតម្រូវឲ្យសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីធានាថា គម្រោងសំណងទាំងអស់ដែលដាក់ជូនអង្គជំនុំជម្រះឲ្យទទួលស្គាល់ថាជាសំណងផ្លូវការសម្រាប់ដើមបណ្តឹងរដ្ឋប្បវេណី ត្រូវមានលក្ខណៈប្រាកដប្រជាតាមបច្ចេកទេស និងមានហិរញ្ញវត្ថុគ្រប់គ្រាន់សម្រាប់អនុវត្ត ។ បន្ថែមពីលើនេះ គម្រោងសំណងត្រូវបង្ហាញពីភស្តុតាងនៃការយល់ព្រម និងកិច្ចសហការរបស់ភាគីទីបីណាមួយ និងត្រូវផ្តល់ព័ត៌មានបន្ថែមចាំបាច់នានា ដូចជាសេចក្តីពិពណ៌នាលម្អិតគម្រោងប្លង់ ឬរូបភាព និងផែនការថវិកាសម្រាប់សំណើសុំទាំងនោះ ។ បើពុំដូច្នោះទេ គម្រោងសំណងដែលស្នើឡើងអាចនឹងត្រូវបដិសេធចោលដោយអង្គជំនុំជម្រះសាលាដំបូង ។

ទោះបីជាយ៉ាងណា នៅក្នុងវិធានផ្ទៃក្នុងក៏បានចែងដែរថា នៅពេលដែលអង្គជំនុំជម្រះរកឃើញពីពិរុទ្ធភាពរបស់ជនជាប់ចោទ អង្គជំនុំជម្រះអាចបង្គាប់ឲ្យពិរុទ្ធជនចេញថ្លៃសោហ៊ុយក្នុងការអនុវត្តសំណង ដែលដើមបណ្តឹងរដ្ឋប្បវេណីទាមទារ ។ ក៏ប៉ុន្តែប្រសិនបើជនជាប់ចោទទទួលមរណភាពនៅមុនពេលចេញសាលក្រម ដំណើរការនីតិវិធីបណ្តឹងរដ្ឋប្បវេណីនៅមុខអង្គជំនុំជម្រះ



ទស្សនកិច្ចរបស់ប្រជាជននៅគុកទួលស្លែង ឬសារមន្ទីរប្រល័យពូជសាសន៍ទួលស្លែង

ចំពោះជនជាប់ចោទរូបនោះនឹងត្រូវបញ្ចប់ ។ ត្រង់ចំណុចនេះមានភាពខុសប្លែកគ្នាពីក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាត្រង់មាត្រា២៨ ដែលចែងថា «ដើមបណ្ដឹងរដ្ឋប្បវេណី អាចសុំឲ្យមានការជួសជុលព្យសនកម្មពីសិទ្ធិវ័ន្ត នៃជនជាប់ចោទបាន ប្រសិនបើជនជាប់ចោទនេះទទួលមរណភាពនៅក្នុងដំណើរការរឿងក្ដីព្រហ្មទណ្ឌ ។ ថ្វីត្បិតតែបណ្ដឹងអាជ្ញាត្រូវរលត់ តុលាការនៅតែមានសមត្ថកិច្ចដើម្បីសម្រេចលើបណ្ដឹងរដ្ឋប្បវេណីដែលធ្វើឡើងដោយសិទ្ធិវ័ន្តទាំងនោះ» ។ ប៉ុន្តែ នៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ពុំបានអនុញ្ញាតឲ្យមានការប្ដឹងប្រឆាំងនឹងសិទ្ធិវ័ន្តនៃជនជាប់ចោទពីសំណាក់ដើមបណ្ដឹងរដ្ឋប្បវេណី ក្រោយពេលជនជាប់ចោទបានទទួលមរណភាពឡើយ ។

រហូតមកដល់បច្ចុប្បន្ននេះ ពុំទាន់មានការទទួលស្គាល់ជាផ្លូវការណាមួយចំពោះគម្រោងសំណងដែលស្នើសុំនៅឡើយទេ ហើយគម្រោងដែលស្នើសុំមួយចំនួនត្រូវបានអង្គជំនុំជម្រះសាលាដំបូងកត់សម្គាល់ឃើញថា នៅខ្វះសេចក្ដីពិពណ៌នាលម្អិតគ្រប់គ្រាន់ ឬខ្វះការបង្ហាញពីភ័ស្តុតាងនៃការយល់ព្រម និងសហប្រតិបត្តិការរបស់ភាគីទីបីណាមួយ ។ នៅក្នុងឯកសារមួយផ្ញើជូនសហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី ចុះថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០១៣ អង្គជំនុំជម្រះបានសង្កត់ធ្ងន់ថា គម្រោងសំណងដែលមិនមានលក្ខណៈច្បាស់លាស់គ្រប់គ្រាន់អាចនឹងមិនត្រូវបានទទួលស្គាល់ដោយអង្គជំនុំជម្រះនោះទេ ។

ខាងក្រោមនេះ ជាគម្រោងសំណងជាក់លាក់ដែលដើមបណ្ដឹងរដ្ឋប្បវេណីបានស្នើសុំឲ្យមានការទទួលស្គាល់ពីសំណាក់អង្គជំនុំជម្រះ ដើម្បីប្រែក្លាយគម្រោងទាំងអស់នោះទៅជាសំណងផ្លូវការសម្រាប់ដើមបណ្ដឹងរដ្ឋប្បវេណីក្នុងសំណុំរឿង០០២/០១ ។

## ជំពូកទី១ ការរំឭក និងការគោរពវិញ្ញាណក្ខន្ធ

ជំពូកនេះមានគោលដៅគោរពវិញ្ញាណក្ខន្ធដល់អ្នកដែលបានស្លាប់បាត់បង់ជីវិតជនរងគ្រោះ និងអនុញ្ញាតឲ្យអ្នកដែលនៅរស់រានមានជីវិត ជាពិសេសដើមបណ្ដឹងរដ្ឋប្បវេណី ក៏ដូចជាយុវជនជំនាន់ក្រោយ បានពិចារណាអំពីអ្វីដែលបានកើតឡើង និងប្រារព្ធពិធីនានាតាមជំនឿ និងសាសនារបស់ខ្លួន ។ ជំពូកការរំឭក និងការគោរពវិញ្ញាណក្ខន្ធនេះ មានគម្រោងសំណងចំនួន៤ ៖

១) គម្រោងទិវាជាតិនៃការចងចាំ

២) គម្រោងសាងសង់ចេតិយ ស្តូប ឬបូជនីយដ្ឋានសាធារណៈ

៣) គម្រោងសាងសង់បូជនីយដ្ឋានសម្រាប់រំឭកដល់ជនរងគ្រោះ និង

៤) គម្រោងកសាងស្តូបនៅប្រទេសបារាំងសម្រាប់ជនជាតិខ្មែរដែលរស់នៅទីនោះ

### ១) គម្រោងទិវាជាតិនៃការចងចាំ

គម្រោងទិវាជាតិនៃការចងចាំ ជាគម្រោងសំណងដែលស្នើសុំដោយដើមបណ្ដឹងរដ្ឋប្បវេណីក្នុងគោលបំណងស្វែងរកការបង្កើតឲ្យមានថ្ងៃចងចាំជាផ្លូវការ ដែលជាថ្ងៃឈប់សម្រាកមួយផ្សេងពីថ្ងៃឈប់ សម្រាកដែលមាននាពេលបច្ចុប្បន្ន ។ ថ្ងៃដែលដើមបណ្ដឹងរដ្ឋប្បវេណីបានស្នើសុំយកមកធ្វើជាទិវាជាតិនៃការចងចាំ រួមមានថ្ងៃ១៧ ខែមេសា ឬថ្ងៃ២០ ខែឧសភា ឬថ្ងៃ៣០ ខែមីនា ។ ទិវានេះអាចនឹងប្រារព្ធនៅទូទាំងប្រទេស ដើម្បីទទួលស្គាល់ជាផ្លូវការនូវឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តក្នុងរបបខ្មែរក្រហម ។

គោលបំណងនៃការបង្កើតឲ្យមានទិវានៃការចងចាំ គឺធ្វើឡើងក្នុងគោលបំណងស្ដារកិត្តិយសដល់ជនរងគ្រោះនៃរបបខ្មែរក្រហមទាំងអ្នកដែលបានស្លាប់ និងអ្នកដែលនៅរស់ រំឭកនូវការឈឺចាប់ និងខឹងសម្បារដល់បុគ្គលដែលជាទីស្រឡាញ់របស់ខ្លួន និងលើកតម្កើងការចងចាំនូវឧក្រិដ្ឋកម្មប្រព្រឹត្តក្នុងអំឡុងពេលរបបខ្មែរក្រហម ជួយផ្សះផ្សានូវរបួសផ្លូវចិត្ត និងស្ដារកិត្តិយសរបស់ជនរងគ្រោះ ។ ម្យ៉ាងវិញទៀត ទិវាជាតិនៃការចងចាំនេះ និងដើរតួនាទីសំខាន់ក្នុងការអប់រំ និងទប់ស្កាត់អំពើប្រល័យពូជសាសន៍មិនឲ្យកើតមានសាជាថ្មីម្ដងទៀតក្នុងប្រទេសកម្ពុជា ។ គម្រោងនេះនឹងបានជាប្រយោជន៍សម្រាប់ដើមបណ្ដឹងរដ្ឋប្បវេណី ក៏ដូចជាប្រជាជនកម្ពុជា អាចជួបជុំគ្នា និងរៀបចំពិធីបុណ្យនានា ។

គម្រោងនេះត្រូវបានរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជាបានឯកភាព និងផ្ដល់ការអនុញ្ញាតជាគោលការណ៍តាមការស្នើសុំរបស់ដើមបណ្ដឹងរដ្ឋប្បវេណីរួចរាល់ហើយ និងបានកំណត់យកថ្ងៃទី២០ ខែឧសភា ជាទិវាជាតិនៃការចងចាំនៅក្នុងប្រតិទិនឈប់សម្រាកប្រចាំឆ្នាំ ។ រាជរដ្ឋាភិបាលនឹងចេញអនុក្រឹត្យនា

ពេលខាងមុខស្តីពីការបង្កើតទិវានេះ ព្រមទាំងអាចចេញសារាចរណែនាំ ឬសេចក្តីជូនដំណឹងទៅអាជ្ញាធរពាក់ព័ន្ធនឹងការអនុវត្តគម្រោងនេះ ។ សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីបានបញ្ជាក់ថា ដោយសារតែគម្រោងសំណងនេះពុំត្រូវការចំណាយថវិកា ដូច្នេះការអនុវត្តសំណងនេះអាចអនុវត្តបានគ្រប់ពេលវេលាទាំងអស់ ។

## ២) គម្រោងសាងសង់ចេតិយ ស្តូប ឬប៉ូដនីយដ្ឋានសាធារណៈ

គម្រោងសំណងទាក់ទងនឹងការកសាងស្តូបសាធារណៈ ជាគម្រោងដែលស្នើសុំដោយដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់នៅក្នុងសំណុំរឿង០០២/០១ ។ គម្រោងសាងសង់ស្តូបសម្រាប់រំឭកជាសាធារណៈ បង្កើតឡើងសម្រាប់តម្កល់អដ្ឋិធាតុរបស់អ្នកដែលស្លាប់បាត់បង់ជីវិតនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ និងសម្រាប់ដើមបណ្តឹងរដ្ឋប្បវេណី ជនរងគ្រោះ ជនដៃដល់ និងសាធារណជនមានឱកាសអុជធូប ធ្វើបុណ្យឧទ្ទិសដល់ជនរងគ្រោះដែលបានបាត់បង់ជីវិតនៅក្នុងរបបខ្មែរក្រហម ក្នុងលក្ខណៈយូរអង្វែង និងជាសមូហភាព ។

គម្រោងសំណងនេះ បង្កើតឡើងក្នុងគោលដៅដើម្បីស្តារកិត្តិយស សេចក្តីថ្លៃថ្នូរ ប៉ះប៉ូវការឈឺចាប់ផ្លូវចិត្ត និងផ្នែកសង្គមរបស់ដើមបណ្តឹងរដ្ឋប្បវេណី រំឭកដល់អ្នកដែលបានបាត់បង់ជីវិត លើកកម្ពស់ការយល់ដឹង និងការស្វែងយល់រួមគ្នាពីប្រវត្តិសាស្រ្តខ្មែរក្រហម ។ បន្ថែមពីលើនេះ គម្រោងនេះនឹងផ្សព្វផ្សាយដល់សហគមហ៍មូលដ្ឋានអំពីអង្គហេតុនៅក្នុងសំណុំរឿង០០២/០១ និងអនុញ្ញាតឲ្យដើមបណ្តឹងរដ្ឋប្បវេណីមានឱកាសក្នុងការនិយាយអំពីរឿងរ៉ាវផ្ទាល់ខ្លួន ក៏ដូចជាបទពិសោធជួរចត់នៅក្នុងរបបខ្មែរក្រហម ។ ការសាងសង់ស្តូបសាធារណៈ នឹងចូលរួមចំណែកលុបបំបាត់ការបែងចែកដែលបណ្តាលមកពីរបបខ្មែរក្រហមក្នុងគោលដៅផ្សះផ្សាសង្គម និងទប់ស្កាត់អំពើឃោរឃៅកុំឲ្យកើតមានឡើងជាថ្មីទៀត ។ ទោះបីជាយ៉ាងណា គម្រោងនេះពុំទាន់មានថវិកាគ្រប់គ្រាន់ដើម្បីអនុវត្តនៅឡើយ ។

## ៣) គម្រោងសាងសង់ប៉ូដនីយដ្ឋានសម្រាប់រំឭកចំពោះជនរងគ្រោះ

គម្រោងសាងសង់ប៉ូដនីយដ្ឋានសម្រាប់រំឭកចំពោះជនរងគ្រោះ ជាប្រភេទគម្រោងសិល្បៈ "ជូនចំពោះអ្នកដែលបានបាត់បង់ជីវិត" និងជាគំនិតដែលផ្តួចផ្តើមដោយសិល្បករសូនរូបខ្មែរ-បារាំងមួយរូបឈ្មោះ សេរ៉ា ។ សេរ៉ា ជាសិល្បករមួយរូបដែលត្រូវបានចាត់ចំណាត់ថ្នាក់ថា ជាសិល្បករប្រសើរបំផុតនៅប្រទេសបារាំងប្រចាំឆ្នាំ២០០២-២០១២ ។ គម្រោងនេះមានគោលដៅរំឭកឡើងវិញអំពីព្រឹត្តិការណ៍ជាក់ស្តែងនៃការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញនៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ដែលជាចំណុចចាប់ផ្តើមនៃវិនាសកម្មលើប្រជាជនកម្ពុជា ។ ការចាកចេញពីភ្នំពេញដោយការបង្ខិតបង្ខំពីសំណាក់ខ្មែរក្រហមបានបង្កើតនូវអនាគតមួយដែលមិនប្រាកដប្រជា និងរងទុក្ខវេទនាបំផុតនៅទីបញ្ចប់ ។ ទីតាំងដែលត្រូវសាងសង់ និងតម្កល់រូបចម្លាក់ គឺនៅទល់មុខស្ថានទូតបារាំង ត្រង់រង្វង់មូលជិតស្ពានជ្រោយចង្វារ ។ ការជ្រើសរើសយកទីតាំងនៅមុខស្ថានទូតបារាំងជាទីកន្លែងសម្រាប់តម្កល់រូបចម្លាក់ទាំងនេះ ដោយសារទីតាំងនោះ គឺជាចំណុចមួយនៃទីក្រុងភ្នំពេញ និងជាច្រកចេញនៃប្រជាជនជាច្រើនដែលត្រូវបានជម្លៀសចេញ និងព្រមទាំងជាទីកន្លែងដែលមនុស្សរាប់ពាន់នាក់បានទៅជ្រកកោននៅទីនោះ រួចចាកចេញពីក្រុងក្រោយគេបន្តស់ ។ ដើមបណ្តឹងរដ្ឋប្បវេណី ជាជនរងគ្រោះនៃការជម្លៀស និងដើមបណ្តឹងរដ្ឋប្បវេណីផ្សេងទៀតដែលមានសាច់ញាតិត្រូវបានជម្លៀសនៅពេលខ្មែរក្រហមចូលកាន់កាប់ទីក្រុងភ្នំពេញនឹងមានកន្លែងមួយ និងរូបចម្លាក់សម្រាប់គោរពបូជា និងធ្វើពិធីនានាតាមប្រពៃណីសាសនា និងជំនឿ ។ គម្រោងនេះទទួលបានការគាំទ្រថវិកាពីសំណាក់រដ្ឋាភិបាលប្រទេសបារាំង និងបុគ្គលផ្សេងៗទៀត ហើយគម្រោងសំណងនេះអាចអនុវត្តបាននៅគ្រប់ពេលវេលា ។

## ៤) គម្រោងកសាងស្តូបរំឭកដល់ជនរងគ្រោះរបបខ្មែរក្រហមសម្រាប់ប្រជាជនខ្មែរនៅប្រទេសបារាំង

គម្រោងនេះស្នើឡើងដោយប្រជាជនខ្មែររស់នៅប្រទេសបារាំង ដើម្បីអាចឲ្យពួកគាត់គោរពវិញ្ញាណក្ខន្ធជនរងគ្រោះដែលបានបាត់បង់ជីវិតនៅក្នុងរបបខ្មែរក្រហម ហើយប្រជាជនទូទៅក៏អាចទៅទីកន្លែងនោះដើម្បីបន់ស្រន់ និងឧទ្ទិសបានគ្រប់ពេលវេលា ។ បន្ថែមពីលើនេះ ស្តូបរំឭកវិញ្ញាណក្ខន្ធនឹងក្លាយជាទីកន្លែងជួបជុំរបស់ខ្មែរសម្រាប់ធ្វើបុណ្យ និងរំឭកវិញ្ញាណក្ខន្ធប្រចាំឆ្នាំ

ហើយស្តូបនេះរឹតតែសំខាន់ថែមទៀត ដោយសារប្រជាជនកម្ពុជាភាគច្រើនពុំអាចស្វែងរកឆ្អឹងសាច់ញាតិដែលបានស្លាប់ក្នុងរបបខ្មែរក្រហម ។ គម្រោងសំណងប្រភេទនេះ នឹងអនុញ្ញាតឲ្យជនរងគ្រោះអាចរំឭកដាអចិន្ត្រៃយ៍ និងសមូហភាពនូវអនុស្សាវរីយ៍ និងធ្វើឲ្យក្មេងជំនាន់ក្រោយ និងសាធារណជនមានការចាប់អារម្មណ៍ចំពោះ អ្វីដែលបានកើតឡើងនៅក្នុងរបបខ្មែរក្រហម ។ បច្ចុប្បន្នគម្រោងនេះទទួលបានការឯកភាពពីសាលាក្រុងប៉ារីស នៃប្រទេសបារាំងរួចហើយ ។ ប៉ុន្តែ ទោះបីជាយ៉ាងណាក្តី គម្រោងនេះកំពុងស្ថិតនៅដំណាក់កាលស្វែងរកថវិកាដើម្បីយកមកអនុវត្តនៅឡើយ ។

**ជំពូកទី២ ការស្តារនីតិសម្បទា**

នៅក្នុងជំពូកទាក់ទងនឹងគម្រោងសំណងស្តារនីតិសម្បទា មានការបែងចែកចេញជាពីរគម្រោង គឺគម្រោងចងក្រងសក្ខីកម្ម និងគម្រោងស្តីពីក្រុមជួយខ្លួនឯង ។ គម្រោងទាំងពីរនេះត្រូវបានបង្កើតឡើង ក្នុងគោលបំណងព្យាបាលការឈឺចាប់ផ្នែកផ្លូវចិត្តរបស់ជនរងគ្រោះ ដោយសារអំពើឧក្រិដ្ឋកម្មរបស់ខ្មែរក្រហម ។

**១) គម្រោងប្រើប្រាស់វិធីព្យាបាលតាមរបៀបចងក្រងជាសក្ខីកម្ម**

សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីបានបញ្ជាក់នៅក្នុងឯកសារស្នើសុំសំណង ដែលដាក់ជូនអង្គជំនុំជម្រះសាលាដំបូងថា ដើមបណ្តឹងរដ្ឋប្បវេណីភាគច្រើនបានស្នើសុំសំណងជាការព្យាបាលការឈឺចាប់ផ្នែកផ្លូវចិត្តដោយអ្នកជំនាញចិត្តសាស្ត្រចំពោះការទទួលរងរបួសផ្លូវចិត្តដោយសារអំពើឧក្រិដ្ឋកម្មក្នុងរបបខ្មែរក្រហម ។ គម្រោងសំណង "ការប្រើប្រាស់វិធីព្យាបាលតាមរបៀបចងក្រងសក្ខីកម្ម" នឹងធ្វើឡើងដោយការនិយាយរៀបរាប់ពីរឿងរ៉ាវដែលកើតឡើងចំពោះជនរងគ្រោះ សមាជិកគ្រួសារ និងសាច់ញាតិជាសាធារណៈ អំពីការឈឺចាប់ និងការទទួលរងរបួសផ្លូវចិត្តដោយសារអំពើឧក្រិដ្ឋកម្មក្នុងរបបខ្មែរក្រហម ។ ការរៀបរាប់របស់របស់ជនរងគ្រោះនឹងត្រូវបានចងក្រងជាឯកសារជាលាយលក្ខណ៍អក្សរដែលការចងក្រងនេះត្រូវបានហៅថាសក្ខីកម្ម ។ ក្នុងដំណាក់កាលបន្ទាប់ សក្ខីកម្មទាំងនោះនឹងត្រូវអានឮៗក្នុងអំឡុងពេលពិធីបុណ្យជាសាធារណៈទូទាំងប្រទេស ដោយធ្វើឡើងនៅជិតទីកន្លែងរស់នៅរបស់ដើមបណ្តឹងរដ្ឋប្បវេណី ។ ពិធីបុណ្យទាំងនោះនឹងអាចរាប់បញ្ចូលទាំងអ្នកដែលនៅរស់រានមានជីវិតពីរបបខ្មែរក្រហម សមាជិកគ្រួសារ សមាជិកក្នុងសហគមន៍ អ្នកដឹកនាំសាសនា អ្នកនយោបាយ និងអង្គការមិនមែនរដ្ឋាភិបាល ។ បន្ទាប់ពីពិធីបុណ្យ សក្ខីកម្មទាំងអស់នោះនឹងត្រូវប្រគល់ជូនដើមបណ្តឹងរដ្ឋប្បវេណី ។

គម្រោងសំណងប្រភេទនេះ នឹងជួយលើកកម្ពស់ការព្យាបាល និងការបង្រួបបង្រួមជាតិតាមរយៈការផ្តល់សំណងសមូហភាព និងផ្លូវចិត្ត និងបង្កើតសេវាសុខភាពផ្លូវចិត្ត និងរូបកាយសម្រាប់ដើមបណ្តឹងរដ្ឋប្បវេណីដែលទទួលរងការឈឺចាប់ ឬក៏មានជំងឺដោយសារមូលហេតុនៃឧក្រិដ្ឋកម្មដែលបានកើតឡើងក្នុងសម័យខ្មែរក្រហម ។ ម្យ៉ាងវិញទៀត គម្រោងសំណងនេះនឹងជួយធ្វើឲ្យប្រសើរឡើងនូវសុខុមាលភាពផ្លូវចិត្តរបស់ដើមបណ្តឹងរដ្ឋប្បវេណីក្នុងសំណុំរឿង០០២ ដោយស្តារនូវសេចក្តីថ្លៃថ្នូរ ភាពជឿជាក់ ថាមពល និងសមត្ថភាព និងអនុញ្ញាតឲ្យពួកគាត់ស្វែងរកនូវតុល្យភាពនៃអារម្មណ៍ និងដើម្បីគ្រប់គ្រងអតីតកាល និងការពិបាកខាងផ្នែកផ្លូវចិត្តដែលមានរហូតដល់បច្ចុប្បន្ន ។

**២) គម្រោងបង្កើតក្រុមជួយខ្លួនឯង**

គម្រោងបង្កើតក្រុមជួយខ្លួនឯង គឺមានលក្ខណៈដូចគ្នានឹងគម្រោងនៃការព្យាបាលផ្លូវចិត្តតាមរបៀបចងក្រងសក្ខីកម្ម ។ ក្រុមជួយខ្លួនឯង គឺជាការប្រមូលផ្តុំដោយស្ម័គ្រចិត្តនៃអ្នកដែលមានបំណងជម្នះនូវការឈឺចាប់របស់ខ្លួនស្វែងយល់ និងគ្រប់គ្រងអារម្មណ៍របស់ខ្លួនតាមរយៈការផ្លាស់ប្តូរយោបល់ និងបទពិសោធគ្នាទៅវិញទៅមក ។ គម្រោងនេះ មានគោលបំណងផ្តល់លទ្ធភាពឲ្យដើមបណ្តឹងរដ្ឋប្បវេណី ដែលជាជនរងគ្រោះនៃការជម្លៀសដោយបង្ខំនៅក្នុងសំណុំរឿង០០២ រៀបរាប់អំពីការឈឺចាប់របស់ខ្លួនក្នុងពេលជួបប្រជុំគ្នា ហើយតាមរយៈការរៀបរាប់នេះ ដើមបណ្តឹងរដ្ឋប្បវេណីនឹងអាចចាប់ផ្តើមដំណើរការព្យាបាលការឈឺចាប់ដែលបានទទួលរងគ្រោះ ។ គម្រោងនេះជាមធ្យោបាយក្នុងការបំបែកភាពឯកោ និងមនោសញ្ចេតនាបន្ទោសខ្លួនឯង តាមរយៈការបង្កើតឲ្យមានទំនាក់ទំនងជាមួយអ្នកដទៃ ។

ទាំងគម្រោងប្រើប្រាស់វិធីព្យាបាលតាមរបៀបចងក្រងជាសក្ខីកម្ម និងគម្រោងបង្កើតក្រុមជួយខ្លួនឯង ទទួលបន្ទុកអនុវត្តដោយអង្គការចិត្តសង្គមអន្តរវប្បធម៌ ធី.ភី.អូ) ដែលមានរយៈ

ពេល ១៦ ខែ ដោយទទួលថវិកាមួយផ្នែកពីរដ្ឋាភិបាលអាល្លឺម៉ង់ និងសប្បុរសជនមួយចំនួនទៀត ។

**ជំពូកទី៣ ការចងក្រងឯកសារ និងការអប់រំ**

គម្រោងសំណងនៅក្នុងជំពូកទី៣ ទាក់ទងនឹងការចងក្រងឯកសារ និងការអប់រំ ត្រូវបានបញ្ជាក់ដោយសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីថា គម្រោងសំណងនេះមានគោលដៅរក្សា និងជំរុញឲ្យមានការយល់ដឹងអំពីប្រវត្តិសាស្ត្រនៅក្នុងសម័យខ្មែរក្រហម និងបទពិសោធនីមួយៗរបស់ជនរងគ្រោះ ។ ជំពូកការចងក្រងឯកសារ និងការអប់រំនេះមានគម្រោងសំណងជាក់លាក់ចំនួន៧ ដែលជាគម្រោងសំណងស្នើសុំដោយសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី ក្រោយពីបានស្តាប់ការចង់បានរបស់ដើមបណ្តឹងរដ្ឋប្បវេណី ដែលជាជនរងគ្រោះនៃរបបខ្មែរក្រហម ។ គម្រោងសំណងទាំងនោះ រួមមាន៖

**១) គម្រោងតាំងពិព័រណ៍អចិន្ត្រៃយ៍**

២) គម្រោងតាំងពិព័រណ៍ចល័ត

៣) គម្រោងតាក់តែងជំពូកជាក់លាក់ស្តីពីការជម្លៀសប្រជាជនដោយបង្ខំ និងទីតាំងសម្លាប់មនុស្សនៅទួលពោធិ៍ជ្រៃ

៤) គម្រោងសាងសង់មជ្ឈមណ្ឌលសិក្សាសន្តិភាព

៥) គម្រោងបោះពុម្ពកូនសៀវភៅពីដំណើរការនៃសំណុំរឿង០០២/០១

៦) គម្រោងបោះពុម្ព និងផ្សព្វផ្សាយសាលក្រមទាំងមូល និងជាសង្ខេប

៧) គម្រោងផ្សាយឈ្មោះដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងគេហទំព័ររបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

**១) គម្រោងតាំងពិព័រណ៍អចិន្ត្រៃយ៍**

គម្រោងសំណងនេះ ត្រូវបានទាមទារដោយដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងសំណុំរឿង០០២ដែលនៅក្នុងនោះ មួយចំណែកធំបានរងគ្រោះដោយសារការជម្លៀសដោយបង្ខំ ដែលបានកើតឡើងនៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ និងថ្ងៃបន្តបន្ទាប់ ។ ការជម្លៀសនេះ គឺជាកម្មវត្ថុនៃការជំនុំជម្រះក្នុងសំណុំរឿង០០២/០១ ។

គម្រោងនេះមានគោលដៅថែរក្សា លើកតម្កើងរឿងរ៉ាវ និងបទពិសោធដែលកើតមាននៅអំឡុងពេលនៃរបបខ្មែរក្រហម ដោយថែរក្សានូវភស្តុតាងគ្រប់ប្រភេទនៅក្នុងទីតាំងជាក់លាក់ ហើយការថែរក្សាភស្តុតាងក្នុងរយៈពេលវែងនឹងចូលរួមក្នុងការផ្សព្វផ្សាយពីប្រវត្តិសាស្ត្រ ។ គម្រោងនេះរៀបចំឡើងដើម្បីជាការទទួលស្គាល់ដល់ជនរងគ្រោះ និងជាមធ្យោបាយសម្រាប់ដើមបណ្តឹងរដ្ឋប្បវេណីអាចផ្តល់នូវបទពិសោធសម្រាប់មនុស្សជំនាន់ក្រោយ និងសាធារណជនជាតិ និងអន្តរជាតិ ។

គម្រោងនេះក៏មានគោលដៅអប់រំ ដោយបង្ហាញបានពីបទពិសោធដែលមាននៅក្នុងអតីតកាល និងផ្សព្វផ្សាយទៅកាន់មនុស្សជំនាន់ក្រោយសម្រាប់ទុកជាចំណេះដឹង និងចូលរួមនៅក្នុងការផ្សះផ្សាជាតិ ។ បន្ថែមពីលើនេះ គម្រោងនេះនឹងអនុញ្ញាតឲ្យដើមបណ្តឹងរដ្ឋប្បវេណី និងជនរងគ្រោះជាច្រើនផ្សេងទៀត ចងក្រង ចែករំលែក និងយល់ដឹងអំពីរឿងរ៉ាវទាក់ទងនឹងរបបខ្មែរក្រហម ហើយគម្រោងនេះក៏នឹងបង្កើតឲ្យមានកម្មវិធីអប់រំអំពីប្រវត្តិសាស្ត្រមួយ និងធ្វើឲ្យរឿងរ៉ាវរបស់ដើមបណ្តឹងរដ្ឋប្បវេណីត្រូវបានផ្សព្វផ្សាយទៅដល់សាធារណជនទូទៅដែរ ។

គម្រោងតាំងពិព័រណ៍អចិន្ត្រៃយ៍ ជាគម្រោងដែលនឹងត្រូវអនុវត្តដោយមជ្ឈមណ្ឌលឯកសារកម្ពុជាដែលនឹងត្រូវបំពេញការកិច្ចយ៉ាងជិតស្និទ្ធជាមួយក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ នៅក្នុងក្របខណ្ឌនៃការថែរក្សា និងអភិវឌ្ឍសារមន្ទីរចំនួន២៤ខេត្ត-ក្រុងនៅទូទាំងព្រះរាជាណាចក្រកម្ពុជា ។ សកម្មភាពរបស់មជ្ឈមណ្ឌលឯកសារកម្ពុជាត្រូវបានឯកភាពដោយរាជរដ្ឋាភិបាលកម្ពុជាក្នុងការចូលរួមបង្កើតបណ្តាញថែរក្សា និងលើកតម្កើងវប្បធម៌ ដូច្នេះ មជ្ឈមណ្ឌលឯកសារកម្ពុជានឹងចូលរួមក្នុងការរៀបចំឯកសារ និងការតាំងពិព័រណ៍អំពីរបបខ្មែរក្រហមនៅគ្រប់ខេត្ត-រាជធានីនៃព្រះរាជាណាចក្រកម្ពុជា ។

ជាបឋមការតាំងពិព័រណ៍អចិន្ត្រៃយ៍នឹងត្រូវធ្វើនៅសារមន្ទីរនៃខេត្តចំនួន៥ ដែលជាបឋមចាប់ផ្តើមពីខេត្តបាត់ដំបង និងបន្ទាយមានជ័យ បន្ទាប់មកនឹងមានការរៀបចំដូចគ្នានៅខេត្តកំពង់ធំ តាកែវ និងស្វាយរៀង ។ ការជ្រើសរើសយកបណ្តាខេត្តទាំងនេះដើម្បីអនុវត្តគម្រោង ដោយសារដំណើរការ និងរចនាសម្ព័ន្ធនៃសារមន្ទីរនៅមានលក្ខណៈល្អច្រើន ។ បន្ថែមពីលើនេះ ទីតាំងដែលត្រូវ

ជ្រើសរើសយកមក ធ្វើពិព័រណ៍ទាំងអស់នេះ មានភាពជាប់ពាក់ព័ន្ធនឹងវិសាលភាពនៃសំណុំរឿង០០២/០១ ដោយមានជនរងគ្រោះដោយសារការជម្លៀសត្រូវបានបញ្ជូនទៅទីកន្លែងទាំងនោះ ។ ទោះបីជាខ្លឹមសារនៃការតាំងពិព័រណ៍ អាចផ្តោតលើបញ្ហាផ្សេងៗនៃប្រវត្តិសាស្ត្រខ្មែរក្រហម ប៉ុន្តែប្រធានបទជាដំបូងនឹងផ្តោតជាសំខាន់ទៅលើការជម្លៀសដោយបង្ខំនៅក្នុងដំណាក់កាលទីមួយ និងដំណាក់កាលទីពី ព្រមទាំងអង្គហេតុដែលកើតឡើងនៅទួលពោធិ៍ជ្រៃ ។

គម្រោងនេះនឹងត្រូវអនុវត្តក្នុងរយៈពេល១៦ខែ ដោយចាប់ផ្តើមពីខែកញ្ញា ឆ្នាំ២០១៣ រហូតដល់ ខែធ្នូ ឆ្នាំ២០១៤ ។ ចន្លោះពីខែកញ្ញា ឆ្នាំ២០១៣ រហូតដល់ខែមេសា ឆ្នាំ២០១៤ ជាដំណាក់កាលរៀបចំសម្ភារ និងការតាំងពិព័រណ៍ ហើយការបើកដំណើរការជាក់ស្តែងនៃការតាំងពិព័រណ៍ គឺចាប់ផ្តើមពីខែឧសភា រហូតដល់ខែធ្នូ ឆ្នាំ២០១៤ ។ ដើមបណ្តឹងរដ្ឋប្បវេណីមួយចំនួននឹងចូលរួមក្នុងការរៀបចំការតាំងពិព័រណ៍នេះ ហើយពួកគាត់នឹងរៀបរាប់អំពីរឿងរ៉ាវរបស់ខ្លួនសម្រាប់ការចងក្រង និងចូលរួមចែករំលែកអំពីអ្វីដែលគាត់បានជួបប្រទះក្នុងរបបខ្មែរក្រហម រួមទាំងដំណើរការកាត់ក្តីផង ។

ការតាំងពិព័រណ៍អចិន្ត្រៃយ៍នេះ នឹងក្លាយជាសំណងសម្រាប់ដើមបណ្តឹងរដ្ឋប្បវេណីក្នុងសំណុំរឿង០០២ ។ មូលនិធិសម្រាប់ការអនុវត្តគម្រោងសំណងនេះទទួលបានពីរដ្ឋាភិបាលអាល្លឺម៉ង់ ។

### ២) គម្រោងតាំងពិព័រណ៍ចល័ត

គម្រោងសំណងទាក់ទងនឹងការតាំងពិព័រណ៍ចល័តមានគោលបំណងជំរុញឲ្យមានការទទួលស្គាល់ជាសាធារណៈនូវការទទួលរងទុក្ខរបស់ដើមបណ្តឹងរដ្ឋប្បវេណីក្នុងអំឡុងពេលនៃរបបខ្មែរក្រហម ជាពិសេសទាក់ទងនឹងការជម្លៀសដោយបង្ខំ និងដើម្បីពង្រឹងការចូលរួមរបស់ប្រជាជនកម្ពុជាក្នុងការឆ្លុះបញ្ចាំងពីអតីតកាលក្នុងរបបខ្មែរក្រហម និងធ្វើយ៉ាងណាដើម្បីទប់ស្កាត់កុំឲ្យមានអំពើបែបនេះកើតឡើងសាជាថ្មីម្តងទៀត ។ បន្ថែមពីលើនេះ គម្រោងតាំងពិព័រណ៍ចល័តត្រូវបានរំពឹងថានឹងចូលរួមក្នុងការលើកតម្កើងវប្បធម៌សន្តិភាព និងការផ្សះផ្សាជាតិ តាមរយៈការផ្តល់សំណងផ្លូវចិត្ត និងសមូហភាព ។ ដើមបណ្តឹងរដ្ឋប្បវេណីនឹងទទួលបានការឧបត្ថម្ភផ្នែកសម្ភារក្នុងអំឡុងពេលនៃការតាំងពិព័រណ៍ និងអាចចូលរួមក្នុងការរចនាការតាំងពិព័រណ៍ និងសកម្មភាពអប់រំផ្សេងៗ ។ ចំពោះដើមបណ្តឹងរដ្ឋប្បវេណីដែលពុំទាន់មានពាក់ព័ន្ធនឹងសកម្មភាពផ្សព្វផ្សាយ ដូចជា ដើមបណ្តឹងរដ្ឋប្បវេណីជាស្ត្រី និងក្រុមជនជាតិភាគតិច ក៏នឹងត្រូវអញ្ជើញឲ្យចូលរួមក្នុងការតាំងពិព័រណ៍នេះដែរ ។

គម្រោងតាំងពិព័រណ៍ចល័តនេះ ជាគម្រោងដែលនឹងត្រូវអនុវត្តដោយអង្គការយុវសន្តិភាព និងអង្គការក្តីករុណានៅលើទីតាំងចំនួន៦កន្លែងដែលត្រូវបានជ្រើសរើសសម្រាប់ជាគោលដៅនៃការអនុវត្តគម្រោងសំណងនេះ ។ ការអនុវត្តគម្រោងនេះត្រូវបានបែងចែកជាពីរដំណាក់កាល ។ ដំណាក់កាលទី១ មានដូចជាការៀបចំរចនាអំពីគំនិតនៃការតាំងពិព័រណ៍ ការផលិតឯកសារវីដេអូ ការតាំងពិព័រណ៍តាមបន្ទះក្តារ ផលិតសម្ភារទាក់ទងនឹងការផ្តល់ព័ត៌មាន ការអប់រំ និងការទំនាក់ទំនងរៀបចំរចនាកម្មវិធីគម្រោង សម្រាប់វេទិកាសាធារណៈ សិក្ខាសាលា ការសម្តែងល្ខោន តន្ត្រី បុណ្យទាន និងការបញ្ចាំងកុន និងការផលិតឯកសារវីដេអូស្តីពីការតាំងពិព័រណ៍ ។ ដំណាក់កាលទី២ អង្គការទាំងពីរនឹងបង្កើតក្រុមការងារ ដោយឡែករៀងៗខ្លួនដើម្បីអនុវត្តគម្រោងទាំងនេះ ។ មូលនិធិសម្រាប់អនុវត្តគម្រោងនេះទទួលបានពីរដ្ឋាភិបាលរបស់អាល្លឺម៉ង់ ។

### ៣) គម្រោងតាក់តែងជំពូកជាក់លាក់ស្តីពីការជម្លៀសប្រជាជនដោយបង្ខំ និងទីតាំងសម្លាប់មនុស្សទួលពោធិ៍ជ្រៃ

គម្រោងសំណងស្តីពីការតាក់តែងជំពូកជាក់លាក់ស្តីពីការជម្លៀសប្រជាជនដោយបង្ខំ និងទីតាំងសម្លាប់មនុស្សនៅទួលពោធិ៍ជ្រៃ ត្រូវបានស្នើសុំដោយដើមបណ្តឹងរដ្ឋប្បវេណីដើម្បីដាក់បញ្ចូលទៅក្នុងសៀវភៅបណ្តុះបណ្តាលគ្រូទទួលបន្ទុកបង្រៀនមុខវិជ្ជាពាក់ព័ន្ធនឹងប្រវត្តិសាស្ត្រខ្មែរក្រហម មានគោលដៅធ្វើឲ្យមានការទទួលស្គាល់ជាផ្លូវការ និងជាអចិន្ត្រៃយ៍នៃប្រវត្តិសាស្ត្ររបបកម្ពុជាប្រជាធិបតេយ្យ និងរឿងរ៉ាវរបស់ដើមបណ្តឹងរដ្ឋប្បវេណី ។ ម្យ៉ាងវិញទៀត សំណងប្រភេទនេះនឹងជួយលើកតម្កើងការអប់រំអំពីរឿងហេតុនៃប្រវត្តិសាស្ត្រ និងអប់រំយុវជនជំនាន់ក្រោយឲ្យមានគំនិតចេះទទួលខុសត្រូវដោយថ្លៃថ្នូរដើម្បីទប់ស្កាត់មិនឲ្យកើតមានឧក្រិដ្ឋកម្មដូចជាអ្វីដែលធ្លាប់កើតមាននៅក្នុងរបបខ្មែរក្រហម ។

ជំពូកនេះនឹងត្រូវរៀបចំ និងចែកចាយដោយមជ្ឈមណ្ឌលឯកសារកម្ពុជា ។ មជ្ឈមណ្ឌលឯកសារកម្ពុជា បានបោះពុម្ព ចែកចាយ និងព្រមទាំងដាក់ឲ្យអនុវត្តសៀវភៅសម្រាប់បណ្តុះបណ្តាលគ្រូបង្រៀនរួចមកហើយ ។ ដូច្នេះ ជំពូកស្តីពីការជម្លៀសប្រជាជនដោយបង្ខំ និងទីតាំងសម្លាប់មនុស្សនៅទួលពោធិ៍ជ្រៃ នឹងត្រូវបញ្ចូលទៅក្នុងសៀវភៅសម្រាប់បណ្តុះបណ្តាលគ្រូ បន្ទាប់ពីមានសេចក្តីសម្រេចរបស់អង្គជំនុំជម្រះ ។ ជំពូកនេះ មានចំណងជើងថា "ការចូលរួមរបស់ដើមបណ្តឹងរដ្ឋប្បវេណី និងអង្គហេតុវិនិច្ឆ័យក្នុងករណី០០២/០១" ដោយចែកចេញជា៤មេរៀន និងមាន១៦ទំព័រ ។ មេរៀនទី១ និយាយអំពីគោលនយោបាយគោលបំណង ព្រមទាំងដំណាក់កាលផ្សេងៗនៃការជម្លៀសប្រជាជន ។ មេរៀនទី២ លើកឡើងការរៀបរាប់របស់ដើមបណ្តឹងរដ្ឋប្បវេណីទាក់ទងនឹងបទពិសោធដែលពួកគាត់បានជួបប្រទះក្នុងអំឡុងពេលនៃការជម្លៀស ។ មេរៀនទី៣ លើកឡើងអំពីផលវិបាកនៃការជម្លៀសដោយបង្ខំមកលើជនរងគ្រោះ ។ ចំពោះមេរៀនទី៤ អត្ថាធិប្បាយអំពីទីតាំងសម្លាប់មនុស្សនៅទួលពោធិ៍ជ្រៃ ដោយផ្តោតជាពិសេសលើស្ថានភាព និងការសម្លាប់រង្គាលនៅទីនោះ ព្រមទាំងបទពិសោធរបស់ដើមបណ្តឹងរដ្ឋប្បវេណី និងសក្ខីកម្មរបស់ដើមបណ្តឹងរដ្ឋប្បវេណី ។

ក្រៅពីគម្រោងសំណងដទៃផ្សេងទៀតគម្រោងសំណងស្តីពីការតាក់តែងជំពូកដាក់លាក់ស្តីពីការជម្លៀសប្រជាជនដោយបង្ខំ និងទីតាំងសម្លាប់មនុស្សនៅទួលពោធិ៍ជ្រៃអាចអនុវត្តបានលុះត្រាមានសេចក្តីសម្រេចពីអង្គជំនុំជម្រះលើអង្គហេតុនៃសំណុំរឿង ០០២/០១ជាមុនសិន ។ អង្គជំនុំជម្រះសាលាដំបូងនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាបានបញ្ជាក់ថា អង្គជំនុំជម្រះពុំទាន់ទទួលស្គាល់គម្រោងនេះជាផ្លូវការបាននៅឡើយទេ ដោយសារតែគម្រោងសំណងនេះមានពាក់ព័ន្ធនឹងអង្គហេតុដែលមិនទាន់ត្រូវបានវិនិច្ឆ័យ ។ នៅពេលរកឃើញពិរុទ្ធភាពរបស់ជនជាប់ចោទ និងមានសាលក្រមផ្តន្ទាទោស អង្គជំនុំជម្រះនឹងមានធាតុផ្សំគ្រប់គ្រាន់សម្រាប់ទទួលស្គាល់គម្រោងនេះថាជាសំណង ។

### ៤) គម្រោងសាងសង់មជ្ឈមណ្ឌលសិក្សាសន្តិភាព

គម្រោងសំណងសាងសង់មជ្ឈមណ្ឌលសិក្សាសន្តិភាពត្រូវបានស្នើឡើងក្នុងគោលដៅអភិវឌ្ឍការពិចារណា និងបែបបទសម្រាប់ថែរក្សាដំណើរការសន្តិភាព និងអភិបាលកិច្ចល្អ និងអនុញ្ញាតឲ្យមានការឆ្លើយឆ្លងរវាងជនរងគ្រោះ និងយុវជនដើម្បីជំនួយដល់ការពិចារណារបស់យុវជនជំនាន់ក្រោយ និងទប់ស្កាត់មិនឲ្យកើតមានសាជាថ្មីនូវអំពើឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងអំពើហិង្សាធ្ងន់ធ្ងរ ។ គម្រោងនេះនឹងត្រូវអនុវត្តនៅក្នុងខេត្តបាត់ដំបង ។ ដើមបណ្តឹងរដ្ឋប្បវេណីនឹងត្រូវអញ្ជើញឲ្យចូលរួមចែករំលែកអំពីបទពិសោធដែលធ្លាប់បានជួបប្រទះពាក់ព័ន្ធនឹងការជម្លៀស និងការធ្វើទុក្ខបុកម្នេញលើជនរងគ្រោះ ។ ជាពិសេសពាក់ព័ន្ធនឹងខេត្តបាត់ដំបង ខេត្តពោធិ៍សាត់ ក្នុងសម័យកម្ពុជាប្រជាធិបតេយ្យក្នុងក្របខណ្ឌនៃការចងក្រងឯកសារ និងមានពន្យល់អំពីអង្គហេតុដែលបានកើតឡើង រួមជាមួយនឹងដំណើរការវិវឌ្ឍនៅសាលាក្តីខ្មែរក្រហមដែរ ។ មជ្ឈមណ្ឌលនេះនឹងក្លាយជាទីកន្លែងមួយសម្រាប់ចងក្រង ផ្សព្វផ្សាយ បណ្តុះបណ្តាល ពិភាក្សា និងអប់រំ ។

ចំពោះទីកន្លែងសម្រាប់សាងសង់មជ្ឈមណ្ឌលនេះ នឹងត្រូវធ្វើនៅអតីតកន្លែងសម្លាប់មនុស្សរួមនៅអំឡុងពេលនៃរបបកម្ពុជាប្រជាធិបតេយ្យ និងបច្ចុប្បន្នជាដីរបស់សហគមន៍ ។ សកម្មភាពផ្សេងទៀតរបស់គម្រោងនេះ មានដូចជា ការបណ្តុះបណ្តាលសមត្ថភាព និងអភិបាលកិច្ចល្អ ការរៀបចំវេទិកាសាធារណៈមួយលើកសម្រាប់មនុស្ស១០០នាក់ បណ្តុំការងារហត្ថកម្ម ការបង្កើតនិងកែលម្អប្រព័ន្ធគ្រប់គ្រងបណ្ណាល័យ ការបោះជំរំរបស់យុវជន និងការចងក្រងឯកសារអំពីទីកន្លែងសម្លាប់មនុស្ស ។

គម្រោងនេះនឹងអនុវត្តដោយអង្គការយុវសន្តិភាព ដោយមានរយៈពេល២ឆ្នាំ គិតចាប់ពីខែកញ្ញា ឆ្នាំ២០១៣ ដល់ខែសីហា ឆ្នាំ២០១៥ ដោយមានជំនួយហិរញ្ញវត្ថុពីអង្គការស៊ីសសម្រាប់ការអភិវឌ្ឍ ។

### ៥) គម្រោងបោះពុម្ពកូនសៀវភៅពីដំណើរការនៃសំណុំរឿង០០២/០១

គម្រោងសំណងនេះ ត្រូវបានស្នើឡើងដោយដើមបណ្តឹងរដ្ឋប្បវេណី ដើម្បីបោះពុម្ពជាកូនសៀវភៅដែលមានប្រើប្រាស់ពាក្យពេចន៍សាមញ្ញ និងងាយយល់ព្រមទាំងមានគំនូរ និងរូបភាពជាច្រើនដែលអាចឲ្យយល់បានដោយងាយអំពីដំណើរការវិវឌ្ឍ

នៅសាលាក្តីខ្មែរក្រហម ។ សៀវភៅនេះនឹងជួយឲ្យបុគ្គលម្នាក់ៗ ស្គាល់ពីព្រឹត្តិការណ៍នៃរបបកម្ពុជាប្រជាធិបតេយ្យ និងយល់ពីប្រវត្តិសាស្ត្រដើម្បីជាមូលដ្ឋានក្នុងការពិចារណា ។ កូនសៀវភៅនេះក៏ជាការឧទ្ទិសដល់ដើមបណ្តឹងរដ្ឋប្បវេណី ដែលបានចូលរួមក្នុងនីតិវិធីតុលាការក្នុងនាមឲ្យជនរងគ្រោះទាំងឡាយ ។

គម្រោងបោះពុម្ពកូនសៀវភៅពីដំណើរការនៃសំណុំរឿង ០០២/០១ នឹងត្រូវអនុវត្តដោយអង្គការគណៈកម្មាធិការប្រព្រឹត្តិកម្មនៃអង្គការ-សមាគមការពារសិទ្ធិមនុស្សកម្ពុជា ហៅកាត់ថា “CHRAC” ដែលជាបណ្តុំអង្គការ និងសមាគមចំនួន២១រួមគ្នា ដោយទទួលបានការផ្តល់ថវិកាពីអង្គការសហប្រតិបត្តិការរបស់អាល្លឺម៉ង់ ។

### ៦) គម្រោងបោះពុម្ព និងផ្សព្វផ្សាយសាលក្រមទាំងមូល និងជាសង្ខេប

ចំពោះគម្រោងសំណងទាក់ទងនឹងការបោះពុម្ព និងផ្សព្វផ្សាយសាលក្រមទាំងមូល និងជាសង្ខេប ត្រូវបានដើមបណ្តឹងរដ្ឋប្បវេណីស្នើសុំអង្គជំនុំជម្រះចាត់ទុកគម្រោងនេះថាជាសំណងសម្រាប់ដើមបណ្តឹងរដ្ឋប្បវេណី ។ ដើមបណ្តឹងរដ្ឋប្បវេណីក៏បានស្នើឲ្យផ្នែកកិច្ចការសាធារណៈរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ជាអ្នកអនុវត្តគម្រោងនេះ ដោយបោះពុម្ព និងចែកចាយសាលក្រមទាំងមូល និងសាលក្រមសង្ខេបនៃសំណុំរឿង ០០២/០១ ចែកជូនដើមបណ្តឹងរដ្ឋប្បវេណី សាធារណជន និងអ្នកមានវិជ្ជាជីវៈផ្នែកច្បាប់ ។

គម្រោងសំណងនេះនឹងចូលរួមចំណែកលើកកម្ពស់ការយល់ដឹងរបស់ប្រជាពលរដ្ឋអំពីកិច្ចដំណើរការនីតិវិធីរបស់តុលាការ និងចូលរួមចំណែកផ្សះផ្សាជាតិ ។ ទោះបីជាយ៉ាងនេះក្តី ថវិកាសម្រាប់យកមកបោះពុម្ពផ្សាយសាលក្រមនេះ នៅពុំទាន់មានគ្រប់គ្រាន់នៅឡើយទេ ។

គម្រោងនេះនឹងត្រូវចំណាយពេលអនុវត្តរយៈពេល៤ខែ បន្ទាប់ពីមានការទទួលស្គាល់ពីសំណាក់អង្គជំនុំជម្រះថាជាសំណង ។

### ៧) គម្រោងផ្សាយឈ្មោះដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងគេហទំព័ររបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

គម្រោងសំណងស្តីពីការផ្សព្វផ្សាយឈ្មោះដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងគេហទំព័ររបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ត្រូវបានស្នើសុំដោយដើមបណ្តឹងរដ្ឋប្បវេណីដើម្បីបង្ហាញអំពីការចូលរួម និងលើកតម្លៃការចូលរួមរបស់ដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងកិច្ចដំណើរការរបស់តុលាការ ។ ការផ្សាយនេះមានរួមបញ្ចូលទាំងឈ្មោះជាភាសាខ្មែរ អក្សរឡាតាំង លេខដើមបណ្តឹងរដ្ឋប្បវេណីដែលចេញដោយអង្គភាពគាំពារជនរងគ្រោះ និងធាតុចាំបាច់ផ្សេងទៀតដែលងាយស្រួលក្នុងការស្វែងរកឈ្មោះ ។

គម្រោងនេះនឹងត្រូវចំណាយពេលអនុវត្តរយៈពេល៣ខែ បន្ទាប់ពីមានសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង ដោយមានការសហការរវាងអង្គភាពគាំពារជនរងគ្រោះ និងផ្នែកកិច្ចការសាធារណៈនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។

ការកត់សម្គាល់របស់អង្គជំនុំជម្រះលើគម្រោងសំណងដែលស្នើសុំដូចបានបញ្ជាក់ គម្រោងសំណងទាំងអស់ដែលរៀបរាប់ខាងលើពុំទាន់ក្លាយជាសំណងផ្លូវការសម្រាប់ដើមបណ្តឹងរដ្ឋប្បវេណីនៅឡើយទេ ។ ការរៀបរាប់លម្អិតអំពីគម្រោងនីមួយៗរបស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីនាពេលនេះ គឺធ្វើឡើងក្នុងគោលបំណងដើម្បីជូនដំណឹង និងធានាអំពីវិសាលភាព និងប្រសិទ្ធភាពនៃគម្រោងសំណងដែលបានស្នើសុំ និងដើម្បីទុកឱកាសឲ្យអង្គជំនុំជម្រះសាលាដំបូងមានលទ្ធភាពពិនិត្យមើល និងផ្តល់ការណែនាំថា តើសំណងដែលបានស្នើសុំនោះស្របជាមួយក្របខ័ណ្ឌគតិយុត្តិរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាដែរឬយ៉ាងណា ។ ប្រសិនបើអង្គជំនុំជម្រះសាលាដំបូងពិនិត្យឃើញថា គម្រោងសំណងដែលស្នើសុំពុំមានលក្ខណៈច្បាស់លាស់គ្រប់គ្រាន់ដើម្បីអនុវត្តទេ គម្រោងសំណងទាំងនោះនឹងពុំត្រូវបានទទួលស្គាល់ដោយអង្គជំនុំជម្រះថាជាសំណងសម្រាប់ដើមបណ្តឹងរដ្ឋប្បវេណីក្នុងសំណុំរឿង០០២/០១ឡើយ ។

អង្គជំនុំជម្រះសាលាដំបូងបានកត់សម្គាល់ថា គម្រោងសំណងមួយចំនួននៅពុំទាន់មានលក្ខណៈច្បាស់លាស់គ្រប់គ្រាន់ដើម្បីអាចយកទៅអនុវត្តបាននៅឡើយ ដោយសារនៅខ្វះសេចក្តីពិពណ៌នាលម្អិត ឬខ្វះការបង្ហាញពីភស្តុតាងនៃការយល់ព្រម និងសហប្រតិបត្តិការរបស់ភាគីទីបី ។ គម្រោងទាំងនោះមានដូចជា គម្រោងស្នើសុំស្តូបរំឭកជាសាធារណៈ និងគម្រោងសាងសង់

បូជនីយដ្ឋាន ដែលនៅពុំទាន់មានការបញ្ជាក់ច្បាស់អំពីថវិកា និងគម្រោងប្លង់ ឬគំរូបំព្រួញ និងជាពិសេស ពុំទាន់មានឯកសារបង្ហាញអំពីការអនុញ្ញាតរបស់អាជ្ញាធររាជធានីភ្នំពេញឲ្យសាងសង់បូជនីយដ្ឋាននៅលើទីតាំងដែលបានស្នើសុំដែលជាទ្រព្យសម្បត្តិសាធារណៈនៅឡើយ ។

អង្គជំនុំជម្រះបានបញ្ជាក់ជូនសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីថា អង្គជំនុំជម្រះមិនអាចធ្វើការយល់ព្រមលើគម្រោងសំណងណាមួយដែលមានការធានាមូលនិធិត្រឹមតែមួយផ្នែកនោះទេ និងថា គម្រោងសំណងដែលមិនមានលក្ខណៈច្បាស់លាស់គ្រប់គ្រាន់ អាចនឹងពុំត្រូវបានទទួលស្គាល់ដោយអង្គជំនុំជម្រះទេ ។ ទោះបីជាយ៉ាងណាក្តី អង្គជំនុំជម្រះសាលាដំបូងបានផ្តល់ឱកាស និងពេលវេលាបន្ថែមជូនសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីដើម្បីបំពេញលក្ខខណ្ឌតម្រូវនៃវិធានផ្ទៃក្នុងចំពោះគម្រោងសំណងដែលអង្គជំនុំជម្រះសាលាដំបូងយល់ថានៅពុំទាន់មានលក្ខណៈគ្រប់គ្រាន់ក្នុងការយកទៅអនុវត្តរហូតដល់ថ្ងៃទី៣១ ខែមីនា ឆ្នាំ២០១៤ ។ ព័ត៌មានណាមួយដែលផ្តល់ជូននៅក្រោយកាលបរិច្ឆេទនេះ អង្គជំនុំជម្រះបញ្ជាក់ថានឹងមិនយកមកពិចារណានោះទេ ។

ដើម្បីធានាថាគម្រោងសំណងទាំងអស់ដែលស្នើសុំនឹងត្រូវទទួលយកដោយអង្គជំនុំជម្រះ ទាំងសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី និងអង្គភាពគាំពារជនរងគ្រោះ ចាំបាច់ត្រូវខិតខំប្រឹងប្រែងឲ្យអស់ពីលទ្ធភាពក្នុងការស្វែងរកកិច្ចសហប្រតិបត្តិការទាំងផ្នែកបច្ចេកទេស និងថវិកាបន្ថែមទៀតពីភាគីទីបីណាមួយ ។

**សន្និដ្ឋាន**

ជាការពិត គម្រោងសំណងមួយចំនួននៅពុំទាន់មានមូលនិធិគ្រប់គ្រាន់ដើម្បីយកទៅអនុវត្តនៅឡើយ ប៉ុន្តែអង្គជំនុំជម្រះពុំគួរបដិសេធគម្រោងសំណងណាមួយដែលស្នើសុំដោយដើមបណ្តឹងរដ្ឋប្បវេណី នៅមុនពេលមានសេចក្តីសម្រេចអំពីពិរុទ្ធភាពរបស់ជនជាប់ចោទទេ ។ អង្គជំនុំជម្រះអាចបន្ទាប់ឲ្យពិរុទ្ធជនចេញថ្លៃសោហ៊ុយក្នុងការអនុវត្តគម្រោងសំណងដែលនៅពុំទាន់មានថវិកាគ្រប់គ្រាន់ក្នុងករណីដែលអង្គជំនុំជម្រះរកឃើញថាជនជាប់ចោទពិតជាមានពិរុទ្ធភាពដូចមានចែងក្នុងវិធាន(២៣ស្ទួនបួន៣) នៃវិធានផ្ទៃក្នុង ។

ប្រសិនបើ អង្គជំនុំជម្រះរកឃើញថា ពិរុទ្ធជនជាជនក្រីក្រគ្មានលទ្ធភាពក្នុងការចេញសោហ៊ុយ អនុវត្តគម្រោងសំណងដែលស្នើសុំអង្គជំនុំជម្រះអាចសម្រេចប្រគល់ភារកិច្ចអនុវត្តគម្រោងសំណងទាំងនោះ ទៅឲ្យតតិយជនដែលមានថវិកាគ្រប់ និងស្ម័គ្រចិត្តទទួលយកទៅអនុវត្ត ។ ចំណែកឯគម្រោង សំណងដែលពុំទាន់មានថវិកាគ្រប់គ្រាន់ អង្គជំនុំជម្រះអាចទុកលទ្ធភាពឲ្យអង្គភាពគាំពារជនរងគ្រោះស្វែងរកថវិកាបន្ថែមដើម្បីយកទៅអនុវត្ត ។

ដូច្នេះ អង្គជំនុំជម្រះគួរតែសម្រេចទទួលស្គាល់គម្រោងសំណងទាំងអស់ដែលស្នើឡើងដោយសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីថាជាសំណងសម្រាប់ដើមបណ្តឹងរដ្ឋប្បវេណីក្នុងសំណុំរឿង ០០២/០១ ។

**លឹម ឋ័យផ័ត្ត**

# រឿងរ៉ាវពិតដើម្បីប្រវត្តិសាស្ត្រ

មជ្ឈមណ្ឌលឯកសារកម្ពុជាសង្ឃឹមថា ប្រជាជនកម្ពុជាគ្រប់រូបដែលធ្លាប់ឆ្លងកាត់របបខ្មែរក្រហមបាន និងកំពុងសរសេរអត្ថបទឬសៀវភៅអំពីរឿងរ៉ាវពិតផ្ទាល់ខ្លួន ហើយនឹងផ្ញើមកមជ្ឈមណ្ឌលឯកសារកម្ពុជាតាមអាសយដ្ឋានខាងក្រោម ៖

ផ្ទះលេខ៦៦ មហាវិថីព្រះសីហនុ ភ្នំពេញ

ព្រះរាជាណាចក្រកម្ពុជា

ទូរស័ព្ទលេខៈ (៨៥៥) (២៣) ២១១ ៨៧៥

ទូរស័ព្ទលេខៈ (៨៥៥) (១៦) ៨៧៦ ៦៩២

ទូរសារលេខៈ (៨៥៥) (២៣) ២១០ ៣៥៨

Email: truthsocheat@dccam.org

Home page: www.dccam.org

# ស្វែងយល់អំពីគេហទំព័រឃ្លាំមើលការវិវឌ្ឍរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

## www.cambodiatribunal.org

គេហទំព័រឃ្លាំមើលការវិវឌ្ឍរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា www.cambodiatribunal.org គឺជាប្រភពឈានមុខគេនៃសារព័ត៌មានដំណឹងវិវឌ្ឍថ្មីៗ ព្រមទាំងបទអត្ថាធិប្បាយរបស់អ្នកជំនាញជាច្រើនទៅលើដំណើរការរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាទាំងមូល ។ រយៈពេលកន្លងមកនេះព័ត៌មានយ៉ាងច្រើនត្រូវបានផ្សព្វផ្សាយនៅលើគេហទំព័រនេះ ។ គេហទំព័រនេះបង្កលក្ខណៈងាយស្រួលបំផុតសម្រាប់សាធារណជនទាំងឡាយក្នុងការស្វែងយល់អំពីដំណើរការរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។

សំណុំរឿងព្រហ្មទណ្ឌលេខ០០២ដែលទាក់ទិននឹងជនជាប់ចោទពីរនាក់ទៀតគឺ ខៀវ សំផន គណៈប្រធានរដ្ឋនៃរបបកម្ពុជាប្រជាធិបតេយ្យ និង នួន ជា អនុលេខាបក្សនិងជាប្រធានរដ្ឋសភានៃរបបកម្ពុជាប្រជាធិបតេយ្យបានចាប់ផ្តើមបើកសវនាការកាលពីខែវិច្ឆិកា ឆ្នាំ២០១១ និងបញ្ចប់សវនាការដេញដោលកាលពីខែតុលា ឆ្នាំ២០១៣ ។

ដើម្បីជួយកាត់បន្ថយចំនួនអ្នកខកខានមិនបានតាមដានដំណើរការដោយផ្ទាល់ឲ្យមកនៅត្រឹមកម្រិតតូចមួយ គេហទំព័រឃ្លាំមើលការវិវឌ្ឍរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា www.cambodiatribunal.org ត្រូវបានបង្កើតដោយមានផ្នែកជាច្រើនទាក់ទិននឹងរបាយការណ៍ប្រចាំថ្ងៃអំពីសវនាការ វីដេអូសវនាការទាំងមូលនិងយោបល់ផ្សេងៗរបស់ជនរងគ្រោះទាក់ទងទៅនឹងសវនាការ សារព័ត៌មានផ្សេងៗជុំវិញតុលាការ របាយការណ៍របស់តុលាការនិងអង្គការក្រៅរដ្ឋាភិបាល ដំណើរការនីតិវិធីផ្សេងៗនៃអង្គជំនុំជម្រះ ប្រវត្តិសាស្ត្រ ប្រវត្តិរបស់តុលាការនេះ និងបទអត្ថាធិប្បាយរបស់អ្នកជំនាញ ។

គេហទំព័រនេះនឹងជួយបង្កលក្ខណៈងាយស្រួលគ្រប់គ្រាន់សម្រាប់និស្សិតគ្រប់គ្រឹះស្ថានសិក្សាដែលមានបំណងចង់សិក្សាស្វែងយល់អំពីដំណើរនីតិវិធីអង្គជំនុំជម្រះវិសាមញ្ញដែលជាដំណើរការមានលក្ខណៈចម្រុះជាតិ និងអន្តរជាតិ ។ ឧទាហរណ៍ ការយកទ្រឹស្តីច្បាប់មួយដែលមានលក្ខណៈស្មុគស្មាញនិងចម្រូងចម្រាសមកអនុវត្តដោយអង្គជំនុំជម្រះវិសាមញ្ញគឺទ្រឹស្តី "សហកម្មឧក្រិដ្ឋកម្មរួម" ដែលភាសាអង់គ្លេសហៅថា "*Join Criminal Enterprise*" ដែលតាមរយៈទ្រឹស្តីនេះ ជនសង្ស័យអាចត្រូវបានដាក់ឲ្យទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌចំពោះបទក្រិដ្ឋទាំងឡាយដែលប្រព្រឹត្តឡើងទៅតាម "ផែនការឧក្រិដ្ឋរួម" ដែលភាសាអង់គ្លេសហៅថា "*Common Criminal Plan*" ។ ដូច្នេះ យើងអាចចូលទៅរកដំណើរការនីតិវិធីផ្សេងៗនៃអង្គជំនុំជម្រះឬបទអត្ថាធិប្បាយរបស់អ្នកជំនាញដើម្បីស្វែងយល់ថាតើចៅក្រមបានសម្រេចយ៉ាងដូចម្តេចចំពោះការដែលយកទ្រឹស្តីនេះមកអនុវត្តនៅចំពោះមុខអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។ តើមានភាគីផ្សេងទៀតដែរឬទេដែលមានយោបល់ទៅលើបញ្ហានេះ?

ប្រសិនបើមិនចង់ចំណាយពេលវេលាច្រើនដើម្បីមើលវីដេអូសវនាការដែលប្រព្រឹត្តឡើងពេញមួយថ្ងៃដែលអាចចំណាយពេលពី៦ទៅ៨ម៉ោងនោះ សាធារណជនអាចចូលទៅក្នុងផ្នែករបាយការណ៍ប្រចាំថ្ងៃអំពីសវនាការ ។ ក្នុងផ្នែកនេះ យើងមានអ្នកឃ្លាំមើលសវនាការម្នាក់ដែលត្រូវបានបញ្ជូនឲ្យទៅអង្គុយនៅក្នុងបន្ទប់សវនាការផ្ទាល់ បន្ទាប់មកអ្នកឃ្លាំមើលនេះសរសេររបាយការណ៍ខ្លីមួយដែលរៀបរាប់អំពីខ្លឹមសារសំខាន់ៗទាំងឡាយទាក់ទិននឹងសវនាការពេញមួយថ្ងៃនោះតែម្តង ។ របាយការណ៍បែបនេះមានជាភាសាខ្មែរដែរ ។

**វ៉ាន់ថាន់ ពៅដារ៉ា**

# ការិយាល័យព័ត៌មានសាធារណៈ

«ការិយាល័យព័ត៌មានសាធារណៈ» របស់មជ្ឈមណ្ឌលឯកសារកម្ពុជា បានបើកបម្រើជូននិស្សិត អ្នកស្រាវជ្រាវ បុគ្គលិករាជការ និងអង្គការក្រៅរដ្ឋាភិបាល និងបុគ្គលទាំងឡាយដែលមានចំណាប់អារម្មណ៍ចង់យល់ដឹងអំពីប្រវត្តិសាស្ត្ររបបកម្ពុជាប្រជាធិបតេយ្យ និងព្រឹត្តិការណ៍វិវឌ្ឍរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ឬសាលាក្តីខ្មែរក្រហម ។

មជ្ឈមណ្ឌលឯកសារកម្ពុជាជាកន្លែងប្រមូលផ្តុំ និងចងក្រងឯកសារអំពីរបបកម្ពុជាប្រជាធិបតេយ្យបានច្រើនបំផុត ។ ឯកសារនៅមជ្ឈមណ្ឌលឯកសារកម្ពុជាមានប្រាំប្រភេទ ។ ប្រភេទឯកសារទីមួយគឺឯកសារជាក្រដាសសន្លឹកដែលមានចំនួនជិតមួយលានទំព័រ ។ ប្រភេទឯកសារទីពីរគឺជាបទសម្ភាសដែលបុគ្គលិកមជ្ឈមណ្ឌលឯកសារកម្ពុជាចុះទៅធ្វើសម្ភាសជាមួយជនរងគ្រោះនិងអតីតកម្មាភិបាលខ្មែរក្រហម ។ ប្រភេទឯកសារទីបីគឺជារូបថតទាក់ទងទៅនឹងសម័យខ្មែរក្រហម ។ ប្រភេទឯកសារទីបួនគឺជាឯកសារទាក់ទងទៅនឹងការធ្វើផែនទីរណ្តៅសាកសព និងទីតាំងសម្លាប់របស់ខ្មែរក្រហម និងឯកសារប្រភេទទីប្រាំគឺជាខ្សែភាពយន្តឯកសារដែលបានផលិតឡើងក្នុងរបបខ្មែរក្រហមនិងសម័យក្រោយមកទៀត ។

តាមរយៈការិយាល័យព័ត៌មានសាធារណៈ សាធារណជនអាចអាននឹងស្រាវជ្រាវឯកសារទាំងនេះបាន ។ ឯកសារខ្លះទៀតរួមមាន ៖ ប្រវត្តិរូបកម្មាភិបាលខ្មែរក្រហម ចម្លើយសារភាព កំណត់ហេតុរបស់បក្ស ទូរលេខឆ្លើយឆ្លង ព័ត៌មានដែលបានមកពីការសម្ភាសជាមួយអតីតកម្មាភិបាលខ្មែរក្រហម និងទិន្នន័យគន្តនិទ្ទេសបង្ហាញពីរណ្តៅសាកសព ទីតាំងគុក និងបូជនីយដ្ឋានប្រល័យពូជសាសន៍ ។

ការិយាល័យព័ត៌មានសាធារណៈមានទីតាំងនៅអគារលេខ៦៦ មហាវិថីព្រះសីហនុ ខាងកើតវិមានឯករាជ្យ ។ ការិយាល័យរបស់យើងបើកជូនសាធារណជនពីថ្ងៃច័ន្ទដល់ថ្ងៃសុក្រ ពេលព្រឹកពីម៉ោង៨ដល់ម៉ោង១២ និងពេលរសៀលពីម៉ោង២ដល់ម៉ោង៥ ។ ប្រសិនបើអស់លោកអ្នកមានចម្ងល់ ឬចង់រៀបចំព្រឹត្តិការណ៍ជាក្រុមណាមួយ សូមទាក់ទងបុគ្គលិករបស់យើង ជា ផល្លា តាមរយៈ ទូរស័ព្ទលេខ ០២៣ ២១១ ៨៧៥ ឬអ៊ីម៉ែល truthphalla.c@dccam.org ។















# នៅតែសោកស្តាយ

ស្ថិតនៅក្នុងវ័យ៧១ឆ្នាំ យាយ ទូច សាគន្ធ ដែលធ្លាប់ជាជនរងគ្រោះនៃរបបខ្មែរក្រហម បានរៀបរាប់ពីដំណើរជីវិតរបស់គាត់ក្នុងសម័យខ្មែរក្រហមថា នៅសម័យសាធារណរដ្ឋខ្មែរ (របបលន់ នល់) គាត់រស់នៅភូមិរការធំ ឃុំស្អុះ ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ ។ គាត់មានបងប្អូនចំនួនប្រាំមួយនាក់ ។ ក្រោយពីរៀបការអស់ បងប្អូនគាត់បានរស់នៅបែកគ្នា លើកលែងតែប្អូនស្រីពៅគាត់ម្នាក់ដែលមិនទាន់មានគ្រួសារ បាននៅរស់នៅជាមួយគាត់ ។

នៅឆ្នាំ១៩៦៨ គាត់បានរៀបការជាមួយស្វាមីឈ្មោះ ម៉ូវ ម៉ែត ដែលមានតួនាទីជាអនុរក្សពន្ធនាគារ ខេត្តកំពង់ស្ពឺ ។ ចំណែកគាត់ធ្វើការនៅសាលាសង្កាត់ស្អុះ ។ គាត់ធ្វើការបានរយៈពេលពីរឆ្នាំ ក៏បានផ្លាស់ទៅធ្វើការនៅសាលាខេត្តកំពង់ស្ពឺវិញ ។ នៅមុនសម័យខ្មែរក្រហម គាត់និងប្តី រួមទាំងកូនបីនាក់ (ស្រីពីរ ប្រុសមួយ) បានរស់នៅរួមគ្នាជាមួយឪពុកម្តាយ និងប្អូនស្រីពៅគាត់ ។

នៅចុងឆ្នាំ១៩៧៣ ដោយមានការវាយប្រហារខ្លាំងក្លាពីសំណាក់ខ្មែរក្រហមទៅលើទ័ពនៃរបបសាធារណរដ្ឋខ្មែរ នៅតាមខ្សែក្រវាត់ខេត្ត គាត់ និងក្រុមគ្រួសារបានបង្ខំចិត្តចាកចេញពីផ្ទះទៅរស់នៅជាមួយសាច់ញាតិនៅភូមិវល្លិ៍ស ឃុំវល្លិ៍ស ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ ដែលមានចម្ងាយប្រមាណ១០ គីឡូម៉ែត្រពីផ្ទះរបស់គាត់ ។ ប៉ុន្តែគាត់មិនបានស្នាក់នៅភូមិនោះជាប់លាប់ទេ គឺគាត់ត្រឡប់មកផ្ទះវិញនៅពេលព្រឹក ។

នៅដើមឆ្នាំ ១៩៧៤ គាត់បានទទួលដំណឹងថា នៅតាមមូលដ្ឋាននៃភូមិវល្លិ៍ស មានការចុះចាប់ប្រជាជនពីសំណាក់ខ្មែរក្រហម


ទូច សាគន្ធ និងប្តី (ម៉ូវ ម៉ែត) ថតឆ្នាំ១៩៦៨


ទូច សាគន្ធ និងប្តី (ម៉ូវ ម៉ែត) ថតជាមួយបងប្អូន នៅឆ្នាំ១៩៦៨

ហើយអ្វីដែលគាត់ដឹងច្បាស់នោះគឺ នៅជុំវិញខេត្ត ត្រូវបានយោធាខ្មែរក្រហមដណ្ដើមកាន់កាប់ស្ទើរទាំងស្រុងហើយ ។ កងយោធាខ្មែរក្រហមបង្កើនការវាយប្រហារខ្លាំងក្លាថែមទៀតក្នុងគោលបំណងវាយចូលដើម្បីកាន់កាប់ខេត្តកំពង់ស្ពឺ ។ ពេលទទួលបានដឹងដំណឹងនេះ គាត់និងក្រុមគ្រួសារក៏សម្រេចចិត្តភៀសខ្លួនមករស់នៅក្នុងផ្សារកំពង់ស្ពឺ ដែលមានទីតាំងនៅចំកណ្ដាលទីរួមខេត្តជាមួយអ្នកភូមិជាច្រើនទៀត ។ ប៉ុន្តែសភាពការណ៍មានការតឹងតែងយ៉ាងខ្លាំងរវាងយោធាខ្មែរក្រហម និងទ័ពសាធារណរដ្ឋខ្មែរ ហើយដោយឃើញការតតាំងរបស់កងទ័ពរបស់សាធារណរដ្ឋខ្មែរ មានសភាពកាន់តែខ្សោយ និងបារម្ភពីសុវត្ថិភាពផ្ទាល់ខ្លួន គាត់និងក្រុមគ្រួសារក៏បានសម្រេចចិត្តភៀសខ្លួនទៅកន្លែងផ្សេង ព្រោះក្នុងផ្សារកំពង់ស្ពឺនេះ លែងមានសុវត្ថិភាពហើយ ។

គាត់ និងក្រុមគ្រួសារក៏បានភៀសខ្លួនទៅកាន់បន្ទាយរបស់ទ្រង់ចន្ទរង្សី ដែលមានទីតាំងនៅមិនឆ្ងាយប៉ុន្មានពីផ្សារកំពង់ស្ពឺ ។ បន្ទាយនេះ ជាមូលដ្ឋានទ័ពធំបំផុតរបស់សារធារណរដ្ឋខ្មែរសម្រាប់ការពារទីតាំងភូមិសាស្ត្រខេត្តកំពង់ស្ពឺទាំងមូល ។ ប៉ុន្តែ ទោះបីបានរស់នៅក្នុងបន្ទាយទ្រង់ចន្ទរង្សីហើយក៏ដោយ ក៏គាត់និងក្រុមគ្រួសារនៅមានការភ័យខ្លាច ព្រោះខ្មែរក្រហមបានធ្វើការផ្លោងចូលបន្ទាយស្ទើរតែរៀងរាល់ថ្ងៃ ។ ពេលខ្មែរក្រហមបាញ់ផ្លោងចូលមកម្ដងៗ គាត់ និងគ្រួសារតែងរត់ចូលទៅក្នុងលេណដ្ឋាន ដែលកងទ័ពជីកទុកសម្រាប់ប្រជាជនលាក់ខ្លួន ។ ដោយមើលឃើញថាស្ថានការណ៍គ្រប់គ្រងលែងបានរដ្ឋាភិបាលសារធារណរដ្ឋខ្មែរក៏បានបញ្ជូនឧទ្ធម្ភាគចក្រមកជម្លៀសប្រជាជនចេញពីទីរួមខេត្ត ។ មាន គ្រួសារជាច្រើនត្រូវបានជម្លៀសចេញទៅភ្នំពេញ ។

នៅក្នុងឆ្នាំ១៩៧៥ ខ្មែរក្រហមធ្វើការវាយចូលបន្ទាយនិងបានកម្ទេចកងទ័ពសាធារណរដ្ឋខ្មែរនៅក្នុងទីរួមខេត្ត ។ ទីបំផុតយោធារបស់ខ្មែរក្រហមបានកាន់កាប់ទាំងស្រុងក្នុងខេត្តកំពង់ស្ពឺ ។ ខ្មែរក្រហមបានប្រមូលគាត់ និងគ្រួសារ និងប្រជាជនផ្សេងទៀតឲ្យនៅមួយកន្លែង ដើម្បីរៀបចំធ្វើការជម្លៀស ។

ខ្មែរក្រហមជម្លៀសប្រជាជនចេញពីទីរួមខេត្តឲ្យទៅនៅជនបទ ។ គាត់ និងក្រុមគ្រួសារត្រូវខ្មែរក្រហមជម្លៀសចេញទៅក្រៅខេត្តដោយថ្មើរជើង ដោយពេលនោះគាត់មានការងឿងឆ្ងល់យ៉ាងខ្លាំង ព្រោះមិនដឹងថាខ្មែរក្រហមឲ្យគាត់ទៅណា? គឺគ្រាន់តែមុនពេលជម្លៀសបន្តិច ខ្មែរក្រហមប្រាប់ថា ស្នើឲ្យចេញពីខេត្តមួយរយៈសិន ។ ព្រដូច្នេះ គាត់បានរៀបចំអង្ករ និងស្បៀងមួយចំនួនទៀតទុកសម្រាប់ហូប ។ នៅតាមផ្លូវ គាត់បានឃើញសាកសពប្រជាជន និងទាហានជាច្រើនដែលធ្វើឲ្យគាត់មានការភ័យខ្លាចជាខ្លាំង ។

ការធ្វើដំណើររបស់គាត់មិនមានគោលដៅច្បាស់លាស់ទេ និងមានការលំបាកយ៉ាងខ្លាំង ព្រោះមិនមានកន្លែងសម្រាកត្រឹមត្រូវ ។ ម្យ៉ាងទៀត កូនរបស់គាត់នៅតូចៗទៀត ។ គាត់បានធ្វើដំណើររយៈពេលកន្លះខែ ទើបទៅដល់វត្តព្រៃជុំ ស្ថិតនៅក្នុងស្រុកឧត្ដុង្គ ខេត្តកំពង់ស្ពឺ ។ ទីតាំងនោះគឺជាកន្លែងដែលបានកំណត់ដោយខ្មែរក្រហម សម្រាប់ធ្វើការប្រមូលផ្ដុំ និងបែងចែកប្រជាជនឲ្យទៅនៅតាមសហករណ៍ផ្សេងៗ ។ ខ្មែរក្រហមបានចាប់ធ្វើប្រវត្តិរូបប្រជាជនដែលបានជម្លៀសទៅទីនោះ ។ ពេលទៅដល់នោះភ្លាមគាត់ក៏បានជួបបងប្អូនជីដូនមួយគាត់ឈ្មោះ ផាន ដែលជាអ្នករស់នៅក្បែរតំបន់នោះ ។ ប្អូនគាត់ឈ្មោះ ផាន នោះ មានបងថ្លៃធ្វើជាប្រធានសហករណ៍ ។ ពេលរៀបចំបែងចែកប្រជាជន មានអ្នកផ្សេងបានលួចខ្សឹបប្រាប់ទៅកម្មាភិបាលខ្មែរក្រហមថា ប្ដីរបស់គាត់ធ្វើជាប៉ូលីស ។ ពេលដឹងរឿងនេះ គាត់មានការភិតភ័យយ៉ាងខ្លាំង ព្រោះគាត់បានដឹងថា ខ្មែរក្រហមនឹងយកគ្រួសារគាត់ទៅសម្លាប់មិនខាន ។ ព្រឹកឡើងឡើង ខ្មែរក្រហមក៏ចាប់ផ្ដើមបញ្ជាឲ្យបែងចែកប្រជាជនទៅតាមប្រវត្តិរូប ដែលមានមន្ត្រី អ្នកដែលជាប់និន្នាការពីរបប លន់ នល់ និងប្រជាជនធម្មតា ។

បងប្អូនជីដូនមួយរបស់គាត់បានទៅសុំអង្វរ អង្គការកុំឲ្យនាំយកគ្រួសារគាត់ទៅ ហើយបើយក សូមយកតែប្ដីទៅបានហើយ ព្រោះកូន ប្រពន្ធ និងឪពុកម្ដាយមិនដឹងទេ ។ ពេលនោះ ខ្មែរក្រហមបានយល់ព្រមទុកគាត់ កូនៗ និងឪពុកម្ដាយដោយយកតែប្ដីគាត់ ។ ខ្មែរក្រហមយកប្ដីគាត់ទៅ ដោយគាត់មិនដឹងថាយកទៅទីណាដែរ ។ ចាប់តាំងពីពេលនោះមក គាត់បាត់ដំណឹងប្ដីរបស់គាត់រហូត ។

នៅឆ្នាំ១៩៧៥ដដែល ខ្មែរក្រហមចាប់ផ្ដើមធ្វើការបែងចែកប្រជាជនតាមមូលដ្ឋាន ។ ពេលនោះ ខ្មែរក្រហមបានរៀបចំសហករណ៍ថ្មីមួយទៀត ស្ថិតនៅក្នុងភូមិត្នោត ស្រុកឧត្ដុង្គ ទើបប្អូនជីដូនមួយគាត់បានសុំឲ្យអង្គការយករទេះគោមកដឹកគ្រួសារគាត់

ទៅសហករណ៍ថ្មីនោះ ។

មកដល់សហករណ៍ថ្មីនេះ អង្គការឲ្យគាត់សង់ជាខ្ទមតូចៗ នៅតាមវាលស្រែ ដែលនៅដាច់ឆ្ងាយពីផ្ទះប្រជាជនមូលដ្ឋាន ។ អង្គការចាប់ផ្តើមបែងចែកការងារឲ្យប្រជាជនថ្មីធ្វើរៀងៗខ្លួន ។ ខ្មែរក្រហមក៏ចាប់ផ្តើមចាប់បំបែកកូនៗរបស់ សុគន្ធ ឲ្យទៅនៅកន្លែងផ្សេងពីគ្នា ។ កូនស្រីច្បងរបស់គាត់ អង្គការបានបញ្ជូនទៅនៅក្នុងកងកុមារ ។ ចំណែកកូនទីពី និងកូនពៅរបស់គាត់ ដោយនៅក្មេងពេក អង្គការក៏ទុកឲ្យរស់នៅជាមួយម្តាយរបស់គាត់ជាអ្នកមើលថែរក្សា ។ ឪពុកគាត់ដែលនៅមានកម្លាំងអាចធ្វើការ ក៏ត្រូវចេញទៅធ្វើការដែរដោយឲ្យគាត់ដើរកាប់ដីដំបូកណាដែលខ្ពស់ៗដុះនៅតាមភ្លឺស្រែឲ្យរាប ។ ចំណែក សុគន្ធ ខ្មែរក្រហមឲ្យគាត់ទៅស្ទូង ។ ការរស់នៅក្នុងសហករណ៍មានការលំបាកណាស់ ព្រោះគាត់ត្រូវប្រឈមមុខនឹងការងារជាច្រើន ដែលគាត់មិនធ្លាប់ធ្វើពីមុនទាល់តែសោះ ។ ដោយសារតែគាត់ធ្លាប់ធ្វើជាមន្ត្រីរាជការ ធ្វើឲ្យគាត់មានការលំបាកក្នុងការដកស្ទូង ហើយអ្វីដែលធ្វើឲ្យគាត់មានការពិបាកទ្រាំទៅទៀត គឺរបបអាហារប្រចាំថ្ងៃដែលមានតែបបរ ។ មួយថ្ងៃគាត់ទទួលបានអាហារតែពីរពេលប៉ុណ្ណោះ គឺនៅពេលថ្ងៃ និងពេលល្ងាច ។ ប៉ុន្តែទោះបីយ៉ាងណា គាត់ត្រូវតែធ្វើការងារដាច់ខាត ព្រោះជាបញ្ជារបស់អង្គការថ្នាក់លើ ហើយបើមិនសម្រេចតាមផែនការទេគាត់នឹងត្រូវប្រឈមការលំបាកជាងនេះជាមិនខាន ។

ក្រោយមកទៀត អង្គការបានបញ្ជូន សុគន្ធ ឲ្យទៅធ្វើការនៅក្នុងរោងបាយវិញ ។ នៅចុងឆ្នាំ១៩៧៥ ដោយការធ្វើការហួសកម្លាំង និងការផ្តល់អាហារមិនគ្រប់គ្រាន់ បានធ្វើឲ្យឪពុករបស់គាត់ធ្លាក់ខ្លួនឈឺជាទម្ងន់ ។

នៅដើមឆ្នាំ១៩៧៦ ខ្មែរក្រហមចាប់ផ្តើមជម្លៀសប្រជាជនថ្មីម្តងទៀត ។ បើតាមគាត់ដឹងប្រជាជនថ្មីទាំងអស់ ត្រូវអង្គការជម្លៀសទៅតំបន់តាមដងទន្លេ ។ ដោយឡែក សម្រាប់គ្រួសារ សុគន្ធ ដែលមានឪពុកឈឺនៅក្នុងបន្ទុក អង្គការទុកឲ្យរស់នៅក្នុងសហករណ៍ចាស់ដដែល ។ ការចេញដំណើររបស់ប្រជាជនថ្មីធ្វើឲ្យសហករមានសភាពស្ងប់ស្ងាត់ ។ ព្រោះនៅសល់តែប្រជាជនមូលដ្ឋានរស់នៅតែប៉ុណ្ណោះ ។ នៅពេលនោះ ជំងឺឪពុករបស់គាត់កាន់តែមានសភាពធ្ងន់ធ្ងរទៅៗ ហើយនៅពាក់កណ្តាលឆ្នាំ១៩៧៦ ឪពុករបស់គាត់ក៏ស្លាប់ទៅ ។

ក្រោយមកពីឪពុកគាត់ស្លាប់ សុគន្ធ រស់នៅដោយភាពភ័យខ្លាច ។ ថ្ងៃខ្លះ ពេលគាត់កំពុងធ្វើការ គាត់បានឃើញកងឈ្លបបណ្តើរមនុស្សកាត់មុខគាត់ទាំងហ្វូងៗ តែដោយមានការភ័យខ្លាចទើបគាត់មិនហ៊ានមើលចំ ។

នៅខែមករា ឆ្នាំ១៩៧៩ គាត់បានឮដំណឹងមកថា មានកងទ័ពវៀតណាមចូលមករំដោះ ។ គាត់មានអារម្មណ៍សប្បាយរីករាយណាស់ ប៉ុន្តែសន្ធឹកគ្រាប់ដែលកងទ័ពវៀតណាមបាញ់មកលើកងទ័ពខ្មែរក្រហមធ្វើឲ្យគាត់មានការភិតភ័យជាខ្លាំង ។ គាត់ចង់រត់ចេញពីកន្លែងនោះ តែខ្មែរក្រហមបានបញ្ជាមិនឲ្យនរណាម្នាក់រត់ចេញពីសហករណ៍ ។ បើសិនជាមិនស្តាប់ ខ្មែរក្រហមនឹងយកទៅសម្លាប់ជាក់ជាមិនខាន ។ ដោយសារសំឡេងគ្រាប់ផ្លោងកាន់តែខ្លាំងទើបធ្វើឲ្យកូនស្រីច្បងរបស់គាត់ដែលធ្វើការនៅកងកុមារបានរត់មករកគាត់ទាំងការភ័យខ្លាច ។

សុគន្ធ បានទៅជួបជុំគ្រួសារដែលនៅក្នុងសហករណ៍ ហើយត្រៀមភៀសខ្លួនចេញពីកន្លែងនោះ ព្រោះខ្មែរក្រហមបានបញ្ជាឲ្យប្រជាជនគេចពីកងទ័ពវៀតណាម ។ ខ្មែរក្រហមបានប្រាប់គាត់ថាវៀតណាមនឹងចូលមកសម្លាប់ប្រជាជនទាំងអស់ ។ ព្រោះដូច្នេះ សុគន្ធ និងក្រុមគ្រួសារក៏ធ្វើការជម្លៀសទៅតាមខ្មែរក្រហម ។ គាត់បានធ្វើដំណើរដោយថ្មើរជើង ដោយមានកងទ័ពរបស់វៀតណាមតាមពីក្រោយ ។ គាត់មានការហត់ហេវ និងអស់កម្លាំង ប៉ុន្តែដោយការភ័យខ្លាចក៏បានជំរុញឲ្យគាត់ខំប្រឹងបន្តដំណើរទៅមុខទៀត ។ ពេលទៅដល់ភូមិនាងហ៊ីង ដែលស្ថិតនៅក្នុងស្រុកថ្ពង ខេត្តកំពង់ស្ពឺ ខ្មែរក្រហមបានអនុញ្ញាតឲ្យប្រជាជនទាំងអស់សម្រាក ។ គាត់បានដើរទៅគោះពងអន្ទ្រង ដើម្បីយកមកឲ្យកូន និងម្តាយគាត់ហូបស្រាប់តែពេលនោះ កងទ័ពវៀតណាមចូលមកដល់ ហើយកៀរគ្រួសារគាត់ត្រឡប់មកវិញ ។ ប្រជាជនជាច្រើនបានត្រឡប់មកតាមទ័ពវៀតណាម ។ ចំណែកប្រជាជនមួយទៀត បានភៀសខ្លួនជាមួយខ្មែរក្រហមឡើងទៅលើភ្នំបន្តទៀត ។ គាត់ពិតជាមានភាពសប្បាយរីករាយណាស់ពេលបានត្រឡប់មកភូមិវិញ ។ ប៉ុន្តែគាត់នៅតែសោកស្តាយ ដោយសារតែការបាត់បង់ប្តី ឪពុក និងការព្រាត់ប្រាស់បងប្អូនជាទីស្រឡាញ់ ។ **យឹម ឋិត្យពិសី**

# ស្ត្រីដែលជានិមិត្តរូបរបស់ខ្ញុំ

កាលពីក្មេងពេលដែលខ្ញុំពុំព្រមញ៉ាំបាយ ម្តាយខ្ញុំតែងតែប្រៀនប្រដៅខ្ញុំថា "កូនប្រុស! កូនឯងត្រូវតែញ៉ាំបាយឲ្យអស់ ពីចានសូម្បីតែមួយគ្រាប់ក៏កុំឲ្យនៅសល់ដែរ ។ កូនដឹងទេ! នៅពេល ម៉ាក់រស់នៅក្នុងសម័យខ្មែរក្រហមម៉ាក់មិនមានបាយញ៉ាំគ្រប់គ្រាន់ ដូចកូនឯងសព្វថ្ងៃនេះទេ ។ ខ្មែរក្រហមឲ្យតែបបររាវៗមួយកូនចាន តែប៉ុណ្ណោះហើយក្នុងមួយថ្ងៃម៉ាក់ទទួលបានតែពីរពេលទេ" ។ ប៉ុន្តែនៅពេលនោះ ខ្ញុំពុំទាន់ទាំងដឹងថាអ្វីទៅជាខ្មែរក្រហមផងហើយ ខ្ញុំគិតថាម្តាយខ្ញុំគាត់គ្រាន់តែលួងលោមដើម្បីធ្វើយ៉ាងណាឲ្យខ្ញុំព្រម ញ៉ាំបាយឲ្យអស់តែប៉ុណ្ណោះ ។

នៅក្នុងឆ្នាំ១៩៩៨ នៅពេលខ្ញុំមានអាយុ៦ឆ្នាំ ខ្ញុំបានចាប់ផ្តើមចូលរៀននៅសាលាបឋមសិក្សាមួយស្ថិតនៅក្បែរវិមានឯករាជ្យហើយខ្ញុំរៀននៅទីនោះរហូតដល់បញ្ចប់ថ្នាក់វិទ្យាល័យ ។ នៅអំឡុងពេលដែលខ្ញុំកំពុងរៀនក្នុងថ្នាក់បឋមសិក្សាខ្ញុំបានឮពាក្យ "ខ្មែរក្រហម" និង "បនប្រល័យពូជសាសន៍" ម្តងទៀតពីគ្រូរបស់ខ្ញុំ ។ នៅពេលនោះ គ្រូរបស់ខ្ញុំបានប្រាប់ខ្ញុំថា របបខ្មែរក្រហមដែលដឹកនាំដោយ ប៉ុល ពត បានសម្លាប់មនុស្សអស់ជិតបីលាននាក់ក្នុងរយៈពេលតែបីឆ្នាំ ប្រាំបីខែ ម្ភៃថ្ងៃប៉ុណ្ណោះ ។ ទោះបីជាខ្ញុំបានរៀនសូត្រ និងបានដឹងអំពីរបបខ្មែរក្រហមខ្លះៗនៅសាលារៀនហើយ ក៏ដោយក៏ខ្ញុំពុំដែលចាប់អារម្មណ៍សាកសួរម្តាយខ្ញុំលម្អិតអំពីបទពិសោធន៍របស់គាត់អំឡុងពេលរបបនោះដែរ ។ សូម្បីមានរឿងអ្វីកើតឡើងចំពោះម្តាយខ្ញុំក៏ខ្ញុំពុំដែលដឹង ។ មានពេលខ្លះ ម្តាយខ្ញុំព្យាយាមរៀបរាប់ពីបទពិសោធជូរចត់ និងភាពឈឺចាប់របស់គាត់ក្នុងរបបនោះឲ្យខ្ញុំស្តាប់ ។ គាត់បង្ហូរទឹកភ្នែកនៅពេលរំឭកអំពីអតីតកាលខ្លោចផ្សានៅពេលដែលខ្មែរក្រហមបង្ខំគាត់ឲ្យធ្វើការតាំងពី



រូបថតម្តាយរបស់ លឹម ជ័យឫទ្ធ ថតក្នុងឆ្នាំ១៩៨១ លើសួនច្បារខាងកើតវិមានឯករាជ្យ

ព្រឹកព្រលឹមរហូតដល់ព្រលប់នៅតាមការដ្ឋាន និងសហករណ៍ក្នុងស្ថានភាពមិនមែនជាមនុស្ស និងគ្មានមនុស្សធម៌ជាទីបំផុត ។ ប៉ុន្តែដោយសារតែខ្ញុំជាក្មេងចូលចិត្តលេងជាជាងចូលចិត្តស្តាប់ខ្ញុំសម្តែងអាការធ្វើជាប្រឹងស្តាប់គាត់រៀបរាប់ពីរឿងរ៉ាវរបស់គាត់ដោយយកចិត្តទុកដាក់ ប៉ុន្តែតាមពិតទៅខ្ញុំពុំចាប់អារម្មណ៍សូម្បីតែមានចម្ងល់ឬសួរត្រឡប់ទៅគាត់វិញក៏ពុំមានដែរ ។ នៅពេលដែលខ្ញុំសម្លឹងមើលទៅភ្នែករបស់ម្តាយខ្ញុំ ខ្ញុំពុំដឹងថាក្នុងចិត្តរបស់គាត់កំពុងតែគិតអំពីអ្វីនោះទេតែសម្រាប់ខ្ញុំវាហាក់បីដូចជាសញ្ញាមួយដែលបង្ហាញថាគាត់ពិតជាចង់និយាយចេញនូវរឿងរ៉ាវទុក្ខសោក និងឈឺចាប់មួយដែលគាត់ធ្លាប់ជួបប្រទះឲ្យកូនៗបានដឹង ។ ទោះបីជាមានពេលខ្លះខ្ញុំមិនសូវជាយកចិត្តទុកដាក់ស្តាប់ការរៀបរាប់របស់ម្តាយខ្ញុំក៏ពិតមែន តែរាល់ពាក្យសម្តីគ្រប់ម៉ាត់របស់គាត់តែងស្ថិតក្នុងចិត្តរបស់ខ្ញុំជានិច្ច ។ បន្ទាប់មក ខ្ញុំតែងតែប្រាប់ខ្លួនឯងថា ខ្ញុំគួរតែធ្វើអ្វីមួយនាពេលអនាគត ។ តាំងពីនៅពេលកំពុងរៀននៅថ្នាក់អនុវិទ្យាល័យខ្ញុំបានផ្តើមកំណត់គោលដៅហើយប្រាប់ខ្លួនឯងថានាពេលអនាគតខ្ញុំចង់ក្លាយជាអ្នកនយោបាយមួយរូប ។ ខ្ញុំយល់ថានេះគឺជាមធ្យោបាយដ៏ប្រសើរមួយសម្រាប់ខ្ញុំដែលផ្តល់ឱកាសឲ្យខ្ញុំអាចជួយអភិវឌ្ឍប្រទេសជាតិរបស់ខ្ញុំដែលធ្លាប់បែកបាក់ និងខ្ទេចខ្ទាំដោយភ្លើងសង្គ្រាមជាច្រើនទសវត្សរ៍ និងរងការបំផ្លិចបំផ្លាញស្ទើរក្លាយជាផេះផង់ដោយសាររបបខ្មែរក្រហម ។

បន្ទាប់ពីបញ្ចប់ការសិក្សាថ្នាក់វិទ្យាល័យខ្ញុំបានសម្រេចចិត្តបន្តការសិក្សាដោយជ្រើសរើសយកមុខជំនាញទាំងផ្នែកច្បាប់និងផ្នែកសេដ្ឋកិច្ចនៅក្នុងសាកលវិទ្យាល័យមួយនៅក្នុងទីក្រុងភ្នំពេញ ។ ភ្លាមៗក្រោយពេលបានបញ្ចប់ការសិក្សាពីសាកលវិទ្យាល័យ ខ្ញុំបានចូលរួមក្នុងវគ្គបណ្តុះបណ្តាលផ្នែកច្បាប់មួយនៅមជ្ឈមណ្ឌលឯកសារកម្ពុជាស្តីពីច្បាប់ព្រហ្មទណ្ឌអន្តរជាតិ និងករណីសំណុំរឿងរបស់ កាំង ហ្គេកអ៊ាវ ហៅ ឌុច ។ ពីរសប្តាហ៍ក្រោយទទួលបានការបណ្តុះបណ្តាលខ្ញុំត្រូវបានជ្រើសរើសជាអ្នកធ្វើការស្ម័គ្រចិត្តនៅទីនោះដោយធ្វើជាអ្នកសង្កេតការណ៍ដំណើរការកាត់ទោសមេដឹកនាំខ្មែរក្រហមក្នុងគម្រោងឃ្លាំមើលយុត្តិធម៌ (Witnessing Justice) ។ នៅពេលចាប់ផ្តើមខ្ញុំត្រូវបានតម្រូវឲ្យសរសេរអំពីរឿងរ៉ាវនៃសាច់ញាតិដែលធ្លាប់ឆ្លងកាត់របបខ្មែរក្រហមដើម្បីចុះផ្សាយនៅក្នុងឯកសារទស្សនាវដ្តី «ស្វែងរកការពិត» ។ ខ្ញុំបានសម្រេចចិត្តជ្រើសរើសយកសាច់រឿងរបស់ម្តាយខ្ញុំផ្ទាល់ដោយសុំឲ្យគាត់រៀបរាប់លម្អិតពីបទពិសោធរបស់គាត់នៅក្នុងរបបដ៏ខ្មៅងងឹតនោះ ។ ម្តាយរបស់ខ្ញុំបានសរសេររៀបរាប់នៅលើក្រដាសប្រមាណ១០ទំព័រ និងបានប្រគល់អត្ថបទនោះមកខ្ញុំ ។ ក្រោយពីបានអានអត្ថបទនោះហើយខ្ញុំមានអារម្មណ៍ក្តុកក្តួលពេកក្រៃ ទឹកភ្នែករបស់ខ្ញុំស្រាប់តែហូរធ្លាក់ចុះមកទាំងមិនដឹងខ្លួន ។ បទពិសោធឈឺចាប់ និងក្តីលំបាកវេទនាដោយសារអំពើអមនុស្សធម៌នៃរបបខ្មែរក្រហមដែលម្តាយខ្ញុំបានជួបប្រទះនឹងត្រូវស្ថិតក្នុងភាពស្ងៀមស្ងាត់ហើយគ្មាននរណាម្នាក់បានដឹងឡើយប្រសិនបើគាត់ពុំបានសរសេររៀបរាប់ចេញនោះ ។ តាមការពិតខ្ញុំគួរតែបានដឹងអំពីទុក្ខសោករបស់គាត់តាំងពីយូរណាស់មកហើយព្រោះគាត់តែងតែប្រាប់ខ្ញុំជារឿយៗតែផ្ទុយទៅវិញខ្ញុំពុំដែលយកចិត្តទុកដាក់ស្តាប់អំពីអ្វីដែលគាត់រៀបរាប់ ។ ម្តាយខ្ញុំពុំមែនជាអ្នកដែលទទួលបានការអប់រំខ្ពស់ដោយសារតែគាត់ពុំមានឱកាសបញ្ចប់ការសិក្សា ។ គាត់ធំដឹងក្តីនៅខណៈពេលដែលប្រទេសជាតិកំពុងស្ថិតក្នុងភ្លើងសង្គ្រាម ។ គាត់ត្រូវបានបង្ខំឲ្យធ្វើការងារយ៉ាងលំបាកទាំងគាត់ទើបតែមានអាយុត្រឹមតែ១៥ឆ្នាំ ។ ក្រោយពេលដែលសង្គ្រាមផុតរលត់ទៅម្តាយរបស់ខ្ញុំបានចំណាយពេលទាំងអស់របស់គាត់ដើម្បីជួយផ្គត់ផ្គង់ការរស់នៅក្នុងគ្រួសារដោយចាប់ផ្តើមពីបាតដៃទទេ ។ គាត់គ្រាន់តែជាស្ត្រីសាមញ្ញមួយរូប ប៉ុន្តែគាត់អាចដោះស្រាយនូវបញ្ហាគ្រប់ជំពូក ។ ទោះបីជាយ៉ាងណាក្តីបទពិសោធជូរចត់របស់ម្តាយខ្ញុំគ្រាន់តែជារឿងរ៉ាវរបស់ជនរងគ្រោះមួយរូបក្នុងចំណោមស្ត្រីជាច្រើនលាននាក់ទៀតដែលធ្លាប់បានឆ្លងកាត់របបនោះតែប៉ុណ្ណោះ ។ ភាពឈឺចាប់របស់ម្តាយខ្ញុំបានជំរុញលើកទឹកចិត្តឲ្យខ្ញុំកាន់តែចង់ស្វែងយល់បន្ថែមទៀតពីប្រវត្តិសាស្ត្រសម័យខ្មែរក្រហម និងចង់ធ្វើការងារដើម្បីជួយជនរងគ្រោះនៃរបបនោះដែលបានទន្ទឹងរង់ចាំយុត្តិធម៌អស់រយៈពេលច្រើនជាងបីទសវត្សរ៍កន្លងមក និងដើម្បីចូលរួមចំណែកចែករំលែកចំណេះដឹងដល់យុវជនជំនាន់ក្រោយដើម្បីទប់ស្កាត់កុំឲ្យអំពើទាំងនោះកើតឡើងសាជាថ្មីម្តងទៀត ។ អ្វីៗទាំងអស់ដែលខ្ញុំមានរហូតមកដល់សព្វថ្ងៃគឺដោយសារតែការតស៊ូ និងភាពអង់អាចនៃអ្នកម្តាយដែលជានិមិត្តរូបរបស់ខ្ញុំ ។

**លឹម ជ័យផត្ត**

# ញឹម ចាន់ ៖ ជីវិតស្ថិតនៅក្រោមការសម្រេចរបស់អង្គការ

ញឹម ចាន់ ភេទស្រី អាយុ៥៨ឆ្នាំ កើតនៅភូមិដូនអាម ឃុំព្រះពន្លា ស្រុកកំពង់រោទ៍ ខេត្តស្វាយរៀង ។

ពីមុនសម័យខ្មែរក្រហម គ្រួសាររបស់ ចាន់ បានមករស់នៅភ្នំពេញតាមឪពុកដែលធ្វើជាទាហាន លន់ នល់ ។ ក្រោយមក នៅពេលដែលខ្មែរក្រហមវាយដាច់ភ្នំពេញ គ្រួសាររបស់ ចាន់ ត្រូវខ្មែរក្រហមជម្លៀសឲ្យទៅនៅស្រុកកំណើតនៅខេត្តស្វាយរៀងវិញ ។ ចាន់ បានត្រឡប់មករស់នៅជាមួយបងស្រីមុន ។ ចំណែកឪពុកម្ដាយរបស់គាត់បានត្រឡប់មកផ្ទះតាមក្រោយ ។ ចាន់ មិនបានជួប និងទទួលដំណឹងឪពុករបស់គាត់ទេ ព្រោះនៅពេលមកដល់ស្រុកភ្លាម ខ្មែរក្រហមចាត់តាំងគាត់ឲ្យទៅរស់នៅកន្លែងផ្សេង ។ ចាន់ គិតថាឪពុកគាត់នឹងត្រូវខ្មែរក្រហមយកទៅសម្លាប់មិនខាន ព្រោះឪពុកគាត់មានជាប់និន្នាការជាទាហាន លន់ នល់ ។ ចំណែកម្ដាយរបស់គាត់បានរត់ទៅជាមួយកងទ័ពវៀតណាម បន្ទាប់ពីខ្មែរក្រហមជម្លៀសគាត់មកដល់ភូមិវិញ ។

រយៈពេលប្រហែលជាពីរទៅបីខែក្រោយមក ខ្មែរក្រហមមកសើរើប្រវត្តិរូប ហើយតាមចាប់ខ្លួន ចាន់ ដោយចោទថា ជាប់ខ្សែក្បត់ជាមួយទាហាន លន់ នល់ និងទាហានវៀតណាម ។ តែសំណាងល្អ បងស្រីរបស់ ចាន់ បានប្រាប់ទៅយោធាខ្មែរក្រហមថា ចាន់ បានមករស់នៅជាមួយគាត់តាំងពីនៅតូចមកម្ល៉េះ ហើយក៏ពុំដែលបានរស់នៅ ឬក៏ទាក់ទងជាមួយម្ដាយឪពុកដែរ ។ ដោយសារហេតុផលនេះហើយ ទើបយោធាខ្មែរក្រហមយល់ព្រមដោះលែង ចាន់មកវិញ ។

ក្រោយមក អង្គការចាត់តាំង ចាន់ ឲ្យឃ្វាលគោ និងក្របីមួយរយៈទើបផ្លាស់ប្ដូរគាត់ឲ្យមកធ្វើនៅកងចល័ត ។ នៅទីនោះ ចាន់ ធ្វើការងារជីកប្រឡាយ, ស្ទូងស្រូវ, គាស់គល់រាំង និងការងារផ្សេងទៀតដែលអង្គការតម្រូវឲ្យធ្វើ ។ អង្គការបានតម្រូវឲ្យ ចាន់ ធ្វើការតាំងពីព្រឹកព្រលឹមរហូតដល់ល្ងាច ទោះបីអង្គការដឹងថាការងារនោះលំបាក និងមិនមានរបបអាហារបរិភោគគ្រប់គ្រាន់ក៏ដោយ ព្រោះនៅពេលព្រឹក ចាន់ ហូបតែបបររាវៗ ចំណែកពេលថ្ងៃ និងល្ងាច គាត់ហូបបាយលាយចេក និងពោតប៉ុណ្ណោះ ។ ដូច្នេះនៅពេលឃ្លានខ្លាំង ចាន់ បានទៅដកគល់ស្លឹកគ្រៃមកជញ្ជក់យករសជាតិដើម្បីបំពេញក្រពះ ។

ចាន់ បានប្រាប់ថា គាត់ហូបអាហារគ្រប់យ៉ាងឲ្យតែគាត់ជួបប្រទះ ព្រោះចង់បន្តជីវិតទៅថ្ងៃមុខទៀត ។ ថ្ងៃមួយ ចាន់ និងអ្នកធ្វើការនៅក្នុងក្រុមជាមួយ បានសម្រេចចិត្តចេញទៅលួចមាន់, លួចពោត និងដំណាំផ្សេងៗយកមកហូប ។ ចាន់ ទៅលួចបានដំឡូងយកមកដុត និងយកមកហូបនៅក្នុងមុងស្ងាត់ៗ ព្រោះខ្លាចឈ្លបខ្មែរក្រហមដឹង រួចហើយយកទៅសម្លាប់ចោល ។

នៅពេលនោះ ចាន់ ពុំយល់ទេចំពោះការដែលប្រើពាក្យថា "លួច" នោះ ព្រោះអ្វីដែលគាត់យកមកបរិភោគនោះ គឺគាត់បានចិញ្ចឹម និងដាំដោយផ្ទាល់ដៃ ។ ចំណែកស្រូវ ដែល ចាន់ និងប្រជាជនដាំដុះរយៈពេលបីដងក្នុងមួយឆ្នាំ ក៏ ចាន់ មិនដឹងថាអង្គការយកទៅណាដែរ ។ ប៉ុន្តែ ចាន់ នៅតែខិតខំប្រឹងប្រែងធ្វើការតាមអង្គការចាត់តាំង ។ ចាន់ ពុំដែលហ៊ានតវ៉ា ឬបញ្ចេញមតិយោបល់ទាក់ទងនឹងអង្គការទេ ព្រោះគាត់ធ្វើការមួយថ្ងៃសម្រាប់តែហូបមួយថ្ងៃ និងរស់មួយថ្ងៃប៉ុណ្ណោះ ។ ចាន់ ពុំដែលបានគិតថា គាត់រស់មកដល់សព្វថ្ងៃទេ គឺជីវិតរបស់ ចាន់ ស្ថិតក្រោមការសម្រេចរបស់ខ្មែរក្រហម ។

ចាន់ រស់នៅ និងធ្វើការងារនៅក្នុងភូមិរហូតដល់វៀតណាមចូលមករំដោះទើបគាត់រៀបការ ហើយទៅរស់នៅជាមួយប្ដីនៅឃុំឃុនរាម ស្រុកបន្ទាយស្រី ខេត្តសៀមរាប ។

**ឆាយ ដាទីន**

# ដំណើរជីវិតរបស់ ព្រុំ គៀម ក្នុងរបបខ្មែរក្រហម

អ៊ំ ព្រុំ គៀម មានអាយុ៦៤ឆ្នាំ មានស្រុកកំណើតនៅភូមិតាភោគ ឃុំបល្ល័ង្គ ស្រុកបារាយណ៍ ខេត្តកំពង់ធំ ។ ស្ថិតក្នុងសម្លៀកបំពាក់ទើបមកពីធ្វើចម្ការ ហើយអង្គុយនៅលើកៅអីវែងមួយនៅមុខផ្ទះ គៀម បាននិយាយរៀបរាប់ទាក់ទងទៅនឹងដំណើររឿងរ៉ាវជីវិតផ្ទាល់ខ្លួន ដែលបានឆ្លងកាត់ក្នុងរបបខ្មែរក្រហមថា៖

សព្វថ្ងៃ គាត់ប្រកបមុខរបរលក់ដូរបន្តិចបន្តួច និងធ្វើស្រែចម្ការដើម្បីចិញ្ចឹមជីវិត ។ គាត់មានកូនប្រាំនាក់ ស្រីពីរ ប្រុសបី ។ ប៉ុន្តែជាអកុសល នៅក្នុងរបប លន់ នល់ កូនស្រីច្បង និងកូនស្រីទីបីរបស់គាត់បានស្លាប់ដោយសារជំងឺ ដោយបន្សល់ទុកចៅស្រីម្នាក់ឲ្យគាត់ចិញ្ចឹមរហូតដល់សព្វថ្ងៃ ។ សព្វថ្ងៃ កូនៗរបស់គាត់មានគ្រួសារ និងបែកទៅរស់នៅផ្ទះផ្សេងអស់ហើយ ។ គៀម បានត្អូញត្អែរថា ជីវិតរស់នៅប្រចាំថ្ងៃរបស់គាត់ពិតជាជួបការលំបាកណាស់ ព្រោះគាត់ត្រូវទទួលរ៉ាប់រងប្រកបរបរប្រចាំថ្ងៃ ដើម្បីចិញ្ចឹមប្តី ដែលមានវ័យចំណាស់ និងត្រូវចិញ្ចឹមថែទាំចៅស្រីម្នាក់ដែលកំព្រាម្តាយតាំងពីតូច ។

គៀម បានរំឭកថា ដោយសារមានការទម្លាក់គ្រាប់របស់អាមេរិកនៅក្នុងរបប លន់ នល់ គាត់ និងស្វាមី ព្រមទាំងកូនៗទាំងពីរនាក់ទៀតបានរត់ភៀសខ្លួនពីគ្រាប់បែក ដោយចេញពីភូមិតាភោគក្នុង ទៅភូមិតាភោគក្រៅ ក្នុងស្រុកបល្ល័ង្គ ខេត្តកំពង់ធំ ។ គៀម បានបន្ថែមថា នៅតាមផ្លូវធ្វើដំណើរ មានសភាពលំបាកខ្លាំងព្រោះតែមានភ្លៀងផ្គរ និងរន្ទះ ។ បន្ទាប់ពីធ្វើដំណើរដោយថ្មើរជើងពេញមួយថ្ងៃ គៀម និងក្រុមគ្រួសារបានទៅដល់ភូមិតាភោគក្រៅ



កងចល័តលើកទំនប់

និងបានសុំអ្នកស្រុក អ្នកភូមិស្នាក់អាស្រ័យនៅខាងក្រោមផ្ទះមួយរយៈ រហូតដល់គាត់ធ្វើខ្ទមសម្រាប់ក្រុមគ្រួសាររបស់គាត់បាន ។

បន្ទាប់ពីការទម្លាក់គ្រាប់បែកមានសភាពស្ងប់ស្ងាត់ គៀម និងក្រុមគ្រួសារបាននាំគ្នាវិលត្រឡប់ទៅស្រុកភូមិវិញ ។ រយៈពេលមួយឆ្នាំក្រោយមក ខ្មែរក្រហមបានចូលកាន់កាប់នៅក្នុងភូមិស្រុករបស់គាត់ ហើយគាត់ត្រូវបានអង្គការចាត់តាំងឲ្យទៅក្រុមប្រវាសដៃ ។ ចំណែកឯកូនៗរបស់គាត់ ត្រូវអង្គការចាត់ឲ្យទៅរើសអាចម៍គោជាមួយក្មេងៗដទៃទៀត ។ គៀម បានរំឭកថា នៅក្នុងក្រុមប្រវាសដៃ អង្គការតម្រូវឲ្យគាត់ដកស្ទូងពេញមួយថ្ងៃ ស្ទើរតែគ្មានពេលឈប់សម្រាក ។ គាត់បានឮអ្នកភូមិនិយាយតៗគ្នាថា ទិន្នផលស្រូវដែលប្រមូលបាន ត្រូវអង្គការដឹកទៅដាក់ក្នុងជង្រុកធំមួយ ហើយដឹកទៅឃ្លាំងនៅភ្នំពេញ បន្ទាប់មក ដឹកចេញទៅកំពង់ផែយ៉ាងប្រុងប្រយ័ត្នបំផុត ។ ប៉ុន្តែគាត់មិនដឹងច្បាស់ពីគោលដៅថាដឹកចេញទៅកាន់ប្រទេសណាខ្លះនោះទេ ។

ក្រៅពីការងារដកស្ទូង គាត់ត្រូវបានអង្គការចាត់ឲ្យចូលទៅកងចល័តដើម្បីរែកដី ទាំងយប់ទាំងថ្ងៃ គ្មានពេលសម្រាក ។ គៀម បានដកដង្ហើមធំ រួចបន្តរៀបរាប់ពីការលំបាករបស់គាត់ថា គាត់ត្រូវបានអង្គការឲ្យលើកទំនប់១មករា ដែលស្ថិតនៅក្នុងខេត្តកំពង់ធំជាមួយនឹងកងចល័តផ្សេងៗទៀតដែលបានកេណ្ឌមកពីគ្រប់ខណ្ឌនិងសង្កាត់ ។ គៀម ព្រមទាំងអ្នកភូមិត្រូវក្រោកពីយប់ និងត្រូវធ្វើដំណើរដោយថ្មើរជើងដើម្បីទៅរែកដី និងលើកទំនប់១មករា ។ ទំនប់នោះ មានចម្ងាយប្រហែលមួយគីឡូម៉ែត្រពីផ្ទះដែលគាត់ស្នាក់នៅ ។ គាត់បានបន្ថែមទៀតថា លក្ខខណ្ឌការងារនៅទំនប់ ១មករា គឺពិតជាអាក្រក់ណាស់ ហើយមានមនុស្សជាច្រើនត្រូវបានស្លាប់នៅក្នុងអំឡុងពេលលើកទំនប់នោះ ដោយសារតែការធ្វើការហួសកម្លាំង ការអត់អាហារ និងជំងឺ ។ អ្នកជំងឺដែលឈឺខ្លាំងត្រូវបានបញ្ជូនទៅមន្ទីរពេទ្យប្រចាំតំបន់ដោយការមើលជំងឺ និងព្យាបាលនោះ គឺគ្រាន់តែជាការផ្តល់ថ្នាំអាចម៍ទន្សាយឲ្យផឹកប៉ុណ្ណោះ ។ នៅពេលដែលអ្នកជំងឺមានសភាពធូរស្បើយ គឺត្រូវមកធ្វើការដូចដើមដោយមិនអនុញ្ញាតឲ្យឈប់សម្រាកទេសូម្បីតែថ្ងៃសៅរ៍ ឬ ថ្ងៃអាទិត្យ ។ ដោយឡែក អ្នកមានវ័យចំណាស់ដែលមានកូនចៅនៅផ្ទះអាចសុំមេក្រុមមកស្នាក់នៅផ្ទះ បន្ទាប់ពីដល់ម៉ោងឈប់សម្រាក ប៉ុន្តែចំពោះកំលោះក្រមុំមិនអាចសុំបានទេ ។

គៀម បានបន្តទៀតថា របបអាហារនៅទីនោះគឺមានតែបបររាវៗពីរដងក្នុងមួយថ្ងៃ គឺពេលព្រឹក និងពេលល្ងាចប៉ុណ្ណោះ ដូច្នេះហើយទើបធ្វើឲ្យរូបរាងកាយរបស់គាត់កាន់តែមានសភាពទ្រុឌទ្រោមពីមួយថ្ងៃទៅមួយថ្ងៃ ។ គាត់បានអះអាងថា ទំនប់១មករានេះ ចាប់ផ្តើមកសាងឡើងកាលពីដើមឆ្នាំ១៩៧៦ និងបញ្ចប់នៅឆ្នាំ១៩៧៩ ។

នៅពេលដែលវៀតណាមចូលមកនៅចុងឆ្នាំ១៩៧៨ កម្មាភិបាលខ្មែរក្រហមគ្រប់រូបបានបំផុសស្មារតីប្រជាជនថា វៀតណាមនឹងចូលមកស្រុកយើងដើម្បីធ្វើការសម្លាប់ប្រជាជននៅក្នុងប្រទេសយើង ។ ប្រជាជនមួយភាគធំដែលឮបែបនេះមានភាពភ័យខ្លាច ខ្លះបានរត់ពួន ខ្លះរត់ចូលព្រៃ ខ្លះប្តេជ្ញាចិត្តតស៊ូនឹងវៀតណាម ។ ប៉ុន្តែ បន្ទាប់ពីកងទ័ពវៀតណាមចូលមក ប្រជាជនឃើញថាសភាពការណ៍មិនដូចអ្វីដែលកម្មាភិបាលខ្មែរក្រហមបានប្រាប់ ទើបក្រុមគ្រួសារគាត់ ព្រមទាំងអ្នកស្រុកបាននាំគ្នាវិលត្រឡប់មកស្រុកកំណើត និងរស់នៅជុំគ្រួសារវិញ ។ **ហួរ ហាច**

## ស្តាប់រឿងរ៉ាវប្រវត្តិសាស្ត្រតាមវិទ្យុ

មជ្ឈមណ្ឌលឯកសារកម្ពុជាមានកម្មវិធី “សំឡេងអំពើប្រល័យពូជសាសន៍ ៖ យុត្តិធម៌ និងការអត់ឃ្មាន” ចាក់ផ្សាយតាមស្ថានីយ៍វិទ្យុ ◆ វិទ្យុជាតិកម្ពុជា FM 105.75 MHz រាជធានីភ្នំពេញវេលាម៉ោង១រសៀល និងម៉ោង៧និង៣០នាទីល្ងាច ◆ វិទ្យុខេត្តកំពត FM 93.25 MHz វេលាម៉ោង៧ព្រឹក និងម៉ោង៧ល្ងាច ◆ វិទ្យុខេត្តព្រះវិហារ FM 99 MHz វេលាម៉ោង៧:៣០ព្រឹក និងម៉ោង៤រសៀល ◆ វិទ្យុខេត្តបាត់ដំបង FM 103.25 MHz វេលាម៉ោង៨ព្រឹក និងម៉ោង៤រសៀល ។

សម្រាប់ព័ត៌មានលម្អិត សូមទាក់ទង ម៉ែន ពិចិត្រ តាមរយៈរយៈទូរស័ព្ទ ០២៣ ២១១ ៨៧៥ ឬ ០៩២ ១៦៨ ៥៤៣ ។

# រឿងរ៉ាវរបស់ ឯក ស៊ីប៉ូរ៉ាន់

ឯក ស៊ីប៉ូរ៉ាន់ ជាកសិករម្នាក់រស់នៅភូមិត្រពាំងព្រីង ឃុំគុស ស្រុកត្រាំកក់ ខេត្តតាកែវ ។ សព្វថ្ងៃ នេះគាត់មានអាយុ៥១ឆ្នាំ ហើយ ។ អ៊ំស្រីមានបងប្អូនចំនួនប្រាំមួយនាក់ ហើយគាត់ជាកូនទីប្រាំ ។ កាលពីមុនសម័យខ្មែរក្រហម គាត់បានទៅរស់នៅជាមួយបងនៅខេត្តព្រះសីហនុដើម្បីរៀន ។ នៅទីនោះ គាត់ធ្វើជាគ្រូបង្រៀនភាសាខ្មែរ និងភាសាបារាំង នៅតាមផ្ទះ ។ នៅថ្ងៃ១៧ ខែមេសា ឆ្នាំ១៩៧៥ ខ្មែរក្រហមបានជម្លៀសគាត់ពីកំពង់សោមមកខេត្តកំពត ។ រ៉ាន់ មានប្រសាសន៍ថា ប្រសិនបើគាត់មិនព្រមធ្វើតាមខ្មែរក្រហមទេ ខ្មែរក្រហមនឹងយកយើងទៅសមុទ្រ ហើយអ្នកដែលទៅសមុទ្រហើយ គឺភាគច្រើនបាត់ខ្លួន ។ ចំណែកការប្រើពាក្យគ្មានអ្វីក្រៅពីពាក្យ មិត្ត នោះទេ ហើយប្រសិនបើនរណាម្នាក់ហ៊ាននិយាយថា ស្អប់ខ្មែរក្រហម ស្អប់ ប៉ុល ពត មិនចង់ឲ្យអ្នកទាំងនោះចូលស្រុក គឺកងឈ្លបនឹងមកចាប់មិនខាន ជាក់ស្តែងអ៊ំស្រី និងជីដូនមួយរបស់ រ៉ាន់ ត្រូវបានអង្គការយកទៅសម្លាប់ចោល ។ មានអ៊ំស្រីរបស់ រ៉ាន់ ម្នាក់ទៀតចេះភាសាចិន ហើយនៅពេលគាត់កំពុងនិយាយជាមួយបងរបស់គាត់ ស្រាប់តែពេលនោះមានអ្នកជិតខាងម្នាក់បានឮ និងបានហាមឃាត់ព្រោះខ្លាចកងឈ្លបយកទៅសម្លាប់ចោល ។ ចាប់តាំងពីថ្ងៃនោះមក អ៊ំស្រីរបស់ រ៉ាន់ ឈប់និយាយភាសាចិនរហូត ។

នៅខេត្តកំពត ខ្មែរក្រហមបានបញ្ជូល រ៉ាន់ ទៅក្នុងក្រុមទី៩ សហករណ៍ទី១៣ និងឲ្យទៅដកស្ទូងតាមសហករណ៍ ។ ចំណែករបបអាហារ គឺទាល់តែគាត់ទៅជីកប្រឡាយ ឬក៏លើកទំនប់រួចទើបអង្គការចែកឲ្យ ។ រហូតដល់ពេលថ្ងៃត្រង់ ទើបអង្គការបំបែកកងចល័តពីកន្លែងការដ្ឋានធ្វើការឲ្យមកហូបបាយតាមសហករណ៍វិញ ដោយ



កងចល័តកុមារត្រឡប់មកពីការដ្ឋាន

ចុងភៅចែកបាយឲ្យមួយកូនឆ្នាំងសម្រាប់មនុស្ស១៣នាក់ ហូបជាមួយនឹងសម្លមួយមុខ ។ ទោះបីជាគាត់ហូបបាយនៅសល់អស់សម្លហើយចង់ទុកហូបទៀតក៏អង្គការមិនអនុញ្ញាតដែរ ។ នៅពេលនោះប្រសិនបើអ្នកណាហ៊ានទាមទារសុំទឹកត្រី ឬក៏សុំអំបិលនោះ ច្បាស់ជាមានឈ្លបតូចៗមកហៅទៅ ហើយនឹងមិនត្រឡប់មកវិញទេ ។

ពេលធ្វើការនៅទីនោះ រយៈពេលមួយអាទិត្យឬពីរអាទិត្យ មានកូនឈ្លបតូចៗយកបាយដំណើបដែលពូតជាដុំយកមកចែកឲ្យគាត់ និងអ្នកឯទៀតហូប ។ មួយអាទិត្យម្តង អង្គការបានហៅគាត់ទៅប្រជុំស្ម័យទិតៀន ។ នៅពេលប្រជុំ អង្គការបានចែកដំឡូងមីឲ្យហូប ដោយម្នាក់ៗទទួលបានមួយដុំតូច ។ ប៉ុន្តែ ប្រសិនបើមានអ្នកណាថា ហូបមិនឆ្អែតនោះឈ្លបនឹងនាំយកទៅ ។ នៅសម័យនោះ បើនរណាម្នាក់មានជំងឺ ហើយមិនទៅធ្វើការ ឈ្លបហៅអ្នកនោះថាគ្រុនទន្សាយ ហើយប្រសិនរកឃើញថាយើងធ្វើពុត ប្រាកដជាឈ្លបយកទៅកសាង និងកាត់បន្ថយរបបអាហារ ។ ចំណែកអ្នកលួចគេចពីការងារ នឹងមានកូនឈ្លបដើររកមិនខាន ។ ថ្ងៃមួយ ពេល វ៉ាន់ ទៅរកក្តាម គាត់ក៏ឮសំឡេងមីក្រូ ។ វ៉ាន់ ឆ្ងល់យ៉ាងខ្លាំង ហើយក៏ដើរទៅរកកន្លែងចាក់មេក្រូ ។ ពេលទៅដល់ វ៉ាន់ ឃើញកងឈ្លបសម្លាប់មនុស្ស ដោយយកដំបងមកវាយ និងបាញ់ទៅលើអ្នកទោស ។

ការរស់នៅរបស់ វ៉ាន់ កាន់តែលំបាកទៅៗ ចំណែកអ្នកដែលធ្វើការនៅក្នុងកងរបស់គាត់ ខ្មែរក្រហមបានយកទៅសម្លាប់ជាបន្តបន្ទាប់ នៅសល់តែពីរនាក់ប៉ុណ្ណោះ ។ បន្ទាប់មក មានមេកងម្នាក់បានមកស្នើសុំ វ៉ាន់ រៀបការ ។ លុះពេលយប់ឡើង ពេលមេកងនោះទៅបាត់ គាត់ក៏បាននិយាយថា គេប្រធានហើយ យើងមិនយកគេម៉េចបាន ។ គ្រាន់តែនិយាយដូចនេះ នៅវេលាប្រហែលជាម៉ោង១២យប់ នៅខែឧសភា ឆ្នាំ១៩៧៨ មានកងឈ្លបមកហៅ និងចង វ៉ាន់ យកទៅ ។ ក្រោយមក បានដោះលែងគាត់មកវិញ ប៉ុន្តែបានចាត់តាំង វ៉ាន់ ឲ្យរែកដី ដោយមិនឲ្យឈប់សម្រាកទេ ។

នៅយប់មួយ បន្ទាប់ពីធ្វើការរួចហើយ វ៉ាន់ បាននិយាយថា មីចិនអស់ហ្នឹងប្រហែលជាជួយយើងហើយមើលទៅ ក៏ស្រាប់តែឈ្លបបីនាក់មកចាប់គាត់យកទៅម្តងទៀត ។ ឈ្លបបានយកចំពុះទុង



កងកុមារធាក់រហាត់ទឹកបញ្ចូលស្រែនៅក្នុងរបបខ្មែរក្រហម

មកចាក់ខ្នងរបស់ វ៉ាន់ ប្រសិនបើគាត់មិនដើរទៅមុខ ។ ឈ្លបតែងតែផ្លាស់ប្តូរពេលបណ្តើរ វ៉ាន់ ទៅដល់ស្នាក់ការនីមួយៗ ។ លុះទៅដល់កន្លែងទីស្នាក់ការនៅខេត្តកំពង់ស្ពឺ ឈ្លបបានឲ្យ វ៉ាន់ ដាំដំឡូងនៅទីនោះ ប៉ុន្តែពេលយប់ឈ្លបបានដាក់ច្រវាក់គាត់ ។ ពេលនៅក្នុងគុក វ៉ាន់ កើតជំងឺហើម និងរមាស់ ព្រោះមិនដែលបានងូតទឹក ។ ឈ្លបបានយក វ៉ាន់ ទៅវាយសួរចម្លើយ ដូចជា រៀនថ្នាក់ទីប៉ុន្មាន? ចេះអក្សរទេ? ម្តាយឪពុកធ្វើអ្វី? វ៉ាន់ បានឆ្លើយប្រាប់ទៅឈ្លបនោះវិញថាឪពុកម្តាយជាអ្នកស្រែ ។ នៅពេលវាយសួរចម្លើយរួច ឈ្លបឲ្យគាត់នៅម្តុំ រួចហើយឆែកឆេររករបស់មានតម្លៃ ។ ក្រោយមក ឆ្មាំគុកបានចាត់តាំងគាត់ឲ្យសែងខ្មោចអ្នកទោសដែលស្លាប់យកទៅកប់ ។ ទោះបីខ្លាចយ៉ាងណា ក៏ វ៉ាន់ មិនដែលហ៊ានប្រកែកដែរ ព្រោះខ្លាចឆ្មាំគុកធ្វើទារុណកម្ម ។ ប៉ុន្មានថ្ងៃក្រោយមក ក៏ស្រាប់តែមានកងទ័ពរណសិរ្ស ចូលមករំដោះ ទើប វ៉ាន់ បានរួចរស់ជីវិតរហូតមកដល់សព្វថ្ងៃនេះ ។

**អៀង ណារី**

# មួយឆ្នាំបានហូបបាយតែមួយរដូវ

អ៊ី យិន អាយុ៦៨ឆ្នាំ មានស្រុកកំណើតនៅភូមិចំបក់ ឃុំត្រពាំងក្រសាំង ស្រុកសន្ទុក ខេត្តកំពង់ធំ ។ គាត់មានបងប្អូន៦នាក់ (ប្រុសពីរនាក់ និងស្រីបួននាក់) ។ សព្វថ្ងៃនេះ យិន រស់នៅភូមិថ្មី ឃុំត្នោតជុំ ស្រុក បារាយណ៍ ខេត្តកំពង់ធំ ។

នៅពេលខ្ញុំសាកសួរទាក់ទងពីប្រវត្តិរបស់គាត់នៅក្នុងរបបខ្មែរក្រហម គាត់មានប្រសាសន៍ទាំងក្តុកក្តួលថា នៅមុនពេលរបបខ្មែរក្រហម គាត់រស់នៅនៅក្នុងគ្រួសារកសិករនៅភូមិកំណើត ។ គាត់បានបន្តថា ទោះបីពេលនោះមានរដ្ឋប្រហារទម្លាក់ សម្តេចសីហនុ ចេញពីអំណាចក៏ដោយ ក៏ការងាររបស់គាត់ហាក់ដូចជាមានភាពប្រសើរ និងអាចស្វែងរកប្រាក់កាសក្នុងការចិញ្ចឹមគ្រួសារបានយ៉ាងស្រួល ។ ចំពោះពេលវេលាវិញ គាត់មានពេលគ្រប់គ្រាន់ដើម្បីសម្រាក និងអាចដើរកម្សាន្តបានទៀតផង ។

រហូតមកដល់ខ្មែរក្រហមឡើងកាន់អំណាច គាត់មានការពិបាកយ៉ាងខ្លាំងដោយខ្មែរក្រហមឲ្យគាត់ធ្វើការងារហួសកម្លាំង និងមិនមានពេលវេលាគ្រប់គ្រាន់ដើម្បីសម្រាក ។ គាត់បានបន្ថែមថា នៅឆ្នាំ១៩៧៦ គាត់ត្រូវបានចាត់តាំងឲ្យទៅជីកទំនប់ ១មករា ចាប់ពីខែមករា រហូតដល់ខែមេសា ទើបខ្មែរក្រហមផ្លាស់គាត់ទៅកាន់ការដ្ឋានប្រុតកាត់វិញ ។



ប្រឡាយទឹកដែលជីកនៅក្នុងរបបខ្មែរក្រហម

ចំពោះការងារថ្មីនេះ គាត់ក៏មានការលំបាកខ្លាំងដែរ ព្រោះក្នុងស្រែមួយហិកតាអង្គការកំណត់ឲ្យមនុស្ស២០នាក់ប្រូតឲ្យហើយ ។ ប្រសិនបើអង្គការមើលឃើញថា យើងធ្វើការងារនោះលឿន និងហើយមុនពេលកំណត់ អង្គការនឹងដកកម្លាំងចេញខ្លះឲ្យទៅធ្វើការងារនៅកន្លែងផ្សេងដើម្បីឲ្យទាន់ផែនការ ។ ចំណែករបបអាហារនៅពេលដំបូង គាត់ហូបបាយ តែក្រោយមកគាត់ហូបតែបបរខាប់ និងកាន់តែរាវទៅៗ ។

អង្គការបានប្រាប់ថា ប្រទេសកំពុងជួបវិបត្តិ ហើយប្រជាជនត្រូវព្យាយាមធ្វើការជាបន្តទៀត ព្រោះឆ្នាំក្រោយនឹងមានបាយហូប ។ តែពាក្យសន្យាទាំងអស់នោះ បានត្រឹមតែឮនៅក្នុងត្រចៀករបស់គាត់ប៉ុណ្ណោះ តែមិនដែលឃើញអង្គការធ្វើតាមការសន្យាទេ ។ គាត់បាននិយាយថា នៅក្នុងមួយឆ្នាំ គាត់បានហូបបាយតែនៅក្នុងរដូវប្រូតកាត់ប៉ុណ្ណោះ ។ នៅពេលឈឺថ្កាត់ គាត់មិនហ៊ានឈឺនោះទេ ព្រោះខ្លាចមិនគង់ជីវិត ហើយបើទោះបីជាឈឺយ៉ាងណាក៏ដោយ ក៏គាត់មិនហ៊ានត្អូញត្អែរដែរ ។

យិន បានបន្តថា នៅក្នុងភូមិឃុំរបស់គាត់មានគ្រោះធម្មជាតិបានកើតឡើងនៅក្នុងឆ្នាំ១៩៧៨ ។ អង្គការបានចាត់តាំងឲ្យគាត់ទៅធ្វើស្រែលិចទឹក និងអ្នកខ្លះទៀត អង្គការឲ្យទៅលើកភ្លឺទប់កុំឲ្យទឹកជ្រាបចូលស្រែ និងបាចទឹចចេញពីស្រែ ។ គាត់ធ្វើការរហូតដល់ពេលប្រទេសបានរំដោះ ទើបគាត់មករស់នៅក្នុងភូមិឃុំរហូតដល់បច្ចុប្បន្នវិញ ។

ពេលសាកសួរពីសាលាក្តីខ្មែរក្រហមវិញ គាត់បាននិយាយថា គាត់មិនបានដឹងច្បាស់នោះទេ តែបើមានតុលាការនោះមែន គាត់ចង់ឲ្យតុលាការធ្វើការកាត់ក្តីទៅលើមេខ្មែរក្រហមដើម្បីរកយុត្តិធម៌ជូនប្រជាជន ក៏ដូចជារូបដែលបានឆ្លងកាត់ទុក្ខវេទនាក្នុងរបបនោះ ។

**ខន្ធ សុសីហា**

# ឪពុករបស់ខ្ញុំនៅក្នុងរបបប្រល័យ

ឪពុកខ្ញុំ កែវ យ៉ាន មានស្រុកកំណើតនៅឃុំពានី ស្រុកកំពង់ត្រឡាច ខេត្តកំពង់ឆ្នាំង ។ នៅឆ្នាំ១៩៦៩ ឪពុកខ្ញុំបានបួសជាព្រះសង្ឃ នៅវត្តពានី ។ គាត់រៀបរាប់ថា នៅពេលមានបុណ្យម្តងៗ មានមនុស្សជាច្រើននាំគ្នាទៅវត្តធ្វើបុណ្យ ដោយសេចក្តីសប្បាយរីករាយ ។ ក្រោយមក គឺនៅឆ្នាំ១៩៧០ សភាពការណ៍ចលាចលយ៉ាងខ្លាំង ។ នៅខណៈនោះដែរ គាត់ក៏បានមកបន្តការសិក្សាធម៌វិន័យនៅទីក្រុងភ្នំពេញ ដោយស្នាក់នៅវត្តលង្កា ។ ឪពុកខ្ញុំបានរៀនរហូតដល់ឆ្នាំ១៩៧២ ប៉ុន្តែគាត់មិនបានដឹងអំពីបញ្ហាសង្គមច្រើនទេ ។ គាត់ខិតខំប្រឹងប្រែងរៀនសូត្រ ដោយសារតែគាត់មានជីវភាពក្រីក្រ ។ម្យ៉ាងទៀត គាត់ចង់ប្រឡងធ្វើការងារក្នុងជួរមន្ត្រីរដ្ឋការ ។ មានថ្ងៃមួយ មានទាហានពាក់ផ្កាយបីបានមកធ្វើបុណ្យនៅវត្តលង្កា ដើម្បីសុំសេចក្តីសុខមុនពេលចេញទៅយុទ្ធជាមួយខ្មែរក្រហម ពេលនោះហើយទើបគាត់ដឹងថាសង្គ្រាមស៊ីវិលមានសភាពខ្លាំងក្លា ។

ឪពុកខ្ញុំបន្តថា មុនពេលខ្មែរក្រហមវាយបែកក្រុងភ្នំពេញ នៅតំបន់វិមានឯករាជ្យ គាត់ឃើញយន្តហោះអាមេរិកាំងចំនួន៨គ្រឿងមកដឹកអ្នកការទូតរបស់ខ្លួនចេញ ដោយបួនគ្រឿងហោះឃ្លាំមើលពីលើអាកាស ។ មានប្រជាជនខ្មែរជាច្រើនបានទៅជាមួយអ្នកទូតនោះ ដោយយន្តហោះដឹកប្រជាជនទាំងនោះយកទៅដាក់នៅខេត្តកោះកុង រួចហើយបញ្ជូនតទៅក្នុងទឹកដីថៃ និងមួយចំនួនទៀតដឹកទៅសហរដ្ឋអាមេរិកតែម្តង ។



កងភ្ជួរនៅក្នុងរបបខ្មែរក្រហម

ឪពុកខ្ញុំបានចាកចេញពីក្រុងភ្នំពេញ មុនយោធាខ្មែរក្រហមជម្លៀសប្រជាជនចេញបន្តិច ។ ឪពុកខ្ញុំបានលាចាកសិក្ខាបទនៅក្នុងវត្តអំពិលទឹក ស្ថិតនៅស្រុកកំពង់ត្រឡាច ខេត្តកំពង់ឆ្នាំង ។ នៅខែកក្កដា ឆ្នាំ១៩៧៥ ឪពុករបស់ខ្ញុំរស់នៅក្នុងសហករណ៍ឃុំច្រេស ។ ប្រធានសហករណ៍ បានចាត់តាំងគាត់ឲ្យដឹកជញ្ជូនស្បៀងទៅសហករណ៍ផ្សេងៗក្នុងឃុំច្រេស ដែលក្នុងកងគាត់មានមនុស្សបីនាក់ ។ ថ្ងៃមួយ ប្រធានសហករណ៍ប្រើបានចាត់តាំងអ្នកនៅក្នុងកងឲ្យទៅភ្ជួរស្រែ ដោយបន្សល់ឪពុកខ្ញុំនៅតែម្នាក់ឯងប៉ុណ្ណោះ ។ ឪពុករបស់ខ្ញុំមិនចេះបររទេះទេ គឺគាត់ជាអ្នកប្រមូលបន្លែដាក់រទេះពេលដឹកជញ្ជូនម្តងៗ ។ ឪពុកខ្ញុំបានបររទេះរហូតដល់ម៉ោងប្រមាណ ១០ ប៉ុន្តែដោយសារក្របីទ្រាំក្តៅមិនបាន ម្យ៉ាងទៀតដោយឪពុកខ្ញុំមិនចេះបររទេះ ក្របីក៏ទាញរទេះចូលទៅក្នុងទន្លេធ្វើឲ្យធ្លាក់បន្លែនិងអណ្តែតពេលផ្ទៃទឹក ។ ដោយដឹងអំពីរឿងនេះ បងប្រុសរបស់គាត់ (ត្រូវជាអ៊ំប្រុសរបស់ខ្ញុំ) ក៏បានស្នើឪពុកខ្ញុំទៅនៅសហករណ៍នៅក្នុងឃុំពានីវិញ ព្រោះគាត់ជាប្រធានសហករណ៍ ។

ឪពុកខ្ញុំធ្វើការជាអ្នកជួសជុលឧបករណ៍កសិកម្ម ដែលមិនសូវមានការលំបាកប៉ុន្មានទេ ។ ប៉ុន្តែគាត់នៅបានតែពីរខែប៉ុណ្ណោះ អង្គការនៅភូមិសេដ្ឋី ក៏ស្នើគាត់ឲ្យចូលទៅនៅក្នុងកងយុវជនឈានមុខ ដែលមានភារកិច្ចលើកភ្លឺស្រែ ជីកប្រឡាយ ឆ្ការព្រៃ និងគាស់គល់ឈើ ។ មួយខែក្រោយមក អង្គការបានបន្ថែមការងារឲ្យគាត់ធ្វើទៀត គឺពេលយប់ឲ្យគាត់ស្ទូងមួយហិកតាជាមួយមនុស្ស៧នាក់ ។

នៅខែធ្នូ ឆ្នាំ១៩៧៨ ឪពុកខ្ញុំបានធ្លាក់ខ្លួនឈឺជាទម្ងន់ ។ គាត់បានទៅសម្រាកព្យាបាលនៅមន្ទីរពេទ្យសហករណ៍ឃុំពានី ។ នៅទីនោះគ្មានថ្នាំវិទ្យាសាស្ត្រសម្រាប់ផឹកទេ គឺមានតែថ្នាំអាចម៍ទន្សាយប៉ុណ្ណោះ ។ ប៉ុន្តែ ដោយសារមានការមើលថែដិតដល់ពីសំណាក់បងប្រុសរបស់គាត់ ទើបធ្វើឲ្យគាត់ជាសះស្បើយ ។ គាត់បានរស់នៅទីនោះរហូតដល់ខ្មែរក្រហមដួលរលំ ។ **យ៉ុង សុធឿន**

# សៀវភៅរំឭកវិញ្ញាណក្ខន្ធអ្នកដែលបានស្លាប់ នៅក្នុងរបបខ្មែរក្រហម

មជ្ឈមណ្ឌលឯកសារកម្ពុជា គ្រោងនឹងបោះពុម្ពផ្សាយនូវសៀវភៅមានកត់ត្រាឈ្មោះរបស់អ្នកដែលស្លាប់បាត់បង់ជីវិតនៅក្នុងរបបខ្មែរក្រហម ។ កន្លងមក មជ្ឈមណ្ឌលឯកសារកម្ពុជាបានចងក្រងនូវឈ្មោះអ្នកដែលស្លាប់ជាង១លាននាក់រួចមកហើយ ។ ប្រសិនបើលោកយាយ លោកតា អ៊ំ ពូ មីង ប្រាថ្នាចង់ឲ្យឈ្មោះសមាជិកក្រុមគ្រួសារដែលបានស្លាប់បាត់បង់ជីវិតមាននៅក្នុងសៀវភៅនេះ សូមទាក់ទងមកកាន់មជ្ឈមណ្ឌលឯកសារកម្ពុជាតាមរយៈ អេង កុកថាយ ទូរស័ព្ទលេខ ០១២ ៧៩៧ ៣៩៤ ឬ អ៊ីម៉ែល ៖ truthkokthay@dccam.org ឲ្យបានឆាប់រហ័សតាមពេលវេលាដែលអាចធ្វើទៅបាន ។

***សូមផ្តល់ព័ត៌មានដូចខាងក្រោមៈ***

១) ឈ្មោះអ្នកប្រកាសប្រាប់, ២) តើមានបងប្អូនបង្កើតរួមទាំងឪពុកម្តាយស្លាប់ប៉ុន្មាននាក់នៅក្នុងសម័យខ្មែរក្រហម? ៣) ឈ្មោះអ្នកស្លាប់, ៤) ភេទអ្នកស្លាប់, ៥) អាយុអ្នកស្លាប់ (បើអាចចាំបាន), ៦) ត្រូវជាអ្វីនឹងអ្នកប្រកាស (ឧទាហរណ៍ៈ ឪពុក ម្តាយ បងប្រុស ប្អូនប្រុស បងស្រី ឬប្អូនស្រី), ៧) សាច់រឿងទាក់ទងនឹងការស្លាប់ (ឧទាហរណ៍ ៈ ស្លាប់នៅទីណា? មូលហេតុអ្វី?), ៨) វត្ថុតាងទាក់ទងនឹងអ្នកស្លាប់ (ឧទាហរណ៍ៈ រូបថត ឯកសារ ឬវត្ថុផ្សេងៗ), ៩) ព័ត៌មានសម្រាប់មជ្ឈមណ្ឌលទាក់ទង (ឧទាហរណ៍ៈ លេខទូរស័ព្ទ អាសយដ្ឋាន) ។

***ប្រសិនបើចង់ស្វែងរកអ្នកដែលបាត់ខ្លួនសូមផ្តល់ព័ត៌មានខាងក្រោមៈ***

១) ឈ្មោះអ្នកបាត់ខ្លួន, ២) ភេទ, ៣) អាយុ, ៤) ត្រូវជាអ្វី, ៥) សាច់រឿងទាក់ទងនឹងការបែកគ្នា, ៦) វត្ថុតាងទាក់ទងនឹងអ្នកបាត់ខ្លួន (ឧទាហរណ៍ៈ រូបថត ឯកសារ ឬវត្ថុផ្សេងៗ) ។










ដើម្បីយុត្តិធម៌និងការចងចាំ
ដែលជាមូលដ្ឋានដ៏សំខាន់ក្នុងការផ្សះផ្សាជាតិ

ឧបត្ថម្ភការបោះពុម្ពផ្សាយដោយ ទីភ្នាក់ងារអភិវឌ្ឍន៍អន្តរជាតិ សហរដ្ឋអាមេរិក (USAID)
អនុញ្ញាតឲ្យបោះពុម្ពផ្សាយដោយក្រសួងព័ត៌មាននៃព្រះរាជាណាចក្រកម្ពុជា ប្រកាសទេសរដ្ឋមន្ត្រីនិងរដ្ឋមន្ត្រីក្រសួងព័ត៌មានលេខ ០២៩១ពម.៩៩ចុះថ្ងៃទី២ ខែសីហា ឆ្នាំ១៩៩៩

**មជ្ឈមណ្ឌលឯកសារកម្ពុជា ៖ ការិយាល័យព័ត៌មានសាធារណៈ**
ផ្ទះលេខ ៦៦, មហាវិថីព្រះសីហនុ ភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរស័ព្ទ ៖ (៨៥៥) ២៣ ២១១ ៨៧៥ ទូរសារ ៖ (៨៥៥) ២៣ ២១០ ៣៥៨

DC-Cam/PIR : #66 ◆ Preah Sihanouk Blvd ◆ Phnom Penh ◆ Cambodia ◆ Tel: (855) 23 211 875 ◆ Fax: (855) 23 210 358 ◆ dccam@online.com.kh ◆ www.dccam.org.
A magazine of the Documentation Center of Cambodia: Searching for the truth. ◆ Number 171, March 2014 ◆ Funded by USAID.
Licensed by the Ministry of Information of the Kingdom of Cambodia, Prakas No.0291 P.M/99, 2 August 1999.